ISSN 1560-7615 / ISBN 978-99950-52-06-5


# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១១ លេខ ២ | មេសា - មិថុនា ឆ្នាំ២០០៧ | តម្លៃ ១.៥០០៛


## សន្និសីទចក្ខុវិស័យកម្ពុជាឆ្នាំ២០០៧: ចក្ខុវិស័យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ការពន្លឿនការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងចំណូលពីប្រេងកាត និងឧស្ម័នធម្មជាតិ



*ប្រទេសកម្ពុជាមានតំបន់ប្រេងកាតនៅបាតសមុទ្រ ៦កន្លែង និងតំបន់សម្បទានត្រួតគ្នាមួយ (OCA)*

នៅថ្ងៃទី២២-២៣ កុម្ភៈ ២០០៧ វិទ្យាស្ថាន CDRI ដោយរួមសហការជាដៃគូជាមួយធនាគារ ANZ Royal បានរៀបចំធ្វើសន្និសីទចក្ខុវិស័យកម្ពុជាឆ្នាំ២០០៧ នៅក្រុងភ្នំពេញ ។ សន្និសីទនេះមានការអញ្ជើញចូលរួម ពីសំណាក់ថ្នាក់ដឹកនាំជាង ២០០នាក់ មកពីរដ្ឋាភិបាល អាជីវកម្ម អង្គការសង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ដើម្បីពិភាក្សាពីបញ្ហាគន្លឹះៗរបស់កម្ពុជាទាក់ទិននឹងកំណើន ការអភិវឌ្ឍន៍ និងវិបុលភាព ។ សន្និសីទនេះ ដែលនឹងប្រារព្ធធ្វើជារៀងរាល់ឆ្នាំ មានបែងចែកជា ៦វគ្គ:

- កម្ពុជាឆ្នាំ២០០៧: ទិដ្ឋភាពម៉ាក្រូ - សូចនាករសំខាន់ៗនៃ កំណើន ការអភិវឌ្ឍន៍ និងវិបុលភាពរួម
- កម្ពុជាក្នុងចំណោមប្រទេសជិតខាងដែលមានកំណើន និងកាលានុវត្តភាព: ទស្សនវិស័យរបស់អ្នកជំនាញការមកពីចិន ថៃ និងវៀតណាម
- ការពង្រឹងពង្រីកក្បាលម៉ាស៊ីនកំណើន និងអភិវឌ្ឍន៍: ហិរញ្ញវត្ថុ ទីផ្សារ វិស័យឯកជន និងវិនិយោគផ្ទាល់ពីបរទេស
- ការចេញពីការពឹងផ្អែកលើជំនួយឆ្ពោះទៅកាន់វិបុលភាពរួម: ការគ្រប់គ្រងធនធានប្រេងកាត និងឧស្ម័នរបស់កម្ពុជា
- ការប្រយុទ្ធនឹងភាពក្រីក្រ: ដល់ពេលអនុវត្តសកម្មភាពមានកំណត់គោលដៅច្បាស់លាស់
- ទស្សនវិស័យ និងមាគ៌ាឆ្ពោះទៅមុខ

សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានលើកនៅក្នុងសុន្ទរកថាគន្លឹះបើកសន្និសីទថា:

*"ខ្ញុំសូមគូសបញ្ជាក់ថា ការពិភាក្សាយ៉ាងយកចិត្តទុកដាក់នៅក្នុងសន្និសីទនេះ ជាពិសេសការផ្ដល់នូវគំនិតល្អៗ និងយោបល់ជាក់ស្ដែងប្រកបដោយនិម្មាបនកម្ម នឹងរួមចំណែកជួយសំរួលដល់ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងរួមចំណែកសំរួលដល់ការសំរេចនៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាផងដែរ ។"*

*"ខ្ញុំសង្ឃឹមថា អ្នកចូលរួមទាំងអស់នឹងផ្ដល់គំនិតល្អៗស្ដីពីការកសាងសេដ្ឋកិច្ចឱ្យមានកំណើនប្រកបដោយចីរភាព ដើម្បីចែករំលែកផ្លែផ្កានៃការអភិវឌ្ឍន៍ប្រកបដោយសមភាព និងលើកកំពស់គុណភាពជីវភាពប្រជាជនកម្ពុជានៅគ្រប់ស្រទាប់សង្គម ។"*

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* លេខនេះមានចុះផ្សាយជាពិសេសនូវបទបង្ហាញគន្លឹះមួយចំនួនក្នុងសន្និសីទចក្ខុវិស័យកម្ពុជាលើកទី១ ។ បទបង្ហាញឯទៀត រួមទាំងសុន្ទរកថាទាំងស្រុងរបស់សម្ដេចនាយក មានចុះក្នុងវេបសាយរបស់ CDRI ។

## មាតិកា


សន្និសីទចក្ខុវិស័យកម្ពុជា ..... ១
កម្ពុជា: ការពិនិត្យស្ថានភាពម៉ាក្រូសេដ្ឋកិច្ចពីឆ្នាំ២០០៧ ..... ២
ចេញពីការពឹងផ្អែកលើជំនួយ ឆ្ពោះទៅកាន់វិបុលភាពរួម ..... ៥
បង្កើនល្បឿនការកាត់បន្ថយភាពក្រីក្រ ..... ១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ..... ១៦
— ស្ថានភាពក្នុងប្រទេស ..... ១៥
— សន្ទស្សន៍សេដ្ឋកិច្ច ..... ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ..... ២៤

# កម្ពុជាៈ ការពិនិត្យស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ពីឆ្នាំ២០០៧ ដល់រយៈពេលមធ្យម-សូចនាករសំខាន់ៗនៃកំណើន ការអភិវឌ្ឍន៍ និង វិបុលភាពរួម

*អេង នេត្រា និង ភីម រុនសុីណារិទ្ធិ បានសង្ខេប និងធ្វើសំយោគបទបង្ហាញរបស់តំណាងមកពី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងវិទ្យាស្ថាន វបសអ-CDRI ។**

កម្ពុជាបានទទួលសន្តិភាព និងស្ថិរភាពប្រសើរឡើងនៅទសវត្សរ៍ចុងក្រោយនេះ ហើយបានចាប់អនុវត្តគំនិតផ្តួចផ្តើមថ្មីជាច្រើន ដូចជា សេរីភាវូបនីយកម្មសេដ្ឋកិច្ច កំណែទំរង់ស្ថាប័ន កំណែទំរង់នយោបាយ ដើម្បីឆ្លើយតបទៅនឹងបំរែបំរួលសេដ្ឋកិច្ចនយោបាយ ។ កម្ពុជាបានរៀបចំ និងគ្រប់គ្រងការបោះឆ្នោត និងបង្កើតស្ថាប័នរដ្ឋ ហើយថ្មីៗនេះបានអនុវត្តដោយជោគជ័យនូវការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទីពីរ ដែលជាផ្នែកមួយនៃដំណើរការវិមជ្ឈការនៅប្រទេសកម្ពុជា ។

កម្ពុជាបានកែលំអសេវាសង្គមចំបងៗ ដូចជា ការថែទាំសុខភាព អប់រំ ហេដ្ឋារចនាសម្ព័ន្ធជនបទ និងប្រព័ន្ធស្រោចស្រព ។ សេដ្ឋកិច្ចមានដំណើរការល្អណាស់ ប៉ុន្តែការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិ និងអភិបាលកិច្ច នៅតែជាបញ្ហាប្រឈម ។ យោងតាមបទបង្ហាញ នៅវគ្គទីមួយនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៧ របស់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មូលនិធិរូបិយវត្ថុអន្តរជាតិ និងវិទ្យាស្ថាន CDRI អត្ថបទនេះបានសង្ខេប និងធ្វើសំយោគ នូវជោគជ័យនៃការអភិវឌ្ឍន៍ និងបញ្ហាប្រឈមចំបងៗ មានទាំងកំណើនសេដ្ឋកិច្ច រហូតដល់អភិបាលកិច្ច ។

## ការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ចៈ លទ្ធផលថ្មីៗ និងចក្ខុវិស័យរយៈពេលមធ្យម

*ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើបទបង្ហាញផ្តោតជាសំខាន់លើបញ្ហាសេដ្ឋកិច្ចចំបងៗ ដែលកម្ពុជាកំពុងប្រឈម ដូចជា លទ្ធផលម៉ាក្រូសេដ្ឋកិច្ច ការវិវត្តន៍ខាងសារពើពន្ធ លទ្ធផលក្នុងវិស័យហិរញ្ញវត្ថុ និងចក្ខុវិស័យលើកំណើនសេដ្ឋកិច្ចទូទៅ សំរាប់ឆ្នាំ២០០៧-២០១៥ ។ ខាងក្រោម ជាសេចក្តីសង្ខេបនៃបញ្ហាទាំងនេះ ។*

*ក្រាហ្វិក ១: អត្រាកំណើនសេដ្ឋកិច្ចឆ្នាំ២០០២-២០១០*




*r = បានពិនិត្យឡើងវិញ e = ប៉ាន់ស្មាន p = ព្យាករណ៍*

*ប្រភពៈ ហង់ ជួនណារ៉ុន*

កម្ពុជាមានការរីកចំរើន និងស្ថិរភាពខាងម៉ាក្រូសេដ្ឋកិច្ចគួរឱ្យកត់សំគាល់ ព្រមទាំងកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ជាមធ្យម ៨,៧% ក្នុងមួយឆ្នាំនាទសវត្សរ៍ចុងក្រោយ ។ ផលិតផលក្នុងស្រុកសរុប (ផសស) ពិត កើន ១០,៤% នៅឆ្នាំ២០០៦ (ក្រាហ្វិក ១) ដោយសារជាសំខាន់មកពីការរីកចំរើនខាងការនាំចេញផលិតផលកាត់ដេរ វិស័យទេសចរណ៍ និងសកម្មភាពសាងសង់ ។ ការនាំចេញផលិតផលកាត់ដេរកម្ពុជា កើន ២០% នៅឆ្នាំ២០០៦ ដល់ ២,៩ពាន់លានដុល្លារ និងផ្តល់ការងារចំនួន ៣៣៤.០០០ ។ សហរដ្ឋអាមេរិកជាអតិថិជនសំខាន់ជាងគេ ដោយបានទទួលទិញ ៧១% បន្ទាប់មកតំបន់អឺរ៉ុប ២៣% និងកាណាដា ៤% ។ ទេសចរណ៍ និងសកម្មភាពសាងសង់ នៅតែខ្លាំងក្លាដដែលនៅឆ្នាំ២០០៦ ។ ចំនួនភ្ញៀវទេសចរ បានរួមចំណែកយ៉ាងសំខាន់ធ្វើអោយ ផសស កើនដល់ ១,៧លានដុល្លារ ។ ផ្ទះល្វែងថ្មីៗសាងសង់នៅភ្នំពេញ កំពុងកើនឡើងពី ៨០០០ ទៅ ១០០០០ផ្ទះ ជារៀងរាល់ឆ្នាំ ហើយគំរោងទីក្រុងថ្មីមួយនៅបឹងពោងពាយ បានចាប់ផ្តើមនៅឆ្នាំ២០០៦ ។ ក្រុមហ៊ុនចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម មានសរុប ១១.៥៨៤ក្រុមហ៊ុន ក្នុងនេះ ១៦០០ ជាក្រុមហ៊ុនចុះបញ្ជីថ្មីនៅឆ្នាំ២០០៦ ។

នៅឆ្នាំ២០០៦ លទ្ធផលសារពើពន្ធកើនឡើង ដោយសារការប្រមូលចំណូល និងសនិទានកម្មចំណាយ បានកាន់តែប្រសើរ ។ អតិរេកថវិកាចរន្តកើនដល់ ១,៨% នៃ ផសស ហើយឱនភាពថវិកាទូទៅ ធ្លាក់ចុះមកត្រឹម ១,៧% នៃ ផសស ។ ចំណូលសរុបកើនពី ៦៦០លានដុល្លារអាមេរិកនៅឆ្នាំ២០០៥ ដល់ ៨៣២លានដុល្លារអាមេរិកនៅឆ្នាំ២០០៦ ដោយសារកំណើនការប្រមូលចំណូលពន្ធ និងចំណូលមិនមែនពន្ធ ។ ចំណាយសរុប កើនឡើងពី ៨៥៣លានដុល្លារអាមេរិក នៅឆ្នាំ២០០៥ ដល់ ៩៥៩លានដុល្លារអាមេរិកនៅឆ្នាំ២០០៦ ក្នុងនេះ ការអភិវឌ្ឍន៍ហេដ្ឋា

* អត្ថបទនេះរៀបរៀងឡើង ដោយផ្អែកលើបទបង្ហាញរបស់លោកបណ្ឌិត ហង់ ជួនណារ៉ុន អគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោក John Nelms តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ IMF ប្រចាំនៅកម្ពុជា និងលោកស្រី អេង នេត្រា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI នៅសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៧ ។ លោក ភីម រុនសុីណារិទ្ធិ ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ។

រថនាសម្ព័ន្ធ គឺជាវិស័យអាទិភាព ដោយត្រូវចំណាយថវិកាអស់ ៤៥លានដុល្លារអាមេរិក ។ កំណើនសេដ្ឋកិច្ចរឹងមាំ និងការវិនិយោគខ្លាំងក្លាលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធជនបទ ក៏នាំឱ្យមានការរីកចំរើនគួរកត់សំគាល់ដែរ ក្នុងវិស័យសង្គមកិច្ច ដូចជាការថយចុះនៃអត្រាមរណៈកុមារ និងកំណើន អត្រាអក្ខរកម្ម ។

វិស័យហិរញ្ញវត្ថុនៅកម្ពុជា លូតលាស់បានល្អនៅឆ្នាំ២០០៦ ។ រូបិយវត្ថុទូទៅ (M2) កើនបាន ៣៨% ធៀបនឹងកំណើន ១៦% នៅឆ្នាំ២០០៥ ដោយសារកំណើនការជឿទុកចិត្តលើប្រព័ន្ធធនាគារ ដែលជាលទ្ធផលនៃកំណែទំរង់ធនាគារ ។ បញ្ញើរូបិយវត្ថុបរទេស កើន ៤៥% និងឥណទានធនាគារចំពោះវិស័យឯកជន កើន ៥១% ។ ការរីកចំរើននៃមីក្រូហិរញ្ញវត្ថុក៏គួរឱ្យកត់សំគាល់ដែរ ។ កំចីមីក្រូហិរញ្ញវត្ថុ កើន ៤០% ដល់ ៥៦លានដុល្លារ នៅឆ្នាំ២០០៥ ។ តាមការបាន់ស្មាន លំហូរវិនិយោគផ្ទាល់បរទេសមានចំនួន ៣៩៤លានដុល្លារ នៅឆ្នាំ២០០៦ ធៀបនឹង ៣៨១លានដុល្លារ នៅឆ្នាំ២០០៥ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័ត ៨៨គំរោងវិនិយោគ មានទឹកប្រាក់សរុប ៣,៨ពាន់លានដុល្លារ ដែលគេរំពឹងថា នឹងបង្កើតបាន ១៥៤.០០០ការងារ បើសិនអនុវត្តបានពេញលេញ ។

សេដ្ឋកិច្ចប្រទេសកម្ពុជាមានអនាគតភ្លឺស្វាងល្អណាស់ ។ នៅក្នុងរយៈពេលមធ្យម ផសស រំពឹងថានឹងកើន ៩% នៅឆ្នាំ២០០៧ និង ៧-៨% នៅឆ្នាំ២០០៨-០៩ នៅក្នុងនេះ វិស័យទេសចរណ៍ ឧស្សាហកម្មកាត់ដេរ និងសកម្មភាពសាងសង់ នៅតែជាសសរទ្រូងនៃកំណើន ហើយកសិកម្មមានតួនាទីជួយទ្រទ្រង់ ។ នៅក្នុងរយៈពេលវែង ផលិតផលក្នុងស្រុកសរុប (ផសស) រំពឹងថានឹងរីកលូតលាស់ ៩-១០% នៅឆ្នាំ២០១០-១៥ ។ ចាប់ពីឆ្នាំ២០១០ ចំណូលពីប្រេងកាត នឹងក្លាយជាប្រភពថ្មីមួយនៃកំណើន ហើយដើរតួនាទីយ៉ាងសំខាន់ជួយរក្សាអត្រាកំណើនដ៏ខ្ពស់នេះ ។ ថ្វីបើវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ នៅតែបន្តជំរុញកំណើន កម្ពុជាត្រូវធ្វើចំរុះកម្មប្រភពកំណើន ដោយកសាងឧស្សាហកម្មថ្មីៗ ដើម្បីធ្វើអោយកំណើនកាន់តែមានមូលដ្ឋានធំទូលាយ ។

ទន្ទឹមនឹងនេះដែរ វាទាមទារអោយមានកំណែទំរង់គោលនយោបាយគ្រប់ជ្រុងជ្រោយ សំដៅធ្វើអោយការវិនិយោគនៅប្រទេសកម្ពុជាកាន់តែមានលក្ខណៈទាក់ទាញ ។ ដើម្បីសំរួលដល់សកម្មភាពពាណិជ្ជកម្ម គេត្រូវដោះស្រាយបញ្ហាកាត់បន្ថយថ្លៃប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ អគ្គិសនី កំពង់ផែ និងកំរៃមិនផ្លូវការផ្សេងៗ ហើយគួរបង្កើតតំបន់កែច្នៃសេដ្ឋកិច្ច (economic processing zones) ដើម្បីទាក់ទាញវិនិយោគទុនពីបរទេស ។

កំណែទំរង់សម្បទានសេដ្ឋកិច្ចមិនដំណើរការ កំណែទំរង់ដីដើម្បីទប់ស្កាត់ការរំលោភយកដីធ្លីពីជនជាតិភាគតិច គោលនយោបាយបង្កើនលទ្ធភាព កសិករក្នុងការទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសគ្រាប់ពូជល្អៗ មីក្រូហិរញ្ញវត្ថុ អគ្គិសនី និងប្រព័ន្ធស្រោចស្រព គឺជាកត្តាចាំបាច់សំរាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម ។ ម្យ៉ាងទៀត ដើម្បីទ្រទ្រង់កំណើនក្នុងវិស័យនេះ ការធ្វើចំរុះកម្មផលិតផលកសិកម្ម ការម៉ៅការឱ្យផ្សព្វផ្សាយពី ផលិតផលម៉ាស៊ីននិងសេវាកម្មប្រភេទខ្លះ ដូចជា ប្រតិបត្តិការការិយាល័យនៅជួរក្រោយ (back office operations) ផ្នែកធនាគារ គណនេយ្យ និងផ្នែកផ្សេងៗទៀត ហើយការជំរុញអាជីវកម្មកែច្នៃផលិតផលកសិកម្ម និងការបង្កើតអង្គការកសិករ ក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ ។

*លោក John Nelmes តំណាង IMF ប្រចាំនៅកម្ពុជា បានធ្វើបទបង្ហាញផ្តល់មតិអំពីការវិវត្តន៍ម៉ាក្រូសេដ្ឋកិច្ចកម្ពុជានាពេលថ្មីៗ និងចក្ខុវិស័យសំរាប់ឆ្នាំ២០០៧ និងរយៈពេលមធ្យម ដែលមានជាសង្ខេបដូចតទៅ:*

*ក្រាហ្វិក ២: សមាភាគនៃអត្រាកំណើន ផសស ពិត*




*ប្រភព: John Nelmes*

សេដ្ឋកិច្ចកម្ពុជា ទោះបីមានមូលដ្ឋានតូចចង្អៀតក្តី ក៏មានកំណើនរឹងប៉ឹងនៅឆ្នាំ២០០៦ និងមានអតិផរណាទាប ។ កំណើន ផសស មានសន្ទុះលឿនជាងអត្រាកំណើនសំរាប់ពិភពលោកទាំងមូល និងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ។ ការនាំចេញផលិតផលកាត់ដេរនៅតែខ្លាំងក្លា វិស័យទេសចរណ៍បានបន្តរីកចំរើន ហើយវិស័យកសិកម្ម និងនេសាទ ក៏មានកំណើនវិជ្ជមានដែរ (ក្រាហ្វិក ២) ។

ការវិវត្តន៍ទាំងនេះ មានការជួយទ្រទ្រង់ពីគោលនយោបាយសារពើពន្ធដ៏ប្រុងប្រយ័ត្នរបស់រដ្ឋាភិបាល ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗ មានការរីកចំរើនក្នុងកិច្ចបង្កើនចំណូលរដ្ឋាភិបាលជាទូទៅ ។ ការពង្រឹងអនុវត្តន៍ខ្លាំងក្លានៃការប្រមូលពន្ធក្នុងស្រុក និងពន្ធគយ ព្រមទាំងបំណុលពន្ធយឺតយ៉ាវមិនទាន់បង់ និងចំណូលពីឯកជនភាវូបនីយកម្ម អាចជួយប៉ះប៉ូវលើសពីគ្រប់គ្រាន់នូវការធ្លាក់ចុះជាបន្តបន្ទាប់នៃចំណូលមិនមែនពន្ធ ។ ប៉ុន្តែ ការប្រមូលចំណូលនៅតែបានទាបជាខ្លាំងជាងប្រទេសឯទៀត ។

សកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសបន្តរីកចំរើន ដោយសារការអនុវត្តន៍នយោបាយរូបិយវត្ថុដ៏ប្រុងប្រយ័ត្ន និងការធ្វើអន្តរការីកម្មហិរញ្ញវត្ថុ កាន់តែស៊ីជំរៅដោយវិស័យធនាគារ ។ អាជីវកម្មខ្នាតតូចដែលកាលពីមុនធ្វើប្រតិបត្តិការក្នុងវិស័យមិនផ្លូវការ កំពុងទៅចុះបញ្ជីកាន់តែច្រើនឡើង និងស្វែងរកហិរញ្ញវត្ថុពីធនាគារ ព្រមទាំងមានសកម្មភាពសាងសង់យ៉ាងខ្លាំងក្លា ដែលឆ្លុះបញ្ចាំងពីការរីកធំឡើងនៃតំរូវការវិនិយោគក្នុងផ្នែកអចលនទ្រព្យ ។

ចក្ខុវិស័យចំពោះម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យមនៅតែល្អប្រសើរ ។ សេដ្ឋកិច្ចរំពឹងថាមានកំណើនពិតប្រហែល ៩% នៅឆ្នាំ២០០៧ ដោយមានការបន្តរីកចំរើនក្នុងការនាំចេញផលិតផលកាត់ដេរ ទេសចរណ៍ និងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ។ ក្នុងរយៈពេលមធ្យម កំណើនរំពឹងថា អាចមានចីរភាពនៅកំរិត ៧-៨% ។ ថ្វីបើប្រមើលមើលឃើញប្រសើរបែបនេះក្តី កម្ពុជាត្រូវប្រឹងប្រែងប្រមូលចំណូលបន្ថែម សំដៅបង្កើនអត្រាទាបជាប្រវត្តិសាស្ត្រនៃចំណូលធៀបនឹង ផសស សំរាប់ធ្វើហិរញ្ញប្បទានច្រើនថែមទៀតដល់ការចំណាយ ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា និង

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ម្យ៉ាងទៀត ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ត្រូវធ្វើកំណែទម្រង់ដ៏ចាំបាច់មួយចំនួន ។ ស្របជាមួយនឹងកំណើនចំណូលរដ្ឋ ត្រូវមានការបែងចែកចំណាយបន្ថែមទៀត ទៅអនុវត្តគំរោងមានផលិតភាព និងការកំណត់គោលដៅបានល្អខាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការថែទាំសុខភាព និងការអប់រំ ដើម្បីលើកស្ទួយជីវភាពរស់នៅ និងពង្រឹងផលិតភាព ។ សំខាន់ដូចគ្នាដែរ កម្ពុជាគួររៀបចំបរិយាកាសសេដ្ឋកិច្ចឱ្យអំណោយផលច្រើនដល់វិស័យឯកជន នឹងវិនិយោគបរទេស តាមរយៈការបន្តប្រឹងប្រែងជួយសំរួលពាណិជ្ជកម្ម និងកាត់បន្ថយទំងន់ហួសហេតុនៃរដ្ឋបាលសាធារណៈ ។

## ចក្ខុវិស័យវិទ្យាស្ថាន CDRI ចំពោះការអភិវឌ្ឍន៍ និងបញ្ហាប្រឈម

*លោកស្រី អេង នេត្រា ប្រធានស្រាវជ្រាវផ្នែកអភិបាលកិច្ចនៅ CDRI បង្ហាញលទ្ធផលស្រាវជ្រាវនៃកម្មវិធីស្រាវជ្រាវចំនួនបួនដែលមានសង្ខេបដូចតទៅ:*

*ការកាត់បន្ថយភាពក្រីក្របានជឿនលឿនទៅមុខ ប៉ុន្តែវិសមភាពកើនឡើង*

ថ្វីបើមានកំណើនម៉ាក្រូសេដ្ឋកិច្ចជាទូទៅក៏រិតខ្ពស់ ប៉ុន្តែនៅទសវត្សរ៍ចុងក្រោយនេះ កម្ពុជាសំរេចបានការកាត់បន្ថយភាពក្រីក្រប្រចាំឆ្នាំត្រឹមតែ ១% ប៉ុណ្ណោះ ។ ការសិក្សារបស់វិទ្យាស្ថាន CDRI លើភាពក្រីក្របង្ហាញថា កំណើននេះមិនបានចែកចាយប្រកបដោយសមធម៌ទេ ហើយគំលាតរវាងអ្នកមាន និងអ្នកក្រ តំបន់ជនបទនិងទីក្រុង បានកើនឡើង ។ តួនាទី និងការរួមចំណែករបស់ស្ត្រីចំពោះសេដ្ឋកិច្ច មានកាន់តែច្រើនឡើង ដោយសារបំរែបំរួលមូលដ្ឋានសេដ្ឋកិច្ច ទោះបីមានស្ត្រីក្រីក្របំផុតកាន់តែច្រើននាក់ កំពុងលក់កំលាំងពលកម្ម ធ្វើចំណាកស្រុកទៅរកការងារធ្វើ និងបំពេញភារកិច្ចរបស់បុរស បន្ថែមលើតួនាទីជាមេផ្ទះរបស់ខ្លួន ។

### ការគ្រប់គ្រងធនធានធម្មជាតិកំពុងធ្លាក់ចុះ

អ្នកក្រ និងអ្នកក្របំផុតកាន់តែច្រើននាក់ ត្រូវពឹងផ្អែកខ្លាំងឡើងៗលើធនធានធម្មជាតិ ជាពិសេស ផលព្រៃឈើ និងជលផល ប៉ុន្តែលទ្ធភាពប្រមូលយកផលកំពុងថយចុះគួរឱ្យកត់សំគាល់ ។ ការសិក្សារបស់វិទ្យាស្ថាន CDRI បង្ហាញថា អភិបាលកិច្ចធនធានធម្មជាតិវាសំខាន់បំផុត និងត្រូវគ្រប់គ្រងឱ្យមានចីរភាព ដើម្បីកាត់បន្ថយភាពក្រីក្រ ពីព្រោះធនធានទាំងនោះគឺជាទ្រព្យសម្បត្តិចំបងគេសំរាប់អ្នកក្រ ។ ក្នុងសុន្ទរកថាបើកសន្និសីទ សម្ដេចនាយករដ្ឋមន្ត្រី មានប្រសាសន៍ថា ការគ្រប់គ្រងដីធ្លីគឺជាអាទិភាពមួយរបស់សម្ដេច ដើម្បីកាត់បន្ថយភាពក្រីក្រ ។ សុវត្ថិភាពកាន់កាប់ដី ជាបញ្ហាមួយសំខាន់បំផុតសំរាប់ប្រជាជនក្រីក្រនៅកម្ពុជា ។ ប្រជាជនក្រីក្រកាន់តែច្រើនកំពុងបាត់បង់ដីដោយសារ "ការលក់ពេលមានអាសន្ន" បញ្ហាសុខភាព និងការរំលោភយកដី ។ វិទ្យាស្ថាន CDRI គាំទ្រយ៉ាងខ្លាំងដល់កិច្ចខំប្រឹងប្រែងចុះបញ្ជីដីធ្លី ប៉ុន្តែគួរពន្លឿនវាថែមទៀត និងផ្ដោតលើតំបន់ទាំងឡាយណា ដែលជួយកាត់បន្ថយភាពក្រីក្របានច្រើនបំផុត ។

ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម បង្ហាញថា ទោះបីជាដែននេសាទសហគមន៍អាចផ្ដល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋានក្ដី ប៉ុន្តែប្រយោជន៍ទាំងនោះមិនបានបែងចែកមានសមភាពល្អឡើយ ។ តំបន់នេសាទដែលបើកចំហសំរាប់ជនទូទៅ បែរជាផ្ដល់ប្រយោជន៍ច្រើន ដល់គ្រួសារអ្នកមាន និងអ្នកខាងក្រៅ (ដូចជា មន្ត្រីថ្នាក់ជាតិ និងឈ្មួញ) ទៅវិញ ។ ការស្រាវជ្រាវបង្ហាញទៀតថា ការគ្រប់គ្រងព្រៃធម្មជាតិធ្វើឡើងដោយថ្នាក់ជាតិ និងគ្មានការចូលរួមពីប្រជាជនមូលដ្ឋាន បានផ្ដល់ផលប៉ះពាល់សេដ្ឋកិច្ចអវិជ្ជមានយ៉ាងច្រើនដល់សហគមន៍ ។ ជំរើសថ្មីៗនៃការគ្រប់គ្រងព្រៃឈើផ្អែកលើសហគមន៍ ត្រូវមានជាចាំបាច់ដើម្បីផ្ដល់សមភាពក្នុងការប្រមូលផលព្រៃឈើ ។ បញ្ហាប្រឈមក្នុងការគ្រប់គ្រងធនធានធម្មជាតិមាន (១) អាណត្តិ និងសិទ្ធិអំណាចមិនច្បាស់លាស់ និងប្រទាំងប្រទើសគ្នា ដែលកាន់តែធ្ងន់ធ្ងរឡើងដោយសារដែនសមត្ថកិច្ចកំណត់មិនច្បាស់លាស់ (២) អំពើពុករលួយនៅថ្នាក់មូលដ្ឋាន ដែលរារាំងដល់ការពង្រឹងអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិ ស្ដីពីលទ្ធភាពប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិ ។

### កំណែទំរង់ស្ថាប័នសំខាន់ៗសំរេចបានហើយ ប៉ុន្តែគណនេយ្យភាពនៅទន់ខ្សោយ

រដ្ឋាភិបាលកម្ពុជាអាចរក្សាបានស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ក្នុងទសវត្សរ៍ចុងក្រោយ ហើយបច្ចុប្បន្នកំពុងអនុវត្តបានល្អក្នុងការកាត់បន្ថយភាពក្រីក្រ និងកែលំអសេវាសាធារណៈ ។ ប៉ុន្តែជាទូទៅ រដ្ឋាភិបាលមិនទាន់មានលទ្ធភាពបង្កើតនីតិរដ្ឋប្រឆាំងអំពើពុករលួយ បង្កើតបរិយាកាសទាក់ទាញវិនិយោគិន រឺបង្កើតជាយន្តការគណនេយ្យភាពនៅឡើយទេ ។ ថ្វីបើសមត្ថភាពបច្ចេកទេសរបស់មន្ត្រីរាជការកំពុងពង្រឹងទៀត ប៉ុន្តែអង្គការចាត់តាំងរបស់រដ្ឋនៅមិនទាន់ផ្សារភ្ជាប់គ្នាបានល្អទេ ។ ការពឹងផ្អែកលើការបង្គាប់បញ្ជាពីថ្នាក់លើមានក៏រិតខ្ពស់ យន្តការគណនេយ្យភាពផ្លូវការនៅទន់ខ្សោយ ហើយការសំរបសំរួលយ៉ាងសក្ដិសិទ្ធនៅក្នុងក្រសួង នឹងរវាងក្រសួងនានាមានតិចតួចបំផុត ។

ការសិក្សារបស់វិទ្យាស្ថាន CDRI ក៏បង្ហាញដែរថា អាជ្ញាធរថ្នាក់ក្រោមជាតិនៅតែមានលក្ខណៈមជ្ឈការ និងពាក់ព័ន្ធនយោបាយក៏រិតខ្ពស់ ។ ការគ្រប់គ្រងបែបមជ្ឈការ និងកង្វះខាតធនធាន ធ្វើអោយអាជ្ញាធរថ្នាក់ក្រោមជាតិទន់ខ្សោយ និងការគ្រប់គ្រងបុគ្គលិកនៅតាមមូលដ្ឋាន ការរៀបចំផែនការ និងការគ្រប់គ្រងចំណាយគ្មានប្រសិទ្ធភាព ។ ជាលទ្ធផល អ្នកគ្រប់គ្រងនៅមូលដ្ឋាន មិនអាចចាប់ឱ្យបុគ្គលិកខ្លួនមានគណនេយ្យភាពបានឡើយ ហើយពួកនោះជារឿយៗ ត្រូវបានអូសទាញដោយការងារ និងផលប្រយោជន៍ខាងក្រៅ ។ រឿងនេះធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ច និងប្រជាជន ជាពិសេសលើអ្នកក្រ និងអាជីវកម្មខ្នាតតូច ។ ស្ថាប័នរដ្ឋ មានសមត្ថភាពមិនទាន់គ្រប់គ្រាន់ដើម្បីជួយសំរួលឱ្យស្ត្រីបានចូលរួមធ្វើសេចក្ដីសំរេចចិត្តនៅគ្រប់ក៏រិត និងដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់ក្រុមងាយរងគ្រោះ ដូចជា អ្នកក្រ និងស្ត្រី ។

ក្រុមប្រឹក្សាឃុំបានផ្ដល់សេចក្ដីសង្ឃឹមខ្លះៗថា អាចកែលំអអភិបាលកិច្ចនៅថ្នាក់មូលដ្ឋានបាន ។ ការសិក្សារបស់វិទ្យាស្ថាន CDRI បង្ហាញថា ក្រុមប្រឹក្សាឃុំធ្វើការមានប្រសិទ្ធភាពល្អលើផ្នែកនានា ដូចជា ហេដ្ឋារចនាសម្ព័ន្ធជនបទដែលរួមមាន ការសាងសង់ផ្លូវ ប្រព័ន្ធស្រោចស្រព និងស្ពាន ។ អ្នកក្រក៏ទទួលបានប្រយោជន៍ផងដែរ ពីកិច្ចសហការរវាង NGOs និងក្រុមប្រឹក្សាឃុំ ។ ដោយសារក្រុមប្រឹក្សាឃុំមានធនធាន និងសិទ្ធិអំណាចតិចតួច ជាពិសេសនៅពេលដោះស្រាយបញ្ហាធនធានធម្មជាតិ រឺបញ្ហាពាក់ព័ន្ធនឹងតួអង្គខាងក្រៅដែលមានឥទ្ធិពល និងឋានៈខ្ពស់ជាង ពួកគេមិនមានលទ្ធភាពការពារនយោបាយប្រជាធិបតេយ្យ សេវាមានប្រសិទ្ធភាព រឺធនធានធម្មជាតិសំខាន់ៗឡើយ ។ រឿងនេះ ចង្អុលបង្ហាញពីសារៈសំខាន់ធំធេងនៃសមត្ថភាពគ្រប់គ្រងរដ្ឋបាល និងត្រិះរិះធ្វើសេចក្ដីសំរេចចិត្ត ដែលនឹងមានចែងច្បាស់នៅក្នុងច្បាប់រៀបចំអង្គការនាពេលខាងមុខ ព្រមទាំងសារៈសំខាន់នៃទំនាក់ទំនងថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន និងអន្តរសកម្មភាពរវាងប្រព័ន្ធអភិបាលកិច្ចផ្លូវការ និងមិនផ្លូវការ ។

កម្មវិធីកំណែទំរង់ចំបងៗរបស់រដ្ឋាភិបាល ដូចជា វិមជ្ឈការនិងវិសហមជ្ឈការ

*តទៅទំព័រទី ១៤*

# ចេញពីការពឹងផ្អែកលើជំនួយ ឆ្ពោះទៅកាន់វិបុលភាពរួម: ការគ្រប់គ្រងធនធានប្រេងកាត និងឧស្ម័នរបស់កម្ពុជា*

*អត្ថបទនេះ រួមបញ្ចូលនូវបទបង្ហាញស្តីពីការគ្រប់គ្រងធនធានប្រេងកាតនិងឧស្ម័នរបស់កម្ពុជា ដោយលោក Douglas Gardner អ្នកសំរបសំរួលនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និង ឯ.ឧ. Joseph Mussomeli អគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជានៅសន្និសីទចក្ខុវិស័យកម្ពុជា នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៧ ព្រមទាំងមានការបូកសរុបជាទូទៅដោយលោកបណ្ឌិត សុខ ស៊ីណា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ។*

## ការបូកសរុបទូទៅដោយវិទ្យាស្ថាន CDRI

យោងតាមអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) ប្រទេសកម្ពុជាមានតំបន់ប្រេងកាតនៅបាតសមុទ្រ ៦កន្លែង (តំបន់ A, B, C, D និង F) និងតំបន់សម្បទានត្រួតគ្នាជាមួយថៃ (OCA) មួយកន្លែង ។ តំបន់ជុំវិញបឹងទន្លេសាបក៏អាចមានប្រេងកាតនិងឧស្ម័ន (O&G) ដែរ ហើយសព្វថ្ងៃកំពុងធ្វើការស្រាវជ្រាវ ។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងធនាគារពិភពលោក (WB) ប៉ាន់ស្មានថា ចំណូលប្រចាំឆ្នាំពី O&G អាចមានរហូតដល់ ២ពាន់លានដុល្លារ រីឯរដ្ឋាភិបាលកម្ពុជាបានព្យាករណ៍ទាបជាខ្លាំងត្រឹម ១០០-៣០០លានដុល្លារ ប៉ុណ្ណោះ ។ ទោះបីតួលេខប៉ាន់ស្មានវាខុសគ្នាក្តី ប៉ុន្តែមានការយល់ស្របជាទូទៅថា ចំណូលពីការនាំចេញ O&G អាចកាត់បន្ថយការពឹងផ្អែករបស់កម្ពុជាលើជំនួយអភិវឌ្ឍន៍បរទេស និងជួយជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ច ។

មានបទពិសោធន៍ជាក់ស្តែងជាច្រើនបង្ហាញថា ប្រទេសសំបូរធនធានខ្លះនៅតែមិនរីកចំរើន ទោះបីជាបានទទួលចំណូលសន្ធឹកសន្ធាប់ពីការនាំចេញធនធានធម្មជាតិក៏ដោយ ។ សេដ្ឋវិទូនានា បានធ្វើការពិពណ៌នាបាតុភូតនេះថាជា "បណ្តាសាធនធាន" ដោយសំដៅដល់ការលូតលាស់ និងអភិវឌ្ឍន៍អវិជ្ជមានដែលពាក់ព័ន្ធនឹងសម្បត្តិធម្មជាតិ ។ បណ្តាសាធនធានមានមូលហេតុច្រើនយ៉ាង ដូចជា "ជំងឺហូឡង់" រឺការថយចុះនៅក្នុងវិស័យនាំចេញមិនមែនប្រេងកាតជាដើម ។ មូលផលផ្សេងទៀត អាចជាការខ្ជះខ្ជាយ អំពើពុករលួយដែលនាំឱ្យថយចុះវិនិយោគ ហើយនៅប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនអាចកើតមានទំនាស់ហិង្សាទៀតផង ។ រីឯ "ពរធនធាន" សំដៅដល់ទំនាក់ទំនងវិជ្ជមានរវាងកំណើន/អភិវឌ្ឍន៍ ហើយនិងសម្បត្តិធម្មជាតិ ។ ប្រទេសដែលអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបានល្អ ទាន់ពេលវេលា និងចេះប្រើប្រាស់ចំណូលពីប្រេងកាតដោយឈ្លាសវៃ អាចជំនះលើហានិភ័យនៃបណ្តាសាធនធានបាន ។

ឥទ្ធិពលអវិជ្ជមានខ្លះអាចកើតមាននៅពេលយកចំណូល O&G មកប្រើដោយគ្មានផែនការ និងការគ្រប់គ្រងដោយប្រុងប្រយ័ត្ន ។ ទំនិញប្រើប្រាស់ជាទូទៅអាចឡើងថ្លៃ ហើយប្រាក់រៀលអាចឡើងថ្លៃដែរ ដែលធ្វើឱ្យចុះខ្សោយដល់សមត្ថភាពប្រកួតប្រជែងនៃទំនិញនាំចេញជាកសិផលសំរាប់លក់យកប្រាក់ និងផលិតផលពីវិស័យកាត់ដេរ ។ ការថយចុះទំនិញនាំចេញទាំងនេះ អាចនាំឱ្យមនុស្សជាច្រើនអស់ការងារធ្វើ ហើយបង្កផលវិបាកធ្ងន់ធ្ងរដល់សេដ្ឋកិច្ចទាំងមូល ។

សកម្មភាព និងកំរិតថ្លៃក្នុងវិស័យមិនមែនពាណិជ្ជកម្ម ដូចជាវិស័យសំណង់ និងសេវាកម្ម ក៏ប្រហែលកើនឡើងដែរ ដោយសារមានតំរូវការខ្ពស់ និងអំណាចទិញខ្លាំងពីវិស័យ O&G ។ អាគារ ផ្ទះ ដី នឹងឡើងថ្លៃទាំងអស់ ប្រសិនតំរូវការរបស់ទាំងនេះ កើនឡើងដោយសារកំលាំងប្រាក់ចំណូលពីប្រេងកាត ហើយកម្ពុជាអាចក្លាយជាប្រទេសត្រូវចំណាយអស់ច្រើនជាងគេក្នុងការរស់នៅ និងវិនិយោគ ។

ថ្វីបើចំណូលពី O&G នាំឱ្យមានហានិភ័យច្រើន ប៉ុន្តែវាក៏ផ្តល់ឱកាសពិសេសបំផុតសំរាប់ឱ្យរដ្ឋាភិបាល ប្រើប្រាស់ធនធានទាំងនេះដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយធ្វើវិនិយោគទៅលើផ្លូវជាតិ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ការអប់រំ សុខាភិបាល ផ្លូវជនបទ ប្រព័ន្ធស្រោចស្រព និងសេវាផ្សេងៗ ។ ការវិនិយោគទៅលើសម្បត្តិសាធារណៈទាំងនេះ នឹងនាំឱ្យមានកំណើនក្នុងរយៈពេលខ្លី និងវែង ។ ចំណូលពីប្រេងកាត ក៏អាចយកមកប្រើប្រាស់ដើម្បីពង្រឹងសំណាញ់សុវត្ថិភាពសង្គម ដោយបង្កើតមូលនិធិសង្គម និងមូលនិធិសោធននិវត្តន៍ ។ ការវិនិយោគទាំងនេះ អាចផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជនកម្ពុជា ដូច្នេះវានឹងជួយសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា (CMDGs) ។

ចំណូលពីប្រេងកាត ក៏ផ្តល់ឱកាសល្អមួយដែរសំរាប់ឱ្យរដ្ឋាភិបាលពន្លឿនកំណែទំរង់ក្នុងវិស័យសាធារណៈ ដោយបង្កើនប្រាក់បៀវត្សរ៍មន្ត្រីរាជការកសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល និងការកែលំអបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធនានាឱ្យទាន់សម័យឡើង ។ ចំណូលនេះក៏អាចប្រើប្រាស់សំរាប់ផ្តល់ការគាំទ្រខាងបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ឧស្សាហកម្មក្នុងស្រុក និងសិប្បកម្ម ដែលនឹងជួយកាត់បន្ថយការពឹងផ្អែកលើទំនិញនាំចូល និងបង្កើតការងារបានច្រើនឱ្យប្រជាជនកម្ពុជាធ្វើ ។

សរុបមក ចំណូលពី O&G នឹងធ្វើឱ្យប្រទេសធូរធារឡើងបើសិនបំពេញបានលក្ខខណ្ឌមួយចំនួន ។ ចំណូលមិនមែនជាបណ្តាសាទេ ប៉ុន្តែបែបបទប្រើប្រាស់និងគ្រប់គ្រងវា អាចហុចផលជា "បណ្តាសា" រឺជា "ពរ" ។ វិទ្យាស្ថាន CDRI មានទស្សនវិស័យថា ចំណូលពី O&G នឹងគ្រប់គ្រងបានល្អ ហើយប្រើប្រាស់ប្រកបដោយឈ្លាសវៃ ដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ ។

* អត្ថបទរៀបរៀងឡើងដោយ បណ្ឌិត សុខ ស៊ីណា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI នេះឆ្លុះបញ្ចាំងពីបទបង្ហាញរបស់ ឯ.ឧ. Joseph Mussomeli ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា និងលោក Douglas Gardner អ្នកសំរបសំរួលនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា នៅសន្និសីទចក្ខុវិស័យកម្ពុជា នៅថ្ងៃទី២២-២៣ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលរៀបចំដោយវិទ្យាស្ថាន CDRI ដោយរួមសហការជាមួយ ធនាគារអេអិនហ្សែតរ៉ូយ៉ាល់ ។

# ឱកាសជាប្រវត្តិសាស្ត្រដើម្បីសំរេចបានវិបុលភាពរួម និងធានាចីរភាពក្នុងរយៈពេលវែង

*បទបង្ហាញដោយលោក **Douglas Gardner** អ្នកសំរបសំរួលនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា*

*"កម្ពុជា ត្រូវតែរៀនពីប្រទេសដទៃទៀត ប្រើប្រាស់ចំណូលពីប្រេងកាត ឱ្យមានប្រសិទ្ធភាព និងជៀសវាងបណ្តាសាពីប្រេងកាត" ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅវេទិកាសេដ្ឋកិច្ចកម្ពុជា នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ ។*

ចំណូលយ៉ាងច្រើនពី O&G នៅបាតសមុទ្រកម្ពុជាដែលនឹងចាប់ផ្តើមបូមយកបានប្រហែលនៅឆ្នាំ២០១០ គឺជាឱកាសតែមួយពិតៗសំរាប់ធានាកំណើនរយៈពេលវែងក្នុងប្រទេស ជួយកាត់បន្ថយភាពក្រីក្រឱ្យបានកាន់តែច្រើន បង្កើនសមធម៌ និងពង្រឹងស្ថិរភាពនៅប្រទេសកម្ពុជាដែលសំរេចបានដោយលំបាកកន្លងមក ។

## ឱកាសនេះល្អឯក ដោយសារហេតុផលច្រើនៈ

ហេតុផលទី១ គឺ O&G ភាគច្រើននៅបាតសមុទ្រ ពុំមានម្ចាស់ដីឯកជន រឺក្រុមម្ចាស់ដីណាមួយអាចទាមទារយកជាកម្មសិទ្ធិបានទេ ។ ដោយសារវាជាធនធានធម្មជាតិនៅបាតសមុទ្រកម្ពុជា វាពិតជារបស់ប្រជាជនកម្ពុជាគ្រប់ៗគ្នា ។

ហេតុផលទី២ គឺ O&G នៅបាតសមុទ្រ វាជាធនធានថ្មី និងគ្មានបញ្ហាលំបាកស្មុគស្មាញនៅក្នុងប្រវត្តិសាស្ត្រថ្មីៗនេះទេ ។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាមានសេរីភាព និងលទ្ធភាពអាចបត់បែនបានច្រើន ដើម្បីប្រើប្រាស់វាជួយលើកស្ទួយសុខមាលភាពរបស់ប្រជាជនភាគច្រើន ។

ហេតុផលទី៣ គឺតាមរយៈលទ្ធផលរកឃើញជាដំបូងៗ ប្រេងកាតនិងឧស្ម័ន (O&G) នៅបាតសមុទ្រនេះ អាចផ្តល់ចំណូលហិរញ្ញវត្ថុយ៉ាងច្រើនដល់រដ្ឋាភិបាល ដែលគ្រប់គ្រាន់ដើម្បីបង្កើនគួរឱ្យកត់សំគាល់នូវការផ្គត់ផ្គង់សេវាសុខាភិបាល ការអប់រំ និងការថែទាំសុខភាពមានគុណភាព ពន្លឿនការរីកចំរើន ឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា (CMDGs) ជួយធានាកំណើនសេដ្ឋកិច្ចរយៈពេលវែង និងពង្រឹងស្ថិរភាពរយៈពេលវែងរបស់កម្ពុជា ។

## តើមានប្រេងច្រើនប៉ុណ្ណា?

បរិមាណប្រេងសំរាប់ធ្វើពាណិជ្ជកម្មមិនទាន់បញ្ជាក់ច្បាស់នៅឡើយទេ ប៉ុន្តែលទ្ធផលរកឃើញជាដំបូងៗ មានសង្ឃឹមច្រើនណាស់ ។ បរិមាណប្រេងពាណិជ្ជកម្មនៅតំបន់ A កំពុងត្រូវបានវាយតំលៃដោយក្រុមហ៊ុន Chevron ។ តួលេខប៉ាន់ស្មានប្រាកដប្រជា ប្រហែលទទួលបាននៅពាក់កណ្តាលឆ្នាំនេះ ។ តួលេខដំបូងៗបំផុត ដែលផ្សព្វផ្សាយនៅឆ្នាំមុន គឺមានប្រេងរហូតដល់៧០០លានធុង គ្រាន់តែនៅតំបន់ A មួយកន្លែងប៉ុណ្ណោះ ។

យោងតាមថ្លៃប្រេងនៅទីផ្សារអន្តរជាតិជាមធ្យម ៦០ដុល្លារ/ធុង បរិមាណប្រេងពាណិជ្ជកម្ម អាចផ្តល់ចំណូលសុទ្ធប្រចាំឆ្នាំដល់ថវិកាជាតិប្រហែល ១,៧ពាន់លានដុល្លារ[១] ។ ទឹកប្រាក់នេះតំណាងឱ្យបីដងនៃជំនួយអភិវឌ្ឍន៍ពីបរទេស (ODA) រឺជិតបីដងនៃចំណូលថវិកាចរន្ត និងលើសពី៥០% នៃចំណូលបានពីការនាំចេញទំនិញ ។

ទោះបីគេធ្វើការសន្មតយ៉ាងប្រយ័ត្នប្រយែងថា អាចទទួលបានចំណូលតែពាក់កណ្តាលតួលេខខាងលើក្តី ក៏វានៅតែអាចផ្តល់ប្រហែល ០,៨៥ពាន់លានដុល្លារ ដល់ដំណើការថវិកាជាទូទៅរបស់រដ្ឋាភិបាលដែរ ។ វានឹងអាចរួមចំណែកធ្វើឱ្យចំណូលចំណាយថវិកាចរន្តកើនឡើងមួយជាពីរ ដោយធ្វើឱ្យចំណាយចរន្តខាងសុខាភិបាល និងអប់រំ អាចកើនជិតបួនដង ហើយនៅតែអាចបង្កើនគួរឱ្យកត់សំគាល់នូវខ្ទង់ចំណាយផ្សេងៗទៀត[២] ។

## ពរ រឺ បណ្តាសា?

ចំណូលពី O&G អាចជាឱកាសមួយដ៏ល្អបំផុតរបស់កម្ពុជាក៏ពិតមែន ប៉ុន្តែការស្រាវជ្រាវសេដ្ឋកិច្ច-សង្គមកិច្ច ឧបត្ថម្ភដោយ UNDP ក្នុងកិច្ចសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) និងអាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) នៅឆ្នាំ២០០៥-២០០៦ ក៏បានបង្ហាញដែរថា វាអាចជាការគំរាមកំហែងដ៏ធំបំផុតមួយដល់សុខមាលភាព និងស្ថិរភាពយូរអង្វែងនៅកម្ពុជា ។

ការសន្និដ្ឋានទាំងនេះ មានមូលដ្ឋានរឹងមាំយោងតាមបទពិសោធន៍ជាង ៤០ឆ្នាំកន្លងមក នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មានចំណូលទាបជាច្រើន ។ ភាគច្រើននៃប្រទេសកំពុងអភិវឌ្ឍន៍សំបូរប្រេងកាត និងរ៉ែ (O&M) បានទទួលផលប៉ះពាល់អវិជ្ជមានពីកំណើនចំណូលបានពីធនធានទាំងនេះ ហើយប្រទេសខ្លះត្រូវរងគ្រោះរង្គើថែមទៀតផង[៣] ។

ជាទូទៅ ការស្រាវជ្រាវបង្ហាញឱ្យឃើញថា អត្រាកំណើនរយៈពេលវែងនៃប្រទេសកំពុងអភិវឌ្ឍន៍ដែលសំបូរប្រេងកាត និងរ៉ែ មានកំរិត ៣០-៥០% ទាបជាងប្រទេស កំពុងអភិវឌ្ឍន៍ខ្សត់ប្រេងកាត និងរ៉ែ ។ ម្យ៉ាងទៀត ប្រទេសសំបូររ៉ែធម្មជាតិ ក៏ចាញ់ប្រទេសខ្សត់រ៉ែដែរ ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយជាច្រើន[៤] ។

## បទពិសោធន៍សាកលលោកស្តីពីបណ្តាសាធនធាន

ការពិនិត្យបទពិសោធន៍ក្នុង ៤០ឆ្នាំកន្លងមក នៅប្រទេសកំពុងអភិវឌ្ឍន៍ដែលទទួលបណ្តាសាធនធាន បានបង្ហាញពីសញ្ញាប្រកាសអាសន្នមួយចំនួនដែលផុសឡើងនៅមុនពេលត្រូវរងគ្រោះធ្ងន់ធ្ងរដោយបណ្តាសា ។

សញ្ញានានាមានជាអាទិ៍ កំណើនយ៉ាងគំហុកនៃចំណូលរូបិយវត្ថុបរទេសបានមកពីការបូមយកធនធានធម្មជាតិមិនកកើតឡើងវិញ ព្រមទាំងៈ

- កង្វះតំលាភាពខាងហិរញ្ញវត្ថុ
- អភិបាលកិច្ចខាងហិរញ្ញវត្ថុអន់ខ្សោយ
- ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបាក់បែកជាដុំៗ និងមានចន្លោះប្រហោងច្រើន
- មូលដ្ឋានប្រមូលពន្ធតូចចង្អៀត និងអន់ខ្សោយ
- មានអំពើពុករលួយច្រើន និងលេចធ្លោ
- ជារដ្ឋកេងប្រវ័ញ្ច ដោយពួកមន្ត្រីព្យាយាមទាញយកប្រយោជន៍ផ្ទាល់ខ្លួន ឱ្យបានច្រើនបំផុត តាមរយៈការប្រើប្រាស់ដោយខុសឆ្គងនូវមុខតំណែងរដ្ឋ[៥]

- សមត្ថភាពគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចទន់ខ្សោយ រហូតដល់ទៅមាន "ជំងឺហូឡង់"
- ការខ្ចីបុលច្រើនៗ ដោយអាងធនធានប្រេង ។

## ធាតុផ្សំនៃពរ

ប្រទេសសំបូរប្រេងកាត ឧស្ម័ន ឬ រ៉ែ មួយភាគតូចដែលទទួលបានពរពីប្រេងកាត ក៏មានលក្ខណៈដូចគ្នាមួយចំនួនដែរ ដែលរួមមានការរំពឹងទុកពីកំណើនយ៉ាងគំហុកនៃប្រាក់ចំណូលបានពី ការប្រមូលយកធនធានធម្មជាតិដែលមិនកកើតឡើងវិញ ព្រមទាំងៈ

- ការរៀបចំផែនការទុកជាមុនសំរាប់ការគ្រប់គ្រង និងការធ្វើវិនិយោគដោយមានប្រសិទ្ធភាពនូវលំហូរហិរញ្ញវត្ថុដែលទទួលបាន
- មានតំលាភាពខ្ពស់
- មានការចូលរួមខ្លាំងក្លា និងសេចក្តីសំរេចសំខាន់ៗអំពីរដ្ឋសភា
- ស្ថាប័នសាធារណៈអភិវឌ្ឍន៍បានល្អ និងធ្វើការមានប្រសិទ្ធភាព
- អំពើពុករលួយមានកំរិតទាប និងមានប្រព័ន្ធច្បាប់ និងតុលាការដំណើរការល្អ
- សង្គមស៊ីវិលមានដំណើរការល្អ
- មានសមត្ថភាពគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចយ៉ាងសក្តិសិទ្ធិ
- មិនចូលចិត្តសន្សំបំណុល
- ការគ្រប់គ្រង និងវិនិយោគចំណូល អនុវត្តបានយ៉ាងសក្តិសិទ្ធិ ដើម្បីជំរុញការធ្វើចំរុះកម្មសេដ្ឋកិច្ច និងជៀសវាងការឡើងថ្លៃរូបិយវត្ថុក្នុងស្រុកហួសហេតុ
- អត្រាចំណាយធ្វើវិនិយោគ ដែលធានាបាននូវប្រសិទ្ធភាព និងសមធម៌នៅក្នុងកំរិតសមត្ថភាពរបស់រដ្ឋ និងសមត្ថភាពស្រូបយករបស់ប្រទេស (តាមធម្មតាត្រូវសំរួលដោយមូលនិធិធនធានធម្មជាតិមួយដែលមានតំលាភាព និងតាក់តែងបានល្អ)

## ចក្ខុវិស័យសំរាប់កម្ពុជា?

ច្បាស់ហើយថា ពរប្រេងកាត មិនមែនទទួលបានជាស្វ័យប្រវត្តិទេ ។ ប៉ុន្តែសំណាងល្អដែរ បទពិសោធន៍នៅបរទេស អាចផ្តល់ជាការណែនាំដ៏មានតំលៃ ។

រាប់ថាជាសំណាងល្អដូចគ្នា រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា បានផ្តល់មាគ៌ាដ៏សក្តិសិទ្ធិមួយ ដើម្បីអាចទទួលបានពរប្រេងកាត ។ រដ្ឋធម្មនុញ្ញណែនាំថា រដ្ឋត្រូវធ្វើផែនការមួយច្បាស់លាស់សំរាប់គ្រប់គ្រងធនធាន ដូចជា O&G ហើយផែនការនោះ ត្រូវអនុម័តដោយប្រជាជន តាមរយៈសំលេងអ្នកតំណាងរបស់ពួកគេនៅក្នុងរដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងតុលាការ[8] ។

ការធ្វើផែនការទុកជាមុន និងការចូលរួមយ៉ាងច្រើនរបស់ប្រជាជននៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត គឺជាកត្តាដ៏សំខាន់ដែលពរប្រេងកាតបានកើតឡើង ចំពោះប្រទេសមានជោគជ័យល្អៗជាងគេ ក្នុងការនាំចេញប្រេងកាត ។

ម្យ៉ាងទៀតយោងតាមបរិបទស្ថាប័ន និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា បទពិសោធន៍អន្តរជាតិបានបង្ហាញពីគោលនយោបាយសំខាន់ៗ កិច្ចការពារផ្នែកច្បាប់និងស្ថាប័ន ដែលត្រូវដាក់អនុវត្តឱ្យបានយូរគួរសម មុនពេលចំណូលពីប្រេងកាតហូរចូលមក ដើម្បីធានាថា កម្ពុជាអាចជៀសផុតពីបណ្តាសា និងទទួលបានពរពិតៗ ។

**ការងារគោលនយោបាយៈ** ត្រូវមាន ១) គោលនយោបាយច្បាស់លាស់ពីបែបបទគ្រប់គ្រងចំណូលពី O&G នាពេលអនាគត ២) គោលនយោបាយមានតំលាភាពពីរបៀបបែងចែកសម្បទាន O&G ដើម្បីឱ្យទូទាំងប្រទេសកម្ពុជា ទទួលបានអត្ថប្រយោជន៍ច្រើនបំផុត ៣) តំលាភាពលើប្រភេទ និងបរិមាណនៃការទូទាត់បង់ប្រាក់ និងលំហូរហិរញ្ញវត្ថុបានមកពីអាជ្ញាប័ណ្ណ O&G ការរុករក ការអភិវឌ្ឍន៍ និងការបូមយក និងជារួម គឺគោលនយោបាយច្បាស់លាស់ពីកំរិតតំលាភាពនៅក្នុងវិស័យនេះទាំងមូល ។

ប្រេងកាត និងឧស្ម័ននៅបាតសមុទ្រ គឺជាសម្បត្តិរបស់ប្រជាជនកម្ពុជាទាំងអស់គ្នា ដូច្នេះដាច់ខាតត្រូវមានការផ្តល់ព័ត៌មាន និងការបើកទូលាយនូវការជជែកវែកញែកជាសាធារណៈ ស្តីពីការប្រើប្រាស់ចំណូលពីប្រេងកាត និងឧស្ម័ន (O&G) នាពេលអនាគត ។ ដើម្បីឱ្យមានប្រសិទ្ធភាព និងអត្ថប្រយោជន៍ច្រើនបំផុតសំរាប់ប្រទេសទាំងមូល ការបែងចែកសម្បទានទៅឱ្យក្រុមហ៊ុនបរទេសគួរធ្វើឡើង តាមរយៈការដាក់ឱ្យដេញថ្លៃប្រកួតប្រជែងគ្នាជាការប្រសើរ ។

លក្ខខណ្ឌធំៗក្នុងកិច្ចសន្យាបែងចែកផលិតផល ដែលចែងពីរបៀបបែងចែកផលិតផល និងប្រភេទផ្សេងៗនៃលំហូរហិរញ្ញវត្ថុចូលមកកម្ពុជា គួរតែបើកទូលាយដល់សាធារណៈជនបានដឹង (ចេញជាសារព័ត៌មាន រឺដាក់នៅលើវេបសាយជាសាធារណៈ) ដើម្បីផ្តល់ព័ត៌មានអំពីការជជែកវែកញែកនានាជាសាធារណៈ ការរៀបចំផែនការពាក់ព័ន្ធ និងការធ្វើសេចក្តីសំរេចចិត្ត ។

**ការងារខាងច្បាប់ៈ** ត្រូវមានច្បាប់ដ៏ល្អមួយស្តីពីប្រេងកាត សំរាប់គ្រប់គ្រងធនធាននេះ ដោយមានការបែងចែកសមហេតុផលនូវការទទួលខុសត្រូវនៅក្នុងការងាររដ្ឋ និង រវាងរដ្ឋនិងវិស័យមិនមែនរដ្ឋ ។ ត្រូវធានាផងដែរឱ្យច្បាប់មានសេចក្តីចែងច្បាស់លាស់ និងរលូនគ្នាល្អជាមួយនឹងច្បាប់ផ្សេងៗទៀត (ឧ. ច្បាប់ស្តីពីសារពើពន្ធ ច្បាប់បរិស្ថាន ...) ។

**ការងារខាងស្ថាប័នៈ** នៅដំណាក់ការបច្ចុប្បន្ននៃការអភិវឌ្ឍន៍ស្ថាប័ននៅកម្ពុជា មានផលប្រយោជន៍ច្រើននឹងប្រើប្រាស់ថវិការដ្ឋ ដើម្បីកសាងមូលនិធិប្រេងកាតមួយ ដែលតាក់តែងបានល្អ និងមានតំលាភាព ដើម្បីធានាដល់ប្រសិទ្ធភាពនិងសមធម៌នៃចំណាយវិនិយោគ នៅក្នុងកំរិតមួយដែលកាត់បន្ថយជាអតិបរមានូវឱកាសដែលអាចកើតជំងឺហូឡង់ និងទទួលបណ្តាសាធនធានផ្សេងៗ ។

ដូចបានធ្វើហើយនៅប្រទេសមួយចំនួនដែលជៀសផុតពីបណ្តាសា លំហូរហិរញ្ញវត្ថុបានពី O&G អាចយកទៅដឹកលប់ជាដំបូងនៅក្នុងមូលនិធិមួយដូចបញ្ជាក់ខាងលើ មុនពេលបើកផ្តល់តាមនីតិវិធីទៅឱ្យថវិកាជាតិ សំរាប់ធ្វើហិរញ្ញប្បទាន ទៅឱ្យគំរោងវិនិយោគដែលស្ថិតនៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ។ ការបើកផ្តល់ត្រូវធ្វើតាមបរិមាណមួយដែលជំរុញឱ្យវិនិយោគមានប្រសិទ្ធភាពល្អ ក្នុងកំរិតសមត្ថភាពខាងស្ថាប័នដែលកំពុងអភិវឌ្ឍន៍ និងសមត្ថភាពស្រូបយករបស់ប្រទេស[10] ។

ជាទូទៅ ការពង្រឹងថែមទៀតនូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងជាកត្តាសំខាន់សំរាប់បញ្ចៀសបណ្តាសាធនធាន ។ កំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរដ្ឋាភិបាលកំពុងប្រឹងប្រែងបន្តទៅមុខ វារឹតតែសំខាន់បំផុតទៀត នៅចំពោះមុខលទ្ធភាពមានកំណើនប្រាក់ចំណូលពី O&G យ៉ាងគំហុកចាប់ពីឆ្នាំ២០១០ តទៅ ។

ម្យ៉ាងទៀត ក៏មានតំរូវការធ្វើការបែងចែកឱ្យសមហេតុផលនៃទំនួលខុសត្រូវខាងស្ថាប័ន និងសមត្ថភាពពាក់ព័ន្ធនៅក្នុងវិស័យប្រេងកាត ។ សមត្ថភាពរបស់ CNPA ត្រូវពង្រឹងបន្ថែមក្នុងផ្នែកបច្ចេកទេសជាច្រើន និង

ត្រូវកំណត់ឱ្យកាន់តែច្បាស់ ពីការបែងចែកការទទួលខុសត្រូវជាមួយអង្គភាពរដ្ឋផ្សេងទៀត ។

## ការធ្វើវិនិយោគក្នុងវិបុលភាពរួម និងស្ថិរភាពរយៈពេលវែងៈ ការជំរុញ CMDGs

បញ្ហាមួយទៀតដែលកម្ពុជាកំពុងប្រឈម គឺការលៃចែកចំណាយអោយមានប្រសិទ្ធភាព តាមរយៈដំណើរការផ្ទេរថវិកា និង NSDP ដើម្បីកាត់បន្ថយឱ្យតិចបំផុតនូវគ្រោះថ្នាក់នៃបណ្តាសាធនធាន និងបង្កើនឱកាសទទួលបាន ពរឱ្យកើនខ្ពស់បំផុត ។ លទ្ធផលជាដំបូងៗនៃការស្រាវជ្រាវឧបត្ថម្ភដោយ UNDP ក្នុងកិច្ចសហការជាមួយ SNEC CNPA និងវិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (Overseas Development Institute) បានជួយបំភ្លឺយ៉ាងច្រើន[11] ។

ការរកឃើញទាំងនេះ ដែលបានមកពីការគណនាសាកល្បងបែបបរិមាណពីកំណើនសេដ្ឋកិច្ចកម្ពុជានៅក្រោមសេណារីយ៉ូ (O&G) ខុសៗគ្នា បង្ហាញថា វិធីសក្តិសិទ្ធិបំផុតដើម្បីកាត់បន្ថយឱកាសកើតជំងឺហូឡង់ និងបណ្តាសាធនធាន គឺត្រូវវិនិយោគមួយចំណែកធំនៃចំណូលពី O&G ទៅលើការអភិវឌ្ឍន៍ជនបទ ជាពិសេសការអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈការកែលំអការអប់រំជាមូលដ្ឋាន ការបណ្តុះបណ្តាល និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ព្រមទាំង ហេដ្ឋារចនាសម្ព័ន្ធជនបទ ជាពិសេស អគ្គិសនី ផ្លូវ និងប្រព័ន្ធស្រោចស្រព ។ តំរូវការចាំបាច់ទាំងនេះ កើតឡើងដោយសារការប្រើប្រាស់មូលធនកំរិតទាបនៅតំបន់ជនបទភាគច្រើននាបច្ចុប្បន្ន ។ វិនិយោគលើធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធនៅជនបទបែបនេះ ក៏ប្រហែលជាអាចផ្តល់ដែនសកម្មភាពទូលាយជាងមុន សំរាប់ធ្វើចំរុះកម្មសេដ្ឋកិច្ច បង្កើតការងារនិងចំណូលនៅក្នុងវិស័យកសិកម្ម/ផលិតកម្ម និងរក្សាឱ្យមានកំណើនល្អក្នុងរយៈពេលវែង ។

ម៉្យាងទៀត ការគណនាសាកល្បងបែបបរិមាណ ក៏បង្ហាញផងដែរពីផលប៉ះពាល់វិជ្ជមានយ៉ាងច្រើនទៅលើសូចនាករសមធម៌ ហើយតាមរយៈនេះ វាជួយជំរុញដល់ស្ថិរភាពសង្គមក្នុងរយៈពេលវែង ។

ផ្ទុយទៅវិញ ឱកាសកើតជំងឺហូឡង់ និងការបាត់បង់សមត្ថភាពប្រកួតប្រជែងក្នុងវិស័យកសិកម្ម/ផលិតកម្ម ប្រហែលនឹងកើតមានឡើង ដោយសារទៅអនាគត គឺមានភាគរយនៃចំណូលកាន់តែច្រើននឹងត្រូវបានទៅដល់តំបន់ទីក្រុង ។ ក្នុងសេណារីយ៉ូនេះ សូចនាករសមធម៌ប្រហែលជានឹងធ្លាក់ចុះយ៉ាងលឿន ដែលជាសញ្ញាមិនល្អសំរាប់ស្ថិរភាពសង្គម និងសុខមាលភាពប្រជាជន ។ សេណារីយ៉ូនេះ ក៏ច្រើនតែធ្វើឱ្យធ្ងន់ធ្ងរថែមទៀត នូវការប្រមូលផ្តុំដីធ្លីកំរិតខ្ពស់ និងវិសមភាពផ្សេងៗដែលជាប់ពាក់ព័ន្ធ ។

ការគណនាសាកល្បងពីដំបូងៗបង្ហាញថា ការធ្វើឱ្យមានតុល្យភាពប្រកបដោយសុវត្ថិភាពរវាងចំណាយប្រើប្រាស់ និងចំណាយវិនិយោគ មានសារៈសំខាន់បំផុត ។ ឥទ្ធិពលជំងឺហូឡង់ នឹងកើនឡើងយ៉ាងគំហុក នៅពេលមានភាគរយកាន់តែធំឡើងនៃចំណូលថ្មីៗ ត្រូវបានយកទៅប្រើក្នុងចំណាយប្រើប្រាស់ ។ វាមានផលប៉ះពាល់អវិជ្ជមានជាពិសេសទៅលើវិនិយោគ និងសមត្ថភាពប្រកួតប្រជែងរបស់វិស័យឯកជន ហើយការនាំចូលនឹងកើនដល់កំរិតគ្មានចីរភាព ។

យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល និង NSDP បានសង្កត់ធ្ងន់លើការអភិវឌ្ឍន៍ជនបទ និងការសំរេចបាន CMDGs ។ ដោយសារ NSDP មិនបានគិតបញ្ចូលនូវលទ្ធភាពទទួលបានចំណូលដ៏ច្រើនពី O&G ដូច្នេះការទទួលចំណូលជាក់ស្តែង អាចធ្វើឱ្យសេណារីយ៉ូនៃ NSDP+ អាចជួយជំរុញកំណើននិងការកាត់បន្ថយភាពក្រីក្រនៅជនបទកាន់តែលឿន ព្រមទាំងការរីកចំរើនកាន់តែលឿនឈានទៅសំរេច CMDGs ដទៃទៀត ។

សរុបមក ការប្រើប្រាស់ចំណូលពី O&G ដើម្បីធ្វើវិនិយោគច្រើនៗទៅលើប្រជាជនជនបទ និងហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយគួបផ្សំនឹងកំណែទំរង់អភិបាលកិច្ច វាអាចជាវិធីដ៏សក្តិសិទ្ធិបំផុត សំរាប់បញ្ចៀសបណ្តាសាធនធាន ព្រមទាំងជួយធានាថា ចក្ខុវិស័យសំរាប់ប្រទេសកម្ពុជានិងប្រជាជន នឹងកាន់តែភ្លឺថ្លាឡើងនៅប៉ុន្មានទសវត្សរ៍ខាងមុខ ។

## កំណត់សំគាល់

១. ការគណនាផ្អែកលើថ្លៃប្រេងពិភពលោក ៦០ដុល្លារ/ធុង និងចំណាយលើការបូមយក ២០ដុល្លារ/ធុង ហើយ ៦០% នៃចំណូលដុល ត្រូវបានទៅរដ្ឋាភិបាល ដោយផ្អែកលើរូបមន្តក្នុងកិច្ចព្រមព្រៀងស្តីពីការបែងចែកផលិតផលជាមួយក្រុមហ៊ុន Chevron ។ រីឯតំបន់ B, C, D និង F វាអាចផ្តល់ចំណូលថែមទៀតនាពេលអនាគត ។

២. ប្រសិនបើយកតួលេខប៉ាន់ស្មានជាដំបូងៗនៃឧស្ម័នធម្មជាតិនៅតំបន់ A (ប្រហែលមាន 3-5 trillion cubic feet រឺ ១០០-១៥០ពាន់លានម៉ែត្រគូប) មកបូកបញ្ចូលផង ក្នុងមួយឆ្នាំៗរដ្ឋាភិបាលអាចបានចំណូលដល់ ៣៥០លានដុល្លារ តាមកិច្ចសន្យាបែងចែកផលិតផលជាមួយក្រុមហ៊ុន Chevron ជាបន្ថែមទៅលើលទ្ធផលហិរញ្ញវត្ថុដែលបញ្ជាក់នៅខាងលើនោះទៀត ។

៣. ពាក្យថា *បណ្តាសាធនធាន* ត្រូវបានកំណត់ថាជា "អភូតហេតុមួយដែលប្រទេសនាំមុខដោយវិស័យនាំចេញធនធានធម្មជាតិ បង្កើតបានចំណូលយ៉ាងច្រើនសំរាប់រដ្ឋាភិបាល តែបែរជានាំឱ្យសេដ្ឋកិច្ចមានភាពទ្រឹង និងពេលខ្លះឈានដល់អស្ថិរភាពខាងនយោបាយ" ។ បណ្តាសាធនធាន អាចមានធាតុផ្សំផ្សេងៗ រួមទាំងអត្រាប្តូរប្រាក់ពិតឡើងតំលៃខ្ពស់ពេក ហេតុនេះ ធ្វើឱ្យធ្លាក់ចុះសមត្ថភាពប្រកួតប្រជែងក្នុងវិស័យមិនមែនធនធាន ជាពិសេសវិស័យកសិកម្ម និងឧស្សាហកម្មផលិត និងបង្កជាការខ្ជះខ្ជាយ អំពើពុករលួយ/ការកេងប្រវ័ញ្ច និងកាត់បន្ថយគ្រឿងលើកទឹកចិត្តដល់ការបំពេញគណនេយ្យភាពរបស់អាជ្ញាធរចំពោះពលរដ្ឋ ។

៤. ឧទាហរណ៍គួរឱ្យចាប់អារម្មណ៍បំផុត គឺប្រទេសខ្សត់ O&M នៅអាស៊ីជាច្រើន ជាប្រទេសអ្នកមាន រីឯប្រទេសសំបូរ O&M ជាច្រើននៅអាមេរិកឡាទីន និងអាហ្វ្រិក ជាប្រទេសក្រីក្របំផុត និងជំពាក់បំណុលច្រើនជាងគេនៅលើពិភពលោក ។ ប្រទេសដែលល្បីល្បាញថាបានទទួលបណ្តាសាធនធាន មានជាអាទិ នីហ្សេរីយ៉ា អង់ហ្គោឡា លីបេរីយ៉ា, Sierra Leone, Equatorial Guinea, អេក្វាទ័រ វ៉េនេហ្ស៊ុយអេឡា ទ្រីនីដាតនិងតូបាហ្គោ (ថ្មីៗនេះ) Kazakhtan, former Zaire, ហ្វីលីពីន នៅទសវត្សរ៍១៩៧០-៨០ និងប្រទេសជាច្រើនទៀត ។

៥. ឧទាហរណ៍លើកឡើងជាញឹកញាប់ទាក់ទងទៅនឹងចំណុចនេះ រួមមានរបបដឹកនាំពីមុនៗ នៅប្រទេសនីហ្សេរីយ៉ា លីបេរីយ៉ា Sierra Leone និង former Zaire ។

៦. "ជំងឺហូឡង់" គឺការឡើងថ្លៃពិតខ្ពស់ពេកនៃរូបិយវត្ថុជាតិ និងការបាត់បង់សមត្ថភាពប្រកួតប្រជែងនៅក្នុងវិស័យពាណិជ្ជកម្មមិនមែនប្រេងកាត ជាពិសេស កសិកម្ម និងឧស្សាហកម្មផលិត ធ្វើឱ្យមូលដ្ឋានសកម្មភាពសេដ្ឋកិច្ចរួមតូច ភាពអត់ការងារធ្វើកើនឡើង និងចំណូលថយចុះ ។ ការថយចុះចំរុះកម្មសេដ្ឋកិច្ច និងកំណើនការពឹងផ្អែកលើវិស័យវត្ថុធាតុដើម

ធ្វើឱ្យប្រទេសងាយមានអស្ថិរភាពសេដ្ឋកិច្ច ដោយសារតែអស្ថិរភាពនៃទីផ្សារវត្ថុធាតុដើមជាក់លាក់ណាមួយដែលជាប់ទាក់ទិន ។

៧. ប្រទេសល្បីឈ្មោះជាងគេថាបានទទួលពរ គឺ ន័រវែស កាណាដា (Alberta) សហរដ្ឋអាមេរិក (Alaska) អូស្ត្រាលី ស៊ីលី និងបូស្វាណា ។ ប្រទេស Timor-Leste គេលើកឡើងជារឿយៗថា ជាប្រទេសកំពុងអភិវឌ្ឍន៍ដែលបានកសាងវិធីសាស្ត្រចាត់ចែងឧស្ម័ននៅបាតសមុទ្ររបស់ខ្លួន ដោយផ្អែកលើមេរៀនដែលប្រទេសផ្សេងៗរៀនសូត្របានក្នុង ៤0ឆ្នាំកន្លងទៅ ហើយអាចក្លាយជាគំរូសំរាប់ប្រទេសកម្ពុជា ។

៨. មាត្រា៥៩ នៃរដ្ឋធម្មនុញ្ញចែងថា រដ្ឋនឹងបង្កើតផែនការច្បាស់លាស់សំរាប់ការគ្រប់គ្រងធនធាន ដូចជា O&G ដើម្បីលើកស្ទួយសុខមាលភាព និងកំរិតជីវភាពរបស់ប្រជាជន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ហើយអំណាចទាំងនេះត្រូវបានប្រើប្រាស់តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រដ្ឋាភិបាល និងតុលាការ ។

៩. រាជរដ្ឋាភិបាលកម្ពុជា បានផ្ដួចផ្ដើមទំនាក់ទំនងការងារជាមួយកម្មវិធីតំលាភាពឧស្សាហកម្មយករ៉ែ (Extractive Industry Transparency Initiative: EITI) ដើម្បីជួយដល់ដំណើរការនេះ ។

១0.ឧទាហរណ៍: ទោះបីពីដំបូងគេយកពាក់កណ្ដាលនៃចំណូល ១,៧ពាន់លានដុល្លារ/ឆ្នាំ ដែលបានបញ្ជាក់ហើយ ទៅដំកល់ក្នុងមូលនិធិប្រេងកាតដែលរចនាតាក់តែងបានល្អនិងមានតំលាភាព (ដូចនៅប្រទេសសំបូរប្រេងមួយចំនួនដែលមានជោគជ័យ) គេនៅសល់ 0,៨៥ពាន់លានដុល្លារទៀតសំរាប់បើកផ្ដល់ទៅក្នុងថវិការដ្ឋ ។ រឿងនេះនឹងធ្វើឱ្យចំណូល និងចំណាយថវិកាចរន្តកើនឡើងមួយជាពីរ ហើយគេអាចចំណាយច្រើនជាងមុនជិត ៤ដងទៅលើវិស័យសុខាភិបាល និងអប់រំ ព្រមទាំងអាចបង្កើនខ្ទង់ចំណាយឯទៀតទាំងអស់ផង ។ ទន្ទឹមគ្នានេះ ទឹកប្រាក់ដំកល់នៅក្នុងមូលនិធិប្រេងកាត នឹងបន្តកើនឡើងដោយផ្ដល់ផលចំណេញតាមអត្រាទាញចំណូលអន្តរជាតិមួយយ៉ាងប្រសើរ ដែលអនុញ្ញាតឱ្យគេធ្វើការកែលំអនៅ ក្នុងវិស័យសុខាភិបាល និងអប់រំជាបន្តទៀត ហួសពីពេលដែលធនធានប្រេងកាតត្រូវបានបូមរលោះអស់ទៅ ដូច្នេះអាចធានាបាននូវស្ថិរភាព សេដ្ឋកិច្ច-សង្គមកិច្ច និងសុវត្ថិភាពខាងហិរញ្ញវត្ថុ ។

១១.យោងតាមតំរូវការរៀបចំផែនការឱ្យបានយូរពេលជាមុន និងត្រៀមជាស្រេចសំរាប់លទ្ធភាពច្រើនបែបយ៉ាង ការស្រាវជ្រាវនេះមានគោលដៅគណនាបរិមាណ និងបង្កើនផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ចសំរាប់កម្ពុជា ផ្អែកលើសេណារីយ៉ូមួយចំនួន ដោយប្រើគំរូលំនឹងទូទៅអាចគណនាបាននៃសេដ្ឋកិច្ច (Computable general equilibrium model of the economy) ។ សេចក្ដីព្រាងពីការរកឃើញក្នុងការស្រាវជ្រាវ នឹងចេញផ្សាយនៅប៉ុន្មានខែខាងមុខសំរាប់ការពិភាក្សា និងកែតំរូវ ។

# ជៀសវាងបណ្ដាសាធនធាន: ការគ្រប់គ្រងឧស្សាហកម្មយករ៉ែនៅកម្ពុជា

*បទបង្ហាញរបស់ ឯ.ឧ.* ***Joseph A. Mussomeli*** *ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា*

ឯកឧត្ដម អស់លោក លោកស្រី !

ខ្ញុំសូមអរគុណចំពោះការអនុញ្ញាតឱ្យខ្ញុំបានចូលរួមក្នុងក្រុមឧទ្ទេសនាមនេះ ។ កិច្ចប្រជុំស្ដីពីការគ្រប់គ្រងប្រេងកាត និងឧស្ម័នធម្មជាតិរបស់កម្ពុជា គឺពិតជាត្រូវចំពេលល្អណាស់ ។ ក្នុងរយៈពេលពាឆ្នាំទៀត ឧស្សាហកម្មយករ៉ែនៅកម្ពុជា (ប្រេងកាត ឧស្ម័ន និងរ៉ែផ្សេងទៀត) អាចធ្វើឱ្យចំណូលប្រចាំឆ្នាំរបស់រដ្ឋកើនលើសពី មួយជាបី ទៅទៀត ។

ការសិក្សាមួយរបស់ UNDP បានបង្ហាញថា នៅថ្ងៃខាងមុខ ប្រាក់ចំណូលពីប្រេងកាតតែមួយមុខ អាចបានច្រើនជាងបីដងនៃជំនួយអភិវឌ្ឍន៍ផ្លូវការដែលកម្ពុជាបានទទួលនៅឆ្នាំ២០០៥ ទៅទៀត ។

រឿងនេះគួរជាព័ត៌មានដ៏អស្ចារ្យហើយ ។ ជាការពិតណាស់ សំរាប់ប្រទេសក្រីក្រមួយចំនួន ឧស្សាហកម្មយករ៉ែ ជាអ្នកសង្គ្រោះសេដ្ឋកិច្ច ដោយជួយរំដោះប្រទេសចេញពីភាពក្រីក្រដែលហាក់ដូចជាទ័លច្រកទៅហើយ ហើយសំរាប់កម្ពុជា វាក៏អាចជាអ្នកសង្គ្រោះសេដ្ឋកិច្ចដែរ ។ ប៉ុន្តែអនាគតបែបនេះ នៅមិនទាន់ច្បាស់លាស់ទេ ។ តាមឆាកជីវិតរបស់យើងផ្ទាល់ យើងទាំងអស់គ្នាអាចដឹងថា ពរជាច្រើនដែលហាក់មើលឃើញទៅហើយ អាចប្រែក្លាយទៅជាបណ្ដាសាវិញ ។ នៅប្រទេសអាមេរិក គ្មានឆ្នាំណាមួយដែលគ្មានការចុះផ្សាយព័ត៌មាន ពីមនុស្សមួយចំនួនមានសំណាងល្អឈ្នះឆ្នោតបានរាប់លានដុល្លារ ប៉ុន្តែនៅទីបញ្ចប់បែរជាធ្លាក់ខ្លួនរឹតតែក្រ និងរឹតតែពិបាកចិត្តជាងកាលពីមុននោះទៀត ។ ភោគទ្រព្យមកដល់ភ្លាមៗ ក៏ពិបាកដោះស្រាយដូចសោកនាដកម្មភ្លាមៗដែរ ។ នៅប្រទេសជាច្រើន ភោគទ្រព្យបានពីការជីកយកធនធានគឺជាបណ្ដាសាគួរឱ្យតក់ស្លុត ដែលធ្វើឱ្យប្រជាជនកាន់តែក្រទៅៗ រីឯអ្នកមានអំណាចពុករលួយមួយចំនួនតូច បែរជាបូមយកចំណូល ដែលគួរយកទៅប្រើប្រាស់ដើម្បីលើកស្ទួយសុខមាលភាពរបស់ប្រជាជនទៅវិញ ។ ដល់យូរៗទៅ អំពើពុករលួយ និងកំណើនគំលាតរវាងអ្នកមាន និងអ្នកគ្មាន វានឹងបង្កដោយជៀសមិនផុតនូវចលាចលក្នុងសង្គម អស្ថិរភាពនយោបាយ និងទំនាស់ហិង្សា ។

តើកម្ពុជាត្រូវធ្វើអន្តរកាលយ៉ាងណា ដើម្បីឈានពីស្ថានភាពពឹងផ្អែកលើជំនួយទៅជាប្រទេសសំបូរធនធាន? តើកម្ពុជានឹងអាចបង្កើនភោគទ្រព្យ បានច្រើនជាអតិបរមា ហើយជំរុះចោលខ្នោះឃ្នាងខាងសង្គមកិច្ច នយោបាយ និងចិត្តសាស្ត្របន្សល់ពីរបបប៉ុលពតដែររឺទេ? តើកម្ពុជាអាចនឹងក្លាយជានាគអាស៊ីនៅសតវត្សរ៍ទី២១ដែររឺទេ ដោយអនុវត្តបាននូវរបៀបរបបអន្តរជាតិដ៏ប្រសើរបំផុត ក្នុងពេលដែលត្រូវបន្តដំណើរនៅលើមាគ៌ារបស់ខ្លួនផ្ទាល់ ដើម្បីឈានទៅរកការរីកចំរើនសេដ្ឋកិច្ច និងស្ថិរភាពនយោបាយ? ចំពោះសំនួរទាំងនេះ ដើម្បីទទួលបានចំលើយ "វិជ្ជមាន" កម្ពុជាត្រូវការឆន្ទៈខាងនយោបាយជាងអ្វីៗទាំងអស់ ។ ឆន្ទៈល្អ ការធ្វើផែនការ និងការបណ្ដុះបណ្ដាល ទាំងអស់មិនអាចជួយឱ្យកម្ពុជាសំរេចបានអ្វីទេ ប្រសិនបើអ្នកដឹកនាំខ្វះឆន្ទៈនយោបាយ ដើម្បីទាមទារឱ្យគេយកប្រាក់ចំណូលបានពីឧស្សាហកម្មយករ៉ែ ទៅប្រើប្រាស់តែសំរាប់ធ្វើឱ្យប្រទេសជាតិបានល្អប្រសើរឡើង ។ ក្នុងសុន្ទរកថាដ៏ចំហ និងក្បោះក្បាយកាលពីថ្ងៃទី២២ កុម្ភៈ ២០០៧ សម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានបង្ហាញពីបំណងចង់ឱ្យមានឆន្ទៈនយោបាយបែបនេះ ។ អ្នកត្រូវតែកសាងក្របខ័ណ្ឌគោលនយោបាយមានតំលាភាព និងបង្កើតរចនាសម្ព័ន្ធស្ថាប័នឱ្យបានសព្វគ្រប់ ដើម្បីទប់ស្កាត់ការប្រើប្រាស់ប្រាក់ចំណូលមិនបានត្រឹមត្រូវពីសំណាក់ជនណាមួយ ទោះមានអំណាចប៉ុណ្ណាក៏ដោយ ។

មុននឹងផ្ដល់អនុសាសន៍ខាងគោលនយោបាយដ៏ជាក់លាក់ ខ្ញុំសូមគូស

រំលេចពីគ្រោះថ្នាក់នៃបណ្តាសាធនធានដែលប្រទេសជាច្រើនបានជួបប្រទះ ។ ផ្ទុយពីការរំពឹងទុក ការរកឃើញធនធានធម្មជាតិដ៏សម្បូរ មិនមែនសុទ្ធតែនាំឱ្យមានកំណើនសេដ្ឋកិច្ច/សង្គមកិច្ចនោះទេ ហើយនៅប្រទេសមួយចំនួនប្រជាជនជាទូទៅរឹតតែក្រថែមទៀត បន្ទាប់ពីទទួលបានចំណូលពីប្រេងកាតអស់រយៈ៣០ឆ្នាំមក ។ បណ្តាសាចាប់ផ្តើមឡើងនៅពេលដែល "អ្នកតថ្លៃ" របស់រដ្ឋាភិបាល មិនទទួលបានថ្លៃខ្ពស់ពី ធនធានធម្មជាតិដែលមិនកកើតឡើងវិញ។ អ្នកទាំងនោះ តាមធម្មតាច្រើនប្រើប្រាស់ដំណើរការគ្មានតំលាភាពដែលផ្តោតលើភោគទ្រព្យក្នុងរយៈពេលខ្លី ជាជាងការអភិវឌ្ឍន៍ជាតិ នៅក្នុងរយៈពេលវែង ។ ពួកគេច្រើនតែមានការយល់ដឹងខាងបច្ចេកទេសតិចតួចពីភាពស្មុគស្មាញនៃអាជីវកម្ម និងរបៀបរបបនៅក្នុងស្យាហកម្មយករ៉ែ ។

ជួនកាល រដ្ឋាភិបាលមិនបានធ្វើផែនការសំរាប់ចំណូលយ៉ាងគំហុតចៀសមិនរួចពាក់ព័ន្ធនឹងការឡើងចុះថ្លៃប្រេង ឧស្ម័ន និងរ៉ែផ្សេងៗ លើពិភពលោកទេ ។ ជារឿយៗ រដ្ឋាភិបាលនៅតែពឹងផ្អែកលើស្ថាប័នហិរញ្ញវត្ថុដែលផ្តល់កំចីសំរាប់រ៉ាប់រងកង្វះថវិកា ហើយអាចឈានដល់ការជំពាក់បំណុលច្រើនហួសហេតុ និងអតិផរណាខ្ពស់ពេក ។

ចំណុចធ្ងន់ធ្ងរបំផុតគឺ ប្រទេសមួយចំនួនបានធ្វើការសំរេចចិត្តសាមញ្ញពេកក្នុងការប្រើប្រាស់អតិរេកធនធាន ដើម្បីបន្ធូរវិន័យខាងសារពើពន្ធ ។ គឺដូចជាកុមារដែលមិនធ្លាប់គិតអ្វីសោះពី ផលវិបាករយៈពេលវែងនៃជំរើសរបស់ខ្លួន ប្រទេសទាំងនោះធ្វើហាក់ដូចជាប្រាក់ចំណូលមិនចេះរីងស្ងួតសោះ ហើយពួកគេមិនចាំបាច់ធ្វើសកម្មភាពប្រកបដោយទំនួលខុសត្រូវឡើយ ។ នៅទីបំផុតសេដ្ឋកិច្ចក៏វិលវល់ធ្លាក់ចុះ ដោយសារកំណើនចំណាយប្រើប្រាស់សាធារណៈវាខ្លាំងជាងការបង្កើនចំណាយជួយផលិតកម្មក្នុងស្រុក ហើយក៏បង្កអតិផរណាក្នុងស្រុក និងការខូចខាតដល់វិស័យផលិតកម្មក្នុងសេដ្ឋកិច្ច ។

តើរឿងនេះមានអត្ថន័យយ៉ាងដូចម្តេច ចំពោះស្ថានភាពនៅកម្ពុជា? អតិផរណាអាចនាំឱ្យចំណាយអស់កាន់តែច្រើន ដើម្បីផលិតបានផលកសិកម្ម និងផលិតផលផ្សេងទៀតនៅកម្ពុជា ដូច្នេះត្រូវថយចុះកំលាំងប្រកួតប្រជែង នៅក្នុងទីផ្សារពិភពលោក ។ សរុបមក ប្រសិនបើប្រាក់ចំណូលបានពីឧស្សាហកម្មយករ៉ែគ្មានការគ្រប់គ្រងសមស្របទេ ឧស្សាហកម្មកាត់ដេរកម្ពុជា ដែលប្រើកម្មករ ៣៣៤.០០០នាក់ និងទទួលប្រាក់ឈ្នួល ២៩២លានដុល្លារ/ឆ្នាំ ហើយនាំចេញបាន ២,៦ពាន់លានដុល្លារនៅឆ្នាំ២០០៦ នឹងត្រូវខូចខាត ហើយទីបំផុតនឹងដួលរលំ ។ នេះជាសេណារីយ៉ូមិនល្អមួយដែលអាចចៀសវាងបាន ។ នៅមានជាច្រើននាក់ក្នុងជួររដ្ឋាភិបាលកម្ពុជាដែលបានទទួលស្គាល់ និងកំពុងធ្វើការងារ ដើម្បីគ្រប់គ្រងដោយមានទំនួលខុសត្រូវខ្ពស់នូវឧស្សាហកម្មរ៉ែនៅប្រទេសកម្ពុជាយើង ។

សហគមន៍ពិភពលោក បានទទួលបទពិសោធន៍ល្អៗជាច្រើននៅប៉ុន្មានទសវត្សរ៍ចុងក្រោយ ពីរបៀបគ្រប់គ្រងហានិភ័យ និងទទួលបានរង្វាន់ល្អពីការអភិវឌ្ឍន៍ប្រេង ឧស្ម័ន និងរ៉ែផ្សេងទៀត ។ កម្ពុជាក៏មានឱកាសរៀនសូត្រពីបរាជ័យរបស់ប្រទេសខ្លះ និងពង្រីកបទពិសោធន៍មានជោគជ័យរបស់ប្រទេសឯទៀត ។

## យើងសូមផ្តល់អនុសាសន៍ខាងគោលនយោបាយដូចតទៅសំរាប់ជាការពិចារណា:

១) យើងអបអរសាទររដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់លើកម្មវិធីតំលាភាពឧស្សាហកម្មយករ៉ែ (EITI) ហើយសង្ឃឹមថា ក្នុងពេលឆាប់ៗ កម្ពុជានឹងក្លាយជាប្រទេសអនុវត្តកម្មវិធីនេះ ។ នេះជាជំហានគួរឱ្យត្រេកអរមួយដែលបង្ហាញពីការតាំងចិត្តរបស់រដ្ឋាភិបាល ដើម្បីបង្កើតតំលាភាពក្នុងប្រព័ន្ធចុះកិច្ចសន្យាខាងឧស្សាហកម្មយករ៉ែ ។

២) រដ្ឋាភិបាលគួរកែលំអច្បាប់ និងបទបញ្ញត្តិផ្សេងៗទាក់ទងនឹងការផ្តល់ព័ត៌មាន និងការត្រួតពិនិត្យលើប្រាក់ចំណូលជាតិ ដើម្បីធានាឱ្យប្រាក់ចំណូលពីឧស្សាហកម្មរ៉ែ មានការតាមដានមើល និងបែងចែកជាចំហ សំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

៣) រាជរដ្ឋាភិបាលកម្ពុជាគួរពិនិត្យឡើងវិញ ពីគោលនយោបាយគ្រប់គ្រងប្រាក់ចំណូល ។ គោលនយោបាយទាំងនោះ គួរឆ្លើយតបនឹងសំនួរសំខាន់ៗ ដូចជា "ត្រូវចំណាយអ្វី" "ត្រូវសន្សំអ្វី" និង "នៅពេលណា" ។ តើចំណូលត្រូវហូរចូលរតនាគារតាមវិធានអ្វី? តើកម្ពុជានឹងដើរតាមគំរូរបស់បណ្តាប្រទេសខាងជើង (Nordic countries) និងបង្កើតមូលនិធិប្រាក់សន្សំសំរាប់អ្នកជំនាន់ក្រោយរឺទេ? បើសិនធ្វើដូច្នេះ តើត្រូវបែងចែកប្រាក់ចំណូលប៉ុន្មានភាគរយទៅដោះស្រាយការចំណាយប្រចាំឆ្នាំ ដើម្បីជួយទ្រទ្រង់ប្រព័ន្ធអប់រំ ការថែទាំសុខភាព ហេដ្ឋារចនាសម្ព័ន្ធជនបទ កិច្ចការពារព្រៃត្រូពិច និងការអភិវឌ្ឍន៍ជាអាទិភាពផ្សេងទៀត?

៤) ការងាររដ្ឋាភិបាលដើម្បីកសាងច្បាប់ថ្មីស្តីពីប្រេងកាត គួរតែពន្លឿនឡើង ដើម្បីធានាឱ្យមានក្របខ័ណ្ឌច្បាប់មានប្រសិទ្ធភាព និងតំលាភាពល្អ ។

៥) សេចក្តីព្រាងវិសោធនកម្មសំរាប់ច្បាប់ស្តីពីសារពើពន្ធ ដែលមានចែងនូវបទប្បញ្ញត្តិយ៉ាងច្បាស់លាស់និងមានប្រសិទ្ធភាពស្តីពី ការយកពន្ធលើឧស្សាហកម្មប្រេងកាត គួរតែមានការអនុមតិ និងបញ្ជូនទៅសភាជាតិ ។ ដើម្បីអនុវត្តប្រព័ន្ធពន្ធដារកែសំរួលឡើងវិញនេះ នាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាំបាច់ត្រូវតែពង្រឹងបន្ថែម និងត្រូវមានអ្នកជំនាញឯកទេសខាងគ្រប់គ្រងពន្ធ លើឧស្សាហកម្មយករ៉ែ ។

៦) សភាជាតិគួរចាត់វិធានការជាបន្ទាន់ ដើម្បីបង្កើនសមត្ថភាពខ្លួនក្នុងការបំពេញតួនាទីពិនិត្យតាមដាន ដូចជា ការបង្កើតគណៈកម្មការអចិន្ត្រៃយ៍មួយដែលមានតួនាទីជាក់លាក់ ក្នុងការពិនិត្យតាមដានលំហូរចំណូលមកពីឧស្សាហកម្មយករ៉ែ ។

៧) រដ្ឋាភិបាលគួរពន្លឿនការអនុមតិច្បាប់ស្តីពីសេរីភាពក្នុងការទទួលបានព័ត៌មាន ដែលនឹងចងក្រងជាច្បាប់ នូវគោលការណ៍ប្រជាធិបតេយ្យជាមូលដ្ឋានតំរូវឱ្យរដ្ឋាភិបាលធ្វើការងាររបស់ខ្លួនតាម បែបបទមានតំលាភាពនិងបើកចំហ ដើម្បីឱ្យអ្នកដឹកនាំមានគណនេយ្យភាពលើការសំរេចចិត្ត និងសកម្មភាពរបស់ខ្លួន ។ម្យ៉ាងទៀត រដ្ឋាភិបាលគួរអនុម័តនិងអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ និងបង្កើតស្ថាប័នឯករាជ្យមួយ ដែលអាចស៊ើបអង្កេតពីអំពើពុករលួយផ្សេងៗ នៅតាមស្ថាប័នរដ្ឋាភិបាល ។

ជាទីបញ្ចប់ បន្ទាប់ពីបានរស់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេល១ឆ្នាំកន្លះមក ខ្ញុំបានពិនិត្យឃើញថា មានរឿងតិចតួចណាស់ដែលប្រជាជនកម្ពុជាឯកភាពតាមទាំងអស់គ្នា ។ ប៉ុន្តែមានរឿងពីរដែលពួកគេយល់ឃើញដូចគ្នាទាំងអស់ ដោយមិនគិតពីអាយុ គណបក្សនយោបាយ និងស្ថានភាពសេដ្ឋកិច្ចឡើយ ។ ទី១ ពួកគេលើកឡើងដោយមានមោទនភាព ពីអារ្យធម៌ខ្មែរដ៏រុងរឿង ដែលបានរីកសុះសាយកាលពីច្រើនសតវត្សរ៍មុន ។ ទី២ ពួកគេទាំងអស់តែងរំលឹកឡើងដោយអារម្មណ៍ពុះពោរថា កាលពី៥០ឆ្នាំមុន កម្ពុជាគឺជាគំរូដែលគេចង់បានគ្រប់គ្នានៅអាស៊ីអគ្នេយ៍ ជាប្រទេសដែលប្រជាជនមានការអប់រំខ្ពស់ មានសេវាថែទាំសុខភាពល្អ និងមានបរិយាកាសវប្បធម៌ដ៏រស់រវើក និងបើកទូលាយ ជាងប្រទេសនៅជិតខាងទាំងអស់ ។

*តទៅទំព័រទី ២២*

# បង្កើនល្បឿន ការកាត់បន្ថយភាពក្រីក្រ

*ថ្វីបើសំរេចបានកំនើនសេដ្ឋកិច្ចដ៏ខ្ពស់នៅទសវត្សរ៍មុន ប្រទេសកម្ពុជាដែលមានអត្រាភាពក្រីក្រដល់ទៅ ៣៥% នៅតែស្ថិតក្នុងចំណោមប្រទេសមានអត្រាក្រីក្រខ្ពស់ជាងគេនៅក្នុងតំបន់ ។ ប៉ុន្តែឥឡូវនេះ ដល់ពេលត្រូវពន្លឿនការកាត់បន្ថយភាពក្រីក្រហើយ ។ នៅក្នុងសន្និសីទចក្ខុវិស័យ រៀបចំដោយ វបសអ នាខែកុម្ភៈ ឆ្នាំ២០០៧ ក្រុមជំនាញការមួយដែលរួមមាន លោកស្រី* Nisha Agrawal *លោក ច័ន្ទ សុផល និងលោក ឈិត សំអាត បានពិភាក្សាពីវិធីកំណត់គោលដៅ និងពន្លឿនការកាត់បន្ថយភាពក្រីក្រ ។**

**បទបង្ហាញរបស់លោកស្រី Nisha Agrawal – ធនាគារពិភពលោក**

នៅឆ្នាំ១៩៩៤-២០០៤ កម្ពុជាបានទទួលជោគជ័យគួរឱ្យកត់សំគាល់ ។ កម្ពុជាសំរេចបានសន្តិភាព និងស្ថិរភាព បន្ទាប់ពីមានសង្គ្រាម និងភាពវឹកវរដ៏រ៉ាំរ៉ៃមក ។ ក្នុងអំឡុងពេលនោះ មានកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ប្រហែល ៧% ក្នុងមួយឆ្នាំ ។ ការកាត់បន្ថយភាពក្រីក្របានជឿនលឿនទៅមុខគួរសម ដោយអត្រាក្រីក្របានថយចុះពី ៤៧% មកត្រឹម ៣៥% រឺក្នុងមួយឆ្នាំៗនាទសវត្សរ៍នោះ មានប្រជាជនប្រមាណ ១% ថែមទៀត បានចាកផុតពីភាពក្រីក្រ ។ ម្យ៉ាងទៀត សូចនាករសង្គមបានប្រសើរឡើងជាទូទៅ ពិសេសក្នុងវិស័យសុខាភិបាល និងអប់រំ ។

ទន្ទឹមគ្នានឹងជោគជ័យខាងលើ វិសមភាពក៏កើនឡើងដែរ ។ វិសមភាពរវាងអ្នកមាន និងអ្នកក្រ បានកើនឡើងយ៉ាងគំហុកនៅទសវត្សរ៍ចុងក្រោយ ។ កំរិតជីវភាពរស់នៅរបស់អ្នកមានជាងគេ ២០% បានកើន ៥ដង លឿនជាងកំរិតជីវភាពរបស់អ្នកក្រជាងគេ ២០% ដោយមានកំនើន ៤៥% ធៀបនឹង ៨% ។ ម្យ៉ាងទៀត មានគំលាតកើនរវាងតំបន់នានា ហើយភាពក្រីក្រកាន់តែធ្ងន់ធ្ងរនៅជនបទ ។ ចំនួនប្រជាជនក្រីក្រ បានថយចុះយ៉ាងលឿននៅភ្នំពេញ និងនៅតំបន់មាត់សមុទ្រ បើធៀបនឹងតំបន់ផ្សេងទៀត ។ ធៀបនឹងប្រទេសជិតខាង វិសមភាពនៅកម្ពុជាមានកំរិតខ្ពស់គឺ ០,៤២ នៅឆ្នាំ២០០៤ រីឯនៅវៀតណាម មានត្រឹមតែ ០,៣៥ នៅឆ្នាំ២០០២ ឥណ្ឌូនេស៊ី មាន ០,៣៤ នៅឆ្នាំ២០០០ ។ល។

ចំពោះអ្នកនយោបាយ វិសមភាពក៏ជាបញ្ហាសំខាន់ដែរ ។ នៅក្នុងសុន្ទរកថានៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា នៅកម្ពុជាយើងត្រូវប្រឈមមុខនឹងបញ្ហាច្រើនណាស់ ដែលអាចកាត់បន្ថយស្ថិរភាពនយោបាយ និងសង្គម ។ បញ្ហាទាំងនេះ រួមមានកំណើនទំនាស់ដីធ្លី សំពាធ និងការរុករានរបស់មនុស្សទៅលើធនធានធម្មជាតិ មូលដ្ឋានតូចចង្អៀតនៃកំណើនសេដ្ឋកិច្ច និងកំណើនវិសមភាព ដូច្នេះត្រូវមានការបែងចែកឡើងវិញនូវផ្លែផ្កានៃកំណើនសេដ្ឋកិច្ច ដើម្បីបង្កើនអត្ថប្រយោជន៍ដល់អ្នកក្រ ។ ហានិភ័យ និងបញ្ហាប្រឈមទាំងនេះ គួរបំប្លែងឱ្យទៅជាឱកាសល្អវិញ ។

*នរណាជាអ្នកក្រជាងគេ ២០%?*

អ្នកក្រជាងគេ ២០% កំពុងស្ថិតនៅខាងក្រោមខ្សែបន្ទាត់ក្រីក្រ ហើយភាគច្រើនរស់នៅតាមវាលទំនាបក្នុងតំបន់ជនបទ តាមដងទន្លេសាប តាមតំបន់ភ្នំ និងខ្ពង់រាប ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើកសិកម្មនិងធនធានទ្រព្យរួម ដូច្នេះងាយរងគ្រោះណាស់ ពីព្រោះវត្តមាន និងការទទួលបានធនធានទាំងនោះ បានថយចុះ ។ ពួកគេ ក៏មានលទ្ធភាពតិចតួចដើម្បីបានប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាដ៏ចាំបាច់នានា ។

*សកម្មភាពបីសំខាន់ៗ ដើម្បីទទួលបានវិបុលភាពរួម*

សកម្មភាពដ៏សំខាន់បំផុតមួយដើម្បីទទួលបានវិបុលភាពរួម គឺការបង្កើនលទ្ធភាពមានដីប្រើប្រាស់ និងសន្តិសុខក្នុងការកាន់កាប់ដីធ្លី សំរាប់ប្រជាជនក្រីក្រនៅជនបទ ។ រដ្ឋាភិបាលកម្ពុជា បានដាក់អនុវត្តរបបសម្បទានដីបំរើសេដ្ឋកិច្ច (ELCs) ដោយពីឆ្នាំ១៩៩២-២០០៦ បានផ្តល់ដីបែបនេះក្រោមលក្ខខណ្ឌជួលរយៈពេល៧០ឆ្នាំ នៅក្នុង១៦ខេត្ត ទៅឱ្យ ៩៦ក្រុមហ៊ុនឯកជន ដែលក្នុងនោះមាន ៥៧ក្រុមហ៊ុន នៅមានដំណើរការ (មិនទាន់លុបចោល) លើដីសម្បទានប្រហែល ១លានហិកតា ។ ដោយឡែក មាន ១៤សម្បទាន ដែលនីមួយៗមានផ្ទៃដីលើសកំរិតកំណត់ ១០.០០០ហិកតា ហើយដែលត្រូវធ្វើការត្រួតពិនិត្យជាពិសេសឡើងវិញ ។ ប៉ុន្តែមកទល់សព្វថ្ងៃ មិនទាន់មានការត្រួតពិនិត្យណាមួយនៅឡើយទេ ។ ទោះបីមានហេតុផលខាងគោលនយោបាយថា ELCs ជាការចាំបាច់សំរាប់ជំរុញផលិតភាព កំណើន និងការប្រកួតប្រជែង ក៏បច្ចុប្បន្នមានតែ ១០ របបសម្បទានដីបំរើសេដ្ឋកិច្ចដែលកំពុងដំណើរការជាក់ស្តែង ។ ចំពោះសម្បទានក្រៅពីនោះ គេទុកដីឱ្យនៅទំនេរចោលដោយរង់ចាំកេងយកចំណេញពីការឡើងថ្លៃ ។ ដូច្នេះមានសំនួរចោទឡើងថា តើនេះជាវិធីប្រសើរបំផុតក្នុងការប្រើប្រាស់ដីនៅកម្ពុជារឺយ៉ាងណា?

នៅពេលដែលដីកសិកម្មធំៗ នៅទំនេរក្រោមរូបភាពជារបបសម្បទានដីបំរើសេដ្ឋកិច្ច (ELCs) គេឃើញមានតំរូវការខ្លាំងខាងសេដ្ឋកិច្ចនូវដីធ្លីសំរាប់អ្នកមានដីកសិកម្មតូចៗ និងសំរាប់សម្បទានដីសង្គមកិច្ច (SLCs) ។ គ្រួសារនៅជនបទ ២០% ជាអ្នកគ្មានដី និងមានគ្រួសារកាន់តែច្រើនបានក្លាយទៅជាអ្នកស្ទើរគ្មានដី រឺមានដីតូចៗ ។ យោងតាមអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចឆ្នាំ២០០៣ រដ្ឋាភិបាលមានគោលនយោបាយលុបចោលសម្បទានដីខាងសេដ្ឋកិច្ចដែលមិនដំណើរការ ហើយផ្ទេរដីទៅឱ្យគ្រួសារគ្មានដី ។ ការលៃចែកដីសាជាថ្មីនេះ មានហេតុផលច្បាស់លាស់ពាក់ព័ន្ធនឹងផលិតភាពសេដ្ឋកិច្ច កំណើន និងការកាត់បន្ថយភាពក្រីក្រ ។ ប៉ុន្តែការអនុវត្តន៍គោលនយោបាយសម្បទានដីសង្គមកិច្ចយឺតយ៉ាវខ្លាំងណាស់ ដូច្នេះត្រូវតែមានការពន្លឿនឡើង ។

សកម្មភាពសំខាន់មួយទៀត គឺការធ្វើចំរុះកម្មប្រភពកំណើនសព្វថ្ងៃ និងពង្រឹងចំណងទាក់ទងរវាងកំនើន និងការកាត់បន្ថយភាពក្រីក្រ ។ កំនើនសេដ្ឋកិច្ចនាបច្ចុប្បន្ន មានមូលដ្ឋានតូចណាស់ ដោយពឹងផ្អែកលើតែវិស័យកាត់ដេរ និងទេសចរណ៍ ។ វិស័យកាត់ដេរផ្តល់ការងារដល់កម្មករជាង ៣០០.០០០នាក់ នៅចុងឆ្នាំ២០០៦ និង ៨០% នៃទំនិញនាំចេញ ។ ការពឹងផ្អែកខ្លាំងចំពោះវិស័យតែមួយនាំឱ្យមានមូលដ្ឋានកំណើនតូចចង្អៀត ដែលងាយរងគ្រោះដោយសារការប៉ះទង្គិចពីខាងក្រៅ ។ វិស័យកាត់ដេរតែមួយ ក៏មិនគ្រប់គ្រាន់ដែរ ដោយសារជារៀងរាល់ឆ្នាំ មានប្រជាជន ២៥០.០០០នាក់ ឈានចូលទៅក្នុងទីផ្សារការងារ ។ ដូច្នេះត្រូវធ្វើចំរុះកម្មវិស័យផលិតដើម្បីបង្កើតការងារឱ្យបានច្រើនថែមទៀត ។

* លោកស្រី Nisha Agrawal ជាអ្នកគ្រប់គ្រងប្រចាំនៅកម្ពុជា នៃធនាគារពិភពលោក ។ លោក ច័ន្ទ សុផល ជាប្រធានស្រាវជ្រាវជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI និងលោក ឈិត សំអាត ជានាយកអង្គការ NGO Forum នៅកម្ពុជា ។

ចំណងទាក់ទងទៅខាងដើមខ្សែនៃវិស័យទេសចរណ៍ ត្រូវមានជាចាំបាច់ ដើម្បីធានាឱ្យកំណើនទេសចរណ៍ រួមចំណែកកាត់បន្ថយភាពក្រីក្រ ។ ក្នុង៥ឆ្នាំចុងក្រោយ វិស័យទេសចរណ៍មានកំណើនមធ្យម ២៦%/ឆ្នាំ ។ ភ្ញៀវទេសចរភាគច្រើន ទៅទស្សនាខេត្តសៀមរាប ។ ប៉ុន្តែសៀមរាបនៅតែស្ថិតក្នុងចំណោមខេត្តក្រីក្របំផុតនៅកម្ពុជា ។ ទេសចរណ៍មិនផ្តល់អត្ថប្រយោជន៍ច្រើនដល់អ្នកក្រទេ បើសិនគ្មានយុទ្ធសាស្ត្រជាក់លាក់ដែលផ្តោតលើផលប៉ះពាល់នៃទេសចរណ៍ ជាជាងលើចំនួនអ្នកទេសចរ ។

ជាចុងបញ្ចប់ ត្រូវមានការផ្តោតសេវា និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៅបំរើក្រុមខ្សត់ខ្សោយ និងបង្កើនការចូលរួមពីក្រុមទាំងនេះនៅក្នុងការពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ ។ ទោះជាចំនួនសុទ្ធនៃការចុះឈ្មោះចូលរៀននៅបឋមសិក្សាបានកើនឡើងសំរាប់គ្រប់ក្រុមប្រាក់ចំណូលក្តី ប៉ុន្តែអ្នកក្របំផុតនៅតែទទួលបានសេវាឯទៀតៗ តិចតួចនៅឡើយ ។ ឧ. អ្នកក្រជាងគេ ៤០% ស្ទើរតែមិនបានទទួលសេវាខាងទឹកស្អាត និងអនាម័យសោះ ។ ដូច្នេះត្រូវតែខំផ្តោតការប្រឹងប្រែងដើម្បីឱ្យសេវាភាគច្រើនទៀត បានទៅដល់អ្នកក្រីក្របំផុតដែរ ។

## បទបង្ហាញរបស់លោក ចាន់ សុផល-វិទ្យាស្ថាន CDRI-វបសអ

ថ្វីបើយើងពេញចិត្តចំពោះកំណើនជាទូទៅនៃការអភិវឌ្ឍន៍ ប៉ុន្តែយើងមានការព្រួយបារម្ភយ៉ាងខ្លាំង ដោយសារមានបញ្ហាមួយចំនួនបានផុសឡើង និងប្រហែលវិវត្តកាន់តែធ្ងន់ធ្ងរ បើសិនការអភិវឌ្ឍន៍នៅតំបន់ជនបទមួយចំនួន មិនបានបង្កើនល្បឿនទាន់ពេលនោះទេ ។ បញ្ហាទាំងនោះ រួមមានកំណើនទំនាស់លើការប្រើប្រាស់ទឹករវាងកសិករនិងម្ចាស់ឡូតិ៍នេសាទ ការរុករាននិងការប្រែក្លាយជាទ្រង់ទ្រាយធំនូវដីព្រៃនិងព្រៃលិចទឹក កំណើនភាពងាយរងគ្រោះរបស់អ្នកក្រ ជាពិសេសស្ត្រីក្នុងគ្រួសារក្រីក្របំផុត ហើយនិងការប្រឈមនឹងគ្រោះថ្នាក់នៃការលួចប្លន់ និងការប្រើប្រាស់គ្រឿងញៀន ក្នុងចំណោមយុវជន ។

ការសិក្សាច្រើនឆ្នាំក្នុង៩ភូមិ នៅទូទាំងប្រទេសបង្ហាញថា កំណើនការកាត់បន្ថយភាពក្រីក្រ មិនបានដូចគ្នាគ្រប់កន្លែងទេ ។ សហគមន៍ខ្លះបានរីកចំរើនយ៉ាងខ្លាំងក្នុងរយៈពេលបីឆ្នាំ ខ្លះទៀតគ្មានការប្រែប្រួលសោះ ហើយខ្លះទៀតបានធ្លាក់ក្រជាងមុនថែមទៀត ។ ដូចគ្នាដែរ គ្រួសារខ្លះមានជីវភាពប្រសើរឡើង រឺបានចាកផុតពីភាពក្រីក្រ ប៉ុន្តែខ្លះទៀតមានជីវភាពចុះខ្សោយ រឺធ្លាក់ចូលក្នុងភាពក្រីក្រ ។ កត្តាដែលបង្កចលនាបែបនេះ មានសារៈសំខាន់ណាស់សំរាប់ការពិភាក្សាខាងគោលនយោបាយ ។

ហេតុផលជំរុញឱ្យសហគមន៍មានជីវភាពប្រសើរឡើង មានជាសំខាន់ (១) កំណើនចំណូលពីកសិកម្ម ដោយសារការកែលំអបច្ចេកទេសកសិកម្ម ប្រព័ន្ធធារាសាស្ត្រ និងទីផ្សារ (២) កំណើនលទ្ធភាពទទួលបានឱកាសល្អនៅខាងក្រៅ ដោយសារការកសាងផ្លូវថ្នល់ និង (៣) ការពង្រីកអាជីវកម្មខ្នាតតូចដែលទទួលបានការគាំទ្រមួយចំណែកពីការរីកដុះដាលឥណទានខ្នាតតូច ។

មានបុព្វហេតុសំខាន់មួយដែលធ្វើឱ្យសហគមន៍និងគ្រួសារ កាន់តែខ្សត់ខ្សោយ និងនៅតែក្រីក្រខ្លាំង ។ នៅទសវត្សរ៍កន្លងទៅ គេឃើញមានការខូចខាតព្រៃឈើយ៉ាងលឿន ដោយសារបរាជ័យក្នុងការដាក់អនុវត្តន៍ច្បាប់ ។ ទោះបីជាស្ថិតិជាតិលើបរិមាណត្រីចាប់បាន គ្មានបង្ហាញសញ្ញានៃការថយចុះក្តី ប៉ុន្តែធនធានជលផលកាន់តែប្រមូលបានដោយអ្នកមាន ជាពិសេសអ្នកនៅខាងក្រៅសហគមន៍នេសាទ ។ ជាលទ្ធផល អ្នកក្របែរជាត្រូវប្រឈមនឹងការថយចុះស្តុកត្រី ។ ម្យ៉ាងទៀត ត្រីចាប់បានក៏កាន់តែតូចទៅៗ រីឯត្រីធំៗវាកាន់តែក្រឡើងៗ ។

ការបារម្ភធំមួយទៀត គឺសហគមន៍រស់នៅក្បែរព្រៃឈើ និងបឹងទន្លេសាបហាក់ដូចជាកាន់តែក្រទៅៗ ។ ធនធានរួមដែលខូចខាតស្រាប់នាបច្ចុប្បន្នប្រហែលមិនអាចទ្រទ្រង់ជីវភាពអ្នកក្រីក្របានច្រើនគ្រួសារឡើយ ហើយយើងកំពុងពិចារណាថា តើមានជំរើសអ្វីផ្សេងទៀតសំរាប់ឱ្យគ្រួសារទាំងនោះរស់តទៅមុខ ។ នាពេលថ្មីៗ គ្រួសារមួយចំនួនដែលពឹងផ្អែកលើធនធានព្រៃឈើត្រូវពួកម្ចាស់ដីថ្មីៗជួលឱ្យកាប់ឆ្ការព្រៃ និងធ្វើរបងព័ទ្ធជុំវិញចំការពួកគេក្នុងគោលបំណងរង់ចាំលក់យកចំណេញ ។ ដូច្នេះនៅពេលសកម្មភាពទិញដីស្ងាត់អស់ទៅ គ្រួសារទាំងនោះត្រូវតែស្វែងរករបរចិញ្ចឹមជីវិតផ្សេងទៀតហើយ ។

វិស័យនាំមុខគេពីរ គឺឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ហាក់ដូចមិនបានជួយទ្រទ្រង់ច្រើនទេដល់ការកាត់បន្ថយភាពក្រីក្រ ពីព្រោះវាមានចំណងទាក់ទងទៅដើមខ្សែតិចពេក ។ យើងចង់ឱ្យវិស័យទាំងពីរលូតលាស់ថែមទៀតក៏ពិតមែន ប៉ុន្តែមានការយល់ស្របជាទូទៅថា ការអភិវឌ្ឍន៍កសិកម្មឱ្យទៅជាក្បាលម៉ាស៊ីនទីបីនៃកំណើន គឺជាវិធីសក្តិសិទ្ធិបំផុតសំរាប់កាត់បន្ថយភាពក្រីក្រ ។ ឥឡូវនេះ ដល់ពេលធ្វើសកម្មភាពហើយ ។

ការអភិវឌ្ឍន៍កសិកម្ម តំរូវឱ្យមានការបែងចែកធនធានកាន់តែច្រើនថែមទៀតទៅកសាងប្រព័ន្ធស្រោចស្រព និងធ្វើការផ្សព្វផ្សាយនិងស្រាវជ្រាវខាងកសិកម្ម ។ ការកែលំអលើការចុះបញ្ជីដីធ្លី ការគ្រប់គ្រងដី ការកែច្នៃកសិផល ការរកទីផ្សារសំរាប់ផលិតផលកសិកម្ម និងឥណទានមានការប្រាក់ទាប សុទ្ធសឹងជាកត្តាសំខាន់បំផុត ។ រហូតមកដល់ពេលនេះ ចំណាយទៅលើកសិកម្ម និងប្រព័ន្ធស្រោចស្រព វាមានចំនួនតិចតួចពេក ។ យោងតាមថវិកាជាតិផ្សព្វផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំណាយរដ្ឋាភិបាលលើកសិកម្មនៅឆ្នាំ២០០៥ មានតែ ១៣លានដុល្លារ នៃចំណាយសរុបប្រហែល ៨០០លានដុល្លារ ។ ចំណាយខាងកសិកម្មរបស់អ្នកផ្តល់ជំនួយ មាន ៣៥លានដុល្លារ នៃ ៥០០លានដុល្លារ ។ ចំណាយរបស់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយទៅលើប្រព័ន្ធស្រោចស្រពមានសរុប ១៣លានដុល្លារ នៅឆ្នាំ២០០៥ គឺនៅដដែលក្នុងពីរ-បីឆ្នាំ ចុងក្រោយ ។

ប្រទេសកម្ពុជាមានសក្តានុពលខ្ពស់ ក្នុងការអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម ។ រហូតមកដល់សព្វថ្ងៃ គេតែងមើលរំលងវិស័យនេះ ។ ផលដំណាំវត្ថុធាតុដើមភាគច្រើនតែងនាំចេញទៅប្រទេសជិតខាងដើម្បីកែច្នៃ និងនាំចេញបន្ត ។ កម្ពុជាមិនត្រឹមតែបាត់បង់ឱកាសទទួលបានតំលៃបន្ថែមលើផលិតផលនោះទេ ប៉ុន្តែការនាំចេញទាំងនោះថែមទាំងមិនផ្លូវការ និងមានកំហិតជាច្រើន ។ ដោយសារនៅចិនមានកំនើនតំរូវការផលិតផលកសិកម្ម ដូចជាដំឡូងមី និងសណ្តែកសៀងជាដើម ដូច្នេះគេមានឱកាសរកចំណេញបានច្រើនណាស់ពីវិនិយោគក្នុងកសិ-ឧស្សាហកម្ម ប៉ុន្តែត្រូវមានការកាត់បន្ថយថែមទៀតជាបន្ទាន់នូវបន្ទុកចំណាយក្នុងការធ្វើអាជីវកម្ម និងពាណិជ្ជកម្មនៅកម្ពុជា ។ អ្វីដែលរដ្ឋាភិបាលអាចធ្វើបាន គឺកាត់បន្ថយចំណាយលើការដឹកជញ្ជូន និងការយកកំរៃផ្សេងៗនៅព្រំដែន ។

កម្ពុជា នៅតែជាប្រទេសមានចំណាយខ្ពស់ខាងដឹកជញ្ជូន និងថាមពល ។ យោងតាមការសិក្សាប្រៀបធៀបនៅឆ្នាំ២០០៤ ដោយបណ្តាវិទ្យាស្ថានស្រាវជ្រាវនៅក្នុងបណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ដែលនាំមុខដោយវិទ្យាស្ថានវបសអ-CDRI ការដឹកជញ្ជូនផលដំណាំ ១តោន ជាពោត សណ្តែកសៀង រឺដំឡូងមី ក្នុងចំងាយផ្លូវ ១០០គ.ម ត្រូវចំណាយអស់ ១០-១២ដុល្លារ នៅកម្ពុជា ប៉ុន្តែអស់ត្រឹម ៤-៥ដុល្លារនៅវៀតណាម និង ២,៥ដុល្លារនៅថៃ ។ ចំណាយកាន់តែអស់ច្រើន និងស្មុគស្មាញថែមទៀត ចំពោះការនាំចេញផលិតផលកសិកម្មឆ្លងកាត់ព្រំដែន ។ ឧ. សំរាប់ពោត ១០តោន កំរៃសរុប គឺ ៥០-៨០ដុល្លារ សំរាប់ឯច្រកព្រំដែនខ្លះនៅតាមព្រំដែនថៃ ។ ពាណិជ្ជករត្រូវឆ្លងកាត់អាជ្ញាធរមួយចំនួន ដូចជា នគរបាលអន្តរជាតិ គយ កាំកុងត្រូល នគរបាលសេដ្ឋកិច្ច ទាហាន អាវុធហត្ថ អាជ្ញាធរព្រំដែន និងអ្នកសំរបសំរួលព្រំដែនទាំងសងខាង ។

អាជ្ញាធរខ្លះមានការិយាល័យផ្សេងគ្នា សំរាប់ថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក ។

កម្ពុជាអាចធ្វើសកម្មភាពបានច្រើនថែមទៀត ដើម្បីប្រមូលផលប្រយោជន៍ពីកំណើនឱកាសបានចូលទៅក្នុងទីផ្សារតំបន់ និងទីផ្សារពិភពលោក ។ រឿងនេះអាចធ្វើទៅបាន ដោយបង្កើនផលិតកម្ម និងវិនិយោគនៅក្នុងការកែច្នៃកសិផល និងដោយកាត់បន្ថយចំណាយម៉ាឃីតទីង ។ កម្ពុជាអាចប្រើប្រាស់ដីបានប្រសើរជាងនេះ ដើម្បីជួយអ្នកក្រ ទាំងនៅតំបន់ចាស់ និងថ្មី ដែលមានការកាប់បំផ្លាញព្រៃឈើ ដោយកែលំអប្រព័ន្ធស្រោចស្រព ផ្ដល់ឱកាសឱ្យចូលពាក់ព័ន្ធទីផ្សារ និងធ្វើការបែងចែកដីដោយមានសមធម៌ ។ ក្នុងនេះដែរ សម្បទានដីសេដ្ឋកិច្ចដែលមិនដំណើរការ គួរតែពិចារណាឡើងវិញឱ្យបានម៉ត់ចត់ ។ ការទិញលក់កេងយកចំណេញ និងការទន្ទ្រានយកដី ដែលកើនឡើងយ៉ាងលឿន គួរគ្រប់គ្រងឱ្យបានដោយប្រមូលយកពន្ធលើដីធំៗ ។ វិធានការនេះ នឹងជួយបង្កើនផលិតកម្មផលដំណាំសំរាប់បំពេញតំរូវការក្នុងតំបន់ដែលកំពុងវិវត្តយ៉ាងលឿននេះ ។ ឧ. នៅឆ្នាំ២០០៥ ថៃ និងវៀតណាមបាននាំចេញដំឡូងមី ៥០០លានដុល្លារ និង ៥០លានដុល្លារ ទៅចិន ។ សំរាប់កម្ពុជាគេប៉ាន់ស្មានថា បាននាំចេញដំឡូងមីប្រហែល ៥លានដុល្លារប៉ុណ្ណោះក្នុងឆ្នាំនោះ ។ ការសិក្សារបស់យើងបង្ហាញថា កម្ពុជាអាចបង្កើនផលិតកម្មជាច្រើនដងទៀត បើសិនចេះប្រើប្រាស់ដីឱ្យមានប្រសិទ្ធភាព ។ ដោយហេតុថា ដំណាំជាច្រើនអ្នកក្រអាចដាំដុះបាន ដូច្នេះកំណើនផលិតកម្ម ការកែច្នៃ និង ការនាំចេញ នឹងជួយកាត់បន្ថយភាពក្រីក្រដោយផ្ទាល់ ។

ដើម្បីឱ្យផលិតកម្ម ការកែច្នៃ និងម៉ាឃីទីងផលដំណាំទទួលបានចំណេញត្រូវមានសកម្មភាពសំខាន់ៗដូចតទៅ:

- ផ្ដល់គ្រឿងលើកទឹកចិត្តដល់វិស័យឯកជន ដើម្បីបង្កើនវិនិយោគក្នុងឧស្សាហកម្មកែច្នៃកសិផល
- ប្រើប្រាស់ដីដោយមានប្រសិទ្ធភាព និងកាត់បន្ថយចំណាយប្រតិបត្តិការរបស់អាជីវកម្ម (រួមទាំង ចំណាយដឹកជញ្ជូន និងកំរៃនៅតាមព្រំដែន) ដើម្បីជួយឱ្យវិនិយោគមានផលចំណេញ
- ផ្ដល់គ្រឿងលើកទឹកចិត្តដល់មន្ត្រីរាជការ ឱ្យជួយសំរួលពិតៗដល់កិច្ចប្រឹងប្រែងរបស់វិស័យឯកជន មិនអោយរាំងស្ទះដល់ការងាររបស់គេទេ ។

### បទបង្ហាញរបស់លោក ឈិត សំអាត-អង្គការ NGO Forum

កម្ពុជាមានការអភិវឌ្ឍន៍យ៉ាងខ្លាំងក្នុងរយៈ១០ឆ្នាំចុងក្រោយ មានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ជាប់រហូត ហើយបច្ចុប្បន្នមានសន្តិភាពពេញលេញល្អ ។ អត្រាភាពក្រីក្រ បានថយចុះប្រហែល ៨% ។ ជាមួយគ្នានេះ វិសមភាពរវាងអ្នកមាន និងអ្នកក្រ បានកើនឡើង ធ្វើឱ្យកម្ពុជាធ្លាក់ចូលទៅក្នុងចំណោមប្រទេសដែលមានគំលាតខ្ពស់ជាងគេរវាងអ្នកមាន និងអ្នកក្រ ។ ភាពក្រីក្រនៅតែមានអត្រាខ្ពស់ដល់ ៣៥% ។ អត្រាមរណៈកុមារ បានកាត់បន្ថយមកត្រឹម ៦៥នាក់/១.០០០កំណើតរស់ រីឯអត្រាមរណៈមាតុភាពនៅតែខ្ពស់ ប្រហែល ៤៧២នាក់/១០០.០០០ កំណើតរស់ ។[១]

មានសំនួរផុសឡើងថា តើអន្តរាគមន៍អភិវឌ្ឍន៍ត្រូវផ្ដោតយ៉ាងដូចម្ដេច ដើម្បីកាត់បន្ថយភាពក្រីក្របានលឿន មានសមភាពកាន់តែប្រសើរ និងធ្វើឱ្យអភិវឌ្ឍន៍មានចីរភាពពិតៗ? ក្នុងនេះយើងត្រូវពិចារណាលើ ១) គំរូល្អបំផុតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីសំរេចបានការអភិវឌ្ឍន៍មានចីរភាព និងសមភាព និង ២) សកម្មភាពនានាដែលផ្ដោតជាសំខាន់លើអ្នកក្រីក្រ និងជនងាយរងគ្រោះ ។

អង្គការមិនមែនរដ្ឋាភិបាល (NGOs) ភាគច្រើន កំពុងធ្វើការជាមួយក្រុមអ្នកក្រីក្រ និងជនងាយរងគ្រោះ ដូចជា អ្នកក្រគ្មានដី ភូមិជនបទដាច់ស្រយាល ប្រជាជនដើម សហគមន៍ពឹងផ្អែកលើព្រៃឈើនិងការនេសាទ ជនពិការ ជនរងគ្រោះដោយសារការជួញដូរនិងអំពើហិង្សាក្នុងគ្រួសារ ជនរងគ្រោះដោយជំងឺអេដស៍ សហគមន៍ក្រីក្រនៅតំបន់ទីក្រុង និងជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្ស ។ NGOs បានមើលឃើញជារឿយៗពីបែបបទដែលកំណើននិងការអភិវឌ្ឍន៍សេដ្ឋកិច្ច បានរំលងចោលពួកអ្នកក្រីក្រ និងជនងាយរងគ្រោះ ហើយពេលខ្លះវាធ្វើឱ្យពួកគេរឹតតែយ៉ាប់យ៉ឺនថែមទៀត ។

ដោយមូលហេតុដូចខាងលើ NGOs ជារឿយៗបានទិតៀនដល់ទស្សនៈថា កម្ពុជាចាំបាច់ត្រូវទាក់ទាញវិនិយោគគ្រប់ប្រភេទ និងស្វែងរកកំណើនសេដ្ឋកិច្ចគ្រប់បែបយ៉ាង ។ តាមពិត វិនិយោគប្រភេទខ្លះអាចបំផ្លិចបំផ្លាញដល់ជីវភាពរស់នៅរបស់សហគមន៍ក្រីក្រ និងបង្វែរធនធានចេញពីអ្នកក្រទៅឱ្យអ្នកមាន និងគ្រួសារមធ្យមទៅវិញ ។

យើងមិនបាច់រៀបរាប់លំអិតពេកទេ ពីការព្រួយបារម្ភចំពោះផលប៉ះពាល់នៃសម្បទានដីកសិកម្មធំៗផ្ដល់ទៅឱ្យក្រុមហ៊ុន ដោយយកដីដែលអ្នកភូមិជនបទប្រើប្រាស់ធ្វើកសិកម្ម រឺសំរាប់ប្រមែប្រមូលធនធានធម្មជាតិ ។ NGOs និងម្ចាស់ជំនួយ បានលើកឡើងជារឿយៗពីការព្រួយបារម្ភនេះ ។ នាពេលថ្មីៗ NGOs នៅកម្ពុជា បានរកឃើញថា បញ្ហាទាំងនេះមិនមែនមានតែនៅកម្ពុជាទេ ប៉ុន្តែមាននៅទូទាំងអាស៊ីអគ្នេយ៍ ។ ក្នុងកិច្ចប្រជុំនៅខេត្តក្រចេះ ស្ដីពីផលប៉ះពាល់នៃចំការដំណាំ ពួក NGOs មកពីតំបន់នេះបានប្រកាសថា "ចំការដំណាំ បានកាត់បន្ថយជាខ្លាំងនូវចំនួនដីសំរាប់ឱ្យសហគមន៍ជនបទធ្វើផលិតកម្មកសិកម្ម ។ សម្បទានចំការដំណាំជាច្រើន បានអនុញ្ញាតឱ្យក្រុមហ៊ុនកាត់យកដីមានជីជាតិបំផុតពីភូមិនានា ទៅដាំដុះដំណាំតែមួយមុខ ។ រឿងនេះមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់បរិស្ថាននៅមូលដ្ឋាន ដូចជា ការបាត់បង់ជីវចំរុះ ការថយចុះគុណភាពដី កំណើនភាពខ្សោះហួតហែង និងការបំពុលប្រភពទឹកក្នុងមូលដ្ឋាន" ។[២]

គំរូល្អជាងនេះនៃការអភិវឌ្ឍន៍ជនបទ គឺអាចជាការដាក់ទុកធនធានឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់កសិករកម្ពុជា ។ បើសិនមានសន្តិសុខកម្មសិទ្ធិដីធ្លី និងលទ្ធភាពទទួលបានព័ត៌មាននិងធនធាន កសិករតូចតាចអាចបង្កើនផលិតភាព និងកសាងជីវភាពល្អប្រសើរសំរាប់ក្រុមគ្រួសាររបស់ខ្លួនបាន ។ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ អាចកែលំអឡើងតាមរយៈការគាំទ្រកសិកម្មចំរុះ រួមមាន ស្រូវ ត្រី បន្លែ ដំណាំលើភ្លឺស្រែ ដើមឈើហូបផ្លែ ។ល។ NGOs បានជួយមតិឱ្យផ្ដល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករតូចតាច និងការប្រើបច្ចេកទេសចំណាយអស់ធាតុចូលតិច ដើម្បីបង្កើនផលដំណាំ ។

ដូចគ្នាដែរ នៅតំបន់ទីក្រុងត្រូវមានតុល្យភាពកាន់តែប្រសើររវាងផលប្រយោជន៍នៃការអភិវឌ្ឍន៍ពាណិជ្ជកម្ម ហើយនិងតំរូវការរបស់អ្នកក្រ ។ គេតែងចាត់ទុកកន្លែងតាំងទីលំនៅអនាធិបតេយ្យថាខុសច្បាប់ និងអាក្រក់មើល ប៉ុន្តែវាផ្ដល់ផ្ទះស្នាក់នៅតំលៃថោក ដែលរកមិនបានទេនៅកន្លែងត្រឹមត្រូវ ។ ពលកម្ម និងសេវាកម្មថោកៗ ផ្ដល់ដោយអ្នករស់នៅកន្លែងទាំងនោះ គឺជាចំណែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចនៅទីក្រុង ។ ជំនួសឱ្យការដេញពួកគេចេញ គួរខំប្រឹងប្រែងផ្ដល់សេវាកម្ម និងកែលំអសិទ្ធិកាន់កាប់ដីរបស់សហគមន៍ទាំងនេះវិញ ។

តុល្យភាពរវាងតំរូវការនិងសិទ្ធិរបស់អ្នកក្រ ហើយនិងតំរូវការនៃពាណិជ្ជកម្ម ចាំបាច់ត្រូវតែមាននៅក្នុងករណីទាំងអស់នេះ ។ ការអនុវត្តន៍ក្របខ័ណ្ឌច្បាប់មួយយ៉ាងរឹងមាំ ត្រូវតែធ្វើឡើងដើម្បីបង្កើតតុល្យភាពនេះឡើងវិញ ។ ដូច្នេះ ការផ្ដល់សម្បទានដីសេដ្ឋកិច្ច ត្រូវមានការចុះបញ្ជីដីរដ្ឋជាមុន និងត្រូវវាយតំលៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច និងសង្គមកិច្ច ។ ការប្តូរកន្លែងប្រជាជនរស់

នៅអាចធ្វើបាន ដោយមានសំណងសមស្រប ។ ទោះយ៉ាងនេះក្តី ខ្ញុំសូមផ្តល់មតិថា ការយល់ឃើញរបស់យើងពីរឿង "ការអភិវឌ្ឍន៍" ក៏គួរមានតុល្យភាពជាងនេះដែរ ។ ការអភិវឌ្ឍន៍មិនគួរវាស់វែងតែតាមរយៈកំណើនសេដ្ឋកិច្ច រឺចំនួនវិនិយោគិនចូលមកប្រទេសយើងនោះទេ ។ ការអភិវឌ្ឍន៍គឺកើតមានឡើងនៅពេលមនុស្សធម្មតា ជាពិសេសអ្នកក្រនិងជនងាយរងគ្រោះ មានការរីកចំរើនភ្លាមៗ និងឋិតថេរយូរអង្វែងក្នុងសុខមាលភាព និងសមត្ថភាពគ្រប់គ្រងអនាគតរបស់ខ្លួន ។

**កំណត់សំគាល់**

១. សូមមើលការវាយតំលៃភាពក្រីក្រនៅកម្ពុជា របស់ធនាគារពិភពលោកឆ្នាំ២០០៦ និងអង្កេតស្តីពីសុខភាពនិងប្រជាសាស្ត្រកម្ពុជា របស់រាជរដ្ឋាភិបាលឆ្នាំ២០០៥

២. របាយការណ៍របស់សន្និសីទទន្លេមេគង្គក្នុងតំបន់ស្តីពីចំការដំណាំ នៅខេត្តក្រចេះ (ខែវិច្ឆិកា ឆ្នាំ២០០៦) ។

---

*តពីទំព័រ ៤* **កម្ពុជាៈ ការពិនិត្យស្ថានភាពម៉ាក្រូសេដ្ឋកិច្ចពីឆ្នាំ២០០៧...**

(D&D) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) និងកំណែទំរង់រដ្ឋបាលសាធារណៈ (PAR) នឹងអាចជួយដោះស្រាយបញ្ហាប្រឈមបានមួយចំនួន ។ D&D កំពុងជឿនលឿនទៅមុខ ដោយមានមេរៀនល្អៗពីក្រុមប្រឹក្សាឃុំ ប៉ុន្តែនៅមានបញ្ហាប្រឈមចំពោះថ្នាក់ខេត្ត និងថ្នាក់ស្រុក ដូច្នេះត្រូវមានកំណែទំរង់វិសហមជ្ឈការតាមវិស័យពាក់ព័ន្ធទៀត ដើម្បីបំពេញបន្ថែមឱ្យកំណែទំរង់ D&D ។ កម្មវិធីកំណែទំរង់ PFM ក្នុងរយៈពេលពីរឆ្នាំចុងក្រោយបានចាប់ផ្តើមហុចលទ្ធផលគួរឱ្យកត់សំគាល់ហើយ ក្នុងការកែទំរង់ការគ្រប់គ្រងចំណូលចំណាយសាធារណៈ ។ វាបើកលទ្ធភាពជាច្រើនសំរាប់តំរង់ទិសចំណាយសាធារណៈឱ្យបានសក្តិសិទ្ធិនិងមានប្រសិទ្ធភាព ដើម្បីជួយកាត់បន្ថយភាពក្រីក្រ ។ PAR លូតលាស់ទៅមុខយឺតៗ ប៉ុន្តែត្រូវជួបនឹងបញ្ហាប្រឈមចំបងៗ ជាពិសេសក្នុងការកំណត់មុខងារច្បាស់លាស់សំរាប់ស្ថាប័នសាធារណៈ និងបុគ្គលិកស្ថាប័នទាំងនោះ ការបង្កើតគ្រឿងលើកទឹកចិត្តសំរាប់លទ្ធផលល្អ និងគណនេយ្យភាព និងការបង្កើតស្មារតីចង់កសាងស្នាដៃ និងវិជ្ជាជីវៈនិយមក្នុងចំណោមមន្ត្រីរាជការស៊ីវិល ។

**សេចក្តីសង្ខេប និងសន្និដ្ឋាន**

មានសេចក្តីសន្និដ្ឋានចំបងៗបួន និងសំនួរស្តីពីគោលនយោបាយពាក់ព័ន្ធមួយចំនួន :

- កំណើនសេដ្ឋកិច្ចមានល្បឿនគួរឱ្យកត់សំគាល់ ប៉ុន្តែត្រូវមានយុទ្ធសាស្ត្ររយៈពេលមធ្យមនិងវែង ជាពិសេសសំរាប់ធ្វើចំរុះកម្មប្រភពកំណើន និងអភិវឌ្ឍវិស័យកសិកម្មឱ្យទៅជាក្បាលម៉ាស៊ីនទីបីនៃកំណើន ។ តើមានលទ្ធភាពអ្វីខ្លះសំរាប់ចែករំលែកវិបុលភាពឱ្យបានច្រើន? តើវិស័យឯកជន អាចធ្វើយ៉ាងណាដើម្បីរួមចំណែកកាន់តែមានប្រសិទ្ធភាពនៅក្នុងកំណើនសេដ្ឋកិច្ច និងមានឥទ្ធិពលដល់ការបង្កើតគោលនយោបាយ ?
- ការកាត់បន្ថយភាពក្រីក្របានសំរេចមួយកំរិតតូច ប៉ុន្តែវិសមភាព និងចលករភាពក្រីក្រដទៃទៀត (ដូចជា ភាពគ្មានដីធ្លី ឥរិយាបថគ្រោះថ្នាក់របស់បុរសៗ និងបញ្ហាប្រឈមចំពោះស្ត្រីជាមេគ្រួសារ) កំពុងផុសឡើង ។ តើកំណើនសេដ្ឋកិច្ច អាចជួយកាត់បន្ថយភាពក្រីក្រយ៉ាងដូចម្តេចបាន? តើគំនិតផ្តួចផ្តើម និងកម្មវិធីសាធារណៈអាចពង្រីកបន្ថែមយ៉ាងដូចម្តេច ដើម្បីឱ្យបានទៅដល់អ្នកក្រ និងជនងាយរងគ្រោះ រួមទាំងស្ត្រីផង?
- ធនធានធម្មជាតិកាន់តែទទួលរងការខូចខាត និងការគំរាមកំហែងកាន់តែច្រើនឡើងៗ ដោយសារកង្វះការដាក់អនុវត្តន៍គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ និងសមត្ថភាពទន់ខ្សោយរបស់តួអង្គនៅមូលដ្ឋាន ។ តើធនធានធម្មជាតិអាចគ្រប់គ្រង និងការពារយ៉ាងដូចម្តេច ដើម្បីជំរុញឱ្យអ្នកក្រមានឱកាសប្រើប្រាស់វាប្រកបដោយចីរភាព?
- កំណែទំរង់អភិបាលកិច្ច និងស្ថាប័ន នៅមិនទាន់រីកចំរើនគ្រប់គ្រាន់ទេ ដើម្បីជួយបង្កើនឱកាសយ៉ាងលឿនសំរាប់កំណើន និងការអភិវឌ្ឍន៍ ។ ការអនុមតិច្បាប់ប្រឆាំងអំពើពុករលួយ និងច្បាប់អង្គការ មានសារៈសំខាន់បំផុត គឺដូចគ្នានឹងការប្តេជ្ញាចិត្តខាងនយោបាយ និងការគាំទ្ររបស់សហគមន៍ ដើម្បីធ្វើកំណែទំរង់រដ្ឋាភិបាល ។ តើកំណែទំរង់ស្ថាប័នត្រូវអនុវត្តយ៉ាងដូចម្តេច ដើម្បីសំរេចគោលដៅរបស់រដ្ឋាភិបាល? តើប្រជាជនកម្ពុជា យល់ឃើញយ៉ាងណាពីឋានៈជាពលរដ្ឋរបស់ខ្លួន? តើយើងអាចកសាងមោទនភាពជាតិ និងការទទួលខុសត្រូវរបស់ប្រជាជនស៊ីវិលយ៉ាងដូចម្តេច ដើម្បីជំរុញនិងរក្សាបានការចូលរួមរបស់ប្រជាជន?
- ចក្ខុវិស័យវិទ្យាស្ថាន CDRI សំរាប់កម្ពុជាគឺ : (១) កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការចែករំលែកប្រកបដោយសមធម៌ នូវផលនៃកំណើន (២) ការសំរេចលក្ខខណ្ឌ MDG ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាលនៅឆ្នាំ២០១៥ (៣) ការប្រើប្រាស់មានចីរភាពនូវការគ្រប់គ្រងដី និងធនធានធម្មជាតិ (៤) ការធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធពាណិជ្ជកម្ម និងអភិបាលកិច្ច ក្នុងតំបន់/អន្តរជាតិ និង (៥) ស្ថាប័នអភិបាលកិច្ចខ្លាំងក្លា និងមានប្រសិទ្ធភាពដែលឆ្លើយតបនឹងតំរូវការរបស់ប្រជាជន ។ នៅវិទ្យាស្ថាន CDRI យើងជឿជាក់ថា មធ្យោបាយដើម្បីសំរេចបាននូវចក្ខុវិស័យនេះ គឺត្រូវមាន រដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ធ្វើការរួមគ្នាដើម្បីអនាគតប្រទេសកម្ពុជា ។

**ឯកសារយោង**


Eng Netra (2007), "CDRI's Vision for Cambodia's Development", Speech at the CDRI/ANZ Royal 2007 Cambodia Outlook Conference, February 23

Hang Chuon Naron (2007), "Macroeconomic Performance 2006–2015", Presentation at the CDRI/ANZ Royal 2007 Cambodia Outlook Conference, February 23

Nelmes, John (2007), "Cambodia: Macroeconomic Developments", Presentation at the CDRI/ANZ Royal 2007 Cambodia Outlook Conference, February 23

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៤ ២០០៦ ផសស ពិត របស់ US កើនតាមអត្រាប្រចាំឆ្នាំ ២,៥% ធៀបនឹង ២,០% នៅត្រីមាសទី៣ ។ អត្រានេះឆ្លុះបញ្ចាំងជាសំខាន់ពីកំនើនចំណាយរបស់អ្នកប្រើប្រាស់ ការនាំចេញ ចំណាយរដ្ឋាភិបាល និងការធ្លាក់ចុះការនាំចូល ។

ផសស ពិត នៅតំបន់អឺរ៉ូ នៅត្រីមាសទី៤ ឆ្នាំ២០០៦ កើន ៣,៣% ខ្ពស់ជាងត្រីមាសដូចគ្នាឆ្នាំមុន និងកើន ០,៩% ធៀបនឹងត្រីមាសមុន ។ ផសស ពិត របស់ជប៉ុន កើន ២,៣% ធៀបនឹងមួយឆ្នាំមុន និង ១,២% ធៀបនឹងត្រីមាសមុន ។

នៅត្រីមាសទី៤ ឆ្នាំ២០០៦ សេដ្ឋកិច្ចចិននៅរក្សាកំណើនយ៉ាងខ្ពស់តាមអត្រាប្រចាំឆ្នាំ ១០,៧% ។ វិស័យឧស្សាហកម្មបន្តកើនឡើង (១២,៥%) លឿនជាងវិស័យសេវាកម្ម (១០,៣%) និងវិស័យកសិកម្ម (៥,០%) រីឯវិនិយោគ និងការនាំចេញនៅតែជាកត្តាជំរុញដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចនេះ ។

ផសស ពិត នៅកូរ៉េខាងត្បូង នៅត្រីមាសទី៤ កើន ៥,០% ធៀបនឹងមួយឆ្នាំមុន និងកើន ០,៨% ធៀបនឹងត្រីមាសមុន ។ នៅត្រីមាសទី៤ ផសស ពិត របស់តៃវ៉ាន់ និងហុងកុង កើន ៤,០% និង ៧,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។

នៅត្រីមាសទី៤ សេដ្ឋកិច្ចម៉ាឡេស៊ី កើន ៥,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ឧស្សាហកម្មផលិត និងសេវាកម្ម កើន ៤,៣% និង ៧,០% រីឯវិស័យកសិកម្ម កើន ៦,៥% ។ ចំណាយប្រើប្រាស់ចុងក្រោយ និងការនាំចេញថយកំណើនមកត្រឹម ៦,៧% និង ១០,៥% ធៀបនឹងមួយឆ្នាំមុន ។

សេដ្ឋកិច្ចសិង្ហបុរី នៅត្រីមាសទី៤ កើន ៧,០% ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ។ ឧស្សាហកម្មផលិត កើន ៨,០% រីឯវិស័យសេវាកម្មកើន ៧,៧% ។

នៅត្រីមាសទី៤ ផសស ពិត នៅថៃ កើន ៤,៧% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៥ ។ វិស័យកសិកម្មកើន ០,៩% រីតិចជាងត្រីមាសមុន (៤,៧%) ដោយសារការធ្លាក់ចុះផលិតកម្មដំណាំ សត្វចិញ្ចឹម និងការនេសាទ ។ វិស័យមិនមែនកសិកម្ម កើន ៤,៦% ធៀបនឹងមួយឆ្នាំមុន គឺតិចជាងកំណើន ៤,៧% នៅត្រីមាសមុន ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី៤ ២០០៦ ថ្លៃទំនិញប្រើប្រាស់នៅ US ថយអត្រាកំនើនប្រចាំឆ្នាំមកត្រឹម ១,៩% ធៀបនឹងកំនើន ៣,៣% នៅត្រីមាសទី៣ ដោយសារប្រេងឆៅ និងថាមពលផ្សេងៗទាក់ទងនឹងប្រេងបានធ្លាក់ថ្លៃ ។ នៅតំបន់អឺរ៉ូ អតិផរណាមានអត្រា ១,៨% រីទាបបន្តិចជាងកំរិតអតិបរមា ២% កំណត់ដោយធនាគារកណ្តាលអឺរ៉ុប (European Central Bank: ECB) ។ ថ្លៃប្រេងធ្លាក់ចុះ គឺជាកត្តាចំបងនៃការថយចុះអត្រាអតិផរណានៅតំបន់អឺរ៉ូ ។ នៅជប៉ុន ថ្លៃទំនិញប្រើប្រាស់កើន ០,៣% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី៤ ធៀបនឹង ០,៦% នៅត្រីមាសមុន ។ ទោះបីក្នុងរយៈមួយឆ្នាំនេះថ្លៃទំនិញប្រើប្រាស់កើនឡើងក្តី ប៉ុន្តែវាសឹងគ្មានភាពប្រែប្រួលទេ បើសិនគេមិនរាប់បញ្ចូលផលិតផលប្រេង និងកត្តាពិសេសៗឯទៀត ។

នៅទីផ្សារប្តូរប្រាក់អន្តរជាតិ ដុល្លារUS បានវិវត្តចំរុះទល់នឹងរូបិយវត្ថុចំបងៗ នៅត្រីមាសទី៤ ឆ្នាំ២០០៦ ។ ទល់នឹងប្រាក់យ៉េនជប៉ុន ដុល្លារUS ប្តូរបាន ១១៧,៨យ៉េន/ដុល្លារUS រីឡើងថ្លៃ បើធៀបនឹងអត្រា ១១៦,៣ យ៉េន/ដុល្លារUS ក្នុងត្រីមាសទី៣ ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៧៨អឺរ៉ូ/ដុល្លារUS គឺស្មើនឹងអត្រានៅត្រីមាសមុន ។ ទល់នឹងប្រាក់វ៉ុនកូរ៉េខាងត្បូង និងប្រាក់យ៉ុនចិន ដុល្លារUS ធ្លាក់ថ្លៃមកត្រឹម ៩៣៨វ៉ុន/ដុល្លារUS និង ៧,៨៦យ៉ុន/ដុល្លារUS ធៀបនឹង ៩៥៥វ៉ុន/ដុល្លារUS និង ៧,៩៧យ៉ុន/ដុល្លារUS នៅត្រីមាសមុន ។ ការធ្លាក់ថ្លៃដុល្លារUS ជាប់ទាក់ទិននឹងប្រតិកម្មទីផ្សារចំពោះស្ថានភាពជាក់ស្តែង នៃការថយចុះសកម្មភាពសេដ្ឋកិច្ចនៅUS ខណៈដែលសេដ្ឋកិច្ចធំៗ (លើកលែងជប៉ុន) និងប្រទេសមួយចំនួននៅអាស៊ីអគ្នេយ៍បន្តមានកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំង ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៤ ពោត ប្រេងឆា និងសណ្តែកសៀងឡើងថ្លៃ រីឯអង្ករ ប្រេងឆៅ សាំង និងម៉ាស៊ូតធ្លាក់ថ្លៃ ។ ប្រេងឆាលក់ថ្លៃ ៤៩៤,៩២ដុល្លារUS/តោន (ឡើងថ្លៃពី ៤៤៦,៨៥ដុល្លារUS/តោន) រីឯពោត និងសណ្តែកសៀងលក់ថ្លៃ ១៤០,១៨ដុល្លារUS/តោន និង ២៧៩,១០ដុល្លារUS/តោន ។ នៅទីផ្សារបាងកក អង្ករថៃ ១០០%B ថុនលេខ២ លក់ថ្លៃ ២៧៩,១០ដុល្លារUS/តោន គឺទាបជាងថ្លៃ ២៨៩,៩១ដុល្លារUS/តោន នៅត្រីមាសទី៣ ។ នៅត្រីមាសទី៤ ប្រេងឆៅធ្លាក់ថ្លៃ ១៦% ធៀបនឹងត្រីមាសមុន មកត្រឹម ៥៦,៣៩ដុល្លារUS/ធុង ។ សាំង និងម៉ាស៊ូតធ្លាក់ថ្លៃ ២២% និង ១៧% ធៀបនឹងត្រីមាសមុន ដោយលក់ថ្លៃ ៤១,០២សេន/លីត្រ និង ៤៦,១១សេន/លីត្រ នៅត្រីមាសទី៤ ឆ្នាំ២០០៦ ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភីម រុនស៊ីណារិទ្ធិ*

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2001 | 2002 | 2003 | 2004 | 2005 Q4 | 2006 Q1 | 2006 Q2 | 2006 Q3 | 2006 Q4 | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 6.7 | 4.8 | 7 | 7.7 | - | - | - | - | - | 13.4 |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 4.9 | 4.6 | 5.2 | 5.5 | 6.1 | 5.6 |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7 | 5.2 | 5.5 | 5.9 | 5.8 | 5.7 | 5.2 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 7.7 | 10.7 | 8.0 | 7.1 | 7.0 | 5.7 |
| ថៃ | 1.9 | 6.1 | 6.9 | 6 | 4.7 | 6.0 | 4.9 | 4.7 | 4.2 | 4.5 |
| វៀតណាម | 6.0 | 6.7 | 7 | 7.5 | - | - | - | - | - | 8.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.9 | 10.9 | 11.3 | 10.4 | 10.7 | 9.6 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 7.6 | 8.2 | 5.2 | 6.8 | 7.0 | 6.5 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3 | 4.7 | 5.2 | 6.1 | 5.3 | 4.8 | 5.0 | 4.7 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | 6.0 | 4.9 | 4.6 | 5.0 | 4.02 | - |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.8 | 2.0 | 2.4 | 2.6 | 3.3 | 1.5 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 4.5 | 3.0 | 2.2 | 2.7 | 2.3 | 2.5 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 1.1 | 5.6 | 2.6 | 2.2 | 2.5 | 3.0 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## តារាង ២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.6 | 3.2 | 1.2 | 4.0 | 6.6 | 6.1 | 4.5 | 4.9 | 3.4 | 5.8 |
| ឥណ្ឌូនេស៊ី | 11.5 | 13.2 | 8.3 | 8.3 | 17.3 | 16.9 | 15.5 | 14.9 | 6.1 | 10.5 |
| ម៉ាឡេស៊ី | 1.4 | 1.8 | 1.1 | 1.6 | 3.4 | 3.9 | 4.1 | 3.6 | 3.1 | 3.1 |
| សិង្ហបុរី | 1.0 | -0.4 | 0.5 | 1.7 | 1.1 | 1.4 | 1.2 | 0.7 | 0.6 | 0.5 |
| ថៃ | 1.7 | 0.6 | 1.8 | 2.7 | 6.0 | 5.7 | 6.0 | 3.6 | 3.3 | 4.5 |
| វៀតណាម | -0.4 | 3.8 | 3.2 | 8.3 | 10.0 | 10.3 | - | - | - | 8.2 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.9 | -0.7 | 1.2 | 3.9 | 1.4 | 1.2 | 1.4 | 1.4 | 1.8 | 1.8 |
| ហុងកុង | -1.3 | -3.0 | -2.6 | -0.4 | 1.8 | 2.0 | 2.1 | 2.3 | 2.2 | 1.1 |
| កូរ៉េខាងត្បូង | 4.4 | 2.7 | 3.5 | 3.5 | 2.5 | 2.4 | 2.3 | 2.5 | 2.4 | 2.8 |
| តៃវ៉ាន់ | -0.01 | -0.2 | -0.3 | 1.6 | 2.5 | 1.4 | 1.5 | -0.3 | -0.1 | 2.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.6 | 2.2 | 2.1 | 2.2 | 2.4 | 2.3 | 2.3 | 2.1 | 1.8 | 2.2 |
| ជប៉ុន | -0.6 | -0.9 | -0.3 | Nil | -0.5 | 0.4 | 0.7 | 0.6 | 0.3 | -0.3 |
| សហរដ្ឋអាមេរិក | 2.8 | 1.6 | 2.3 | 2.7 | 3.7 | 3.7 | 4.0 | 3.3 | 1.9 | 3.4 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

## តារាង ៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,916.3 | 3,912.1 | 3,973 | 4,016.3 | 4,154.3 | 4,081.3 | 4,095.3 | 4145.3 | 4129.4 | 4,092.5 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10,261 | 9,311 | 8,577 | 8,938 | 9,999 | 9,175 | 9,115 | 9,122 | 9124 | 9,705 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.80 | 3.80 | 3.80 | 3.78 | 3.73 | 3.65 | 3.67 | 3.62 | 3.79 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.79 | 1.74 | 1.69 | 1.69 | 1.63 | 1.59 | 1.58 | 1.56 | 1.66 |
| ថៃ (បាត) | 44.4 | 42.9 | 41.5 | 40.2 | 41.02 | 39.3 | 38.1 | 37.7 | 36.5 | 40.2 |
| វៀតណាម (ដុង) | 14,725 | 15,280 | 15,510 | - | 15,907 | 15,921 | - | - | - | 15,859 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.08 | 8.05 | 8.01 | 7.97 | 7.86 | 8.19 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.78 | 7.79 | 7.75 | 7.76 | 7.76 | 7.78 | 7.78 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,291 | 1,251 | 1,192 | 1,145 | 1,036 | 976 | 949 | 955 | 938 | 1,024 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.8 | 34.5 | 34.4 | 33.6 | 33.4 | 32.3 | 32.2 | 32.8 | 32.8 | 32.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.12 | 1.06 | 0.89 | 0.80 | 0.84 | 0.83 | 0.80 | 0.78 | 0.78 | 0.80 |
| ជប៉ុន (យ៉េន) | 121.5 | 125.4 | 115.9 | 108.2 | 117.2 | 116.9 | 114.5 | 116.3 | 117.8 | 110.2 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

## តារាង ៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០១-២០០៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | |
| ពោត (US No. 2) - US ($/តោន) | 81.18 | 89.98 | 95.42 | 110.65 | 90.64 | 95.37 | 99.95 | 108.67 | 140.18 | 89.19 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 259.13 | 353.91 | 402.03 | 427.47 | 391.52 | 395.75 | 397.87 | 446.85 | 494.92 | 381.32 |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 160.81 | 178.59 | 182.22 | 221.67 | 259.40 | 275.12 | 283.86 | 289.91 | 279.10 | 262.88 |
| សណ្តែកសៀង (US No. 1) – US ($/តោន) | 163.89 | 182.58 | 218.86 | 262.03 | 210.42 | 210.96 | 207.02 | 207.38 | 230.17 | 224.25 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 22.8 | 23.9 | 26.8 | 33.5 | 52.99 | 57.89 | 65.03 | 67.00 | 56.39 | 50.14 |
| សាំង – US Gulf coast (សេន/លីត្រ) | 19.5 | 19.1 | 23 | 30.9 | 42.29 | 41.18 | 55.89 | 52.70 | 41.02 | 42.19 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) – US Gulf coast (សេន/លីត្រ) | 18.72 | 17.85 | 21.63 | 29.48 | 49.90 | 47.72 | 55.89 | 55.66 | 46.11 | 44.35 |

*Sources: Food and Agriculture Organisation and US Energy Information Administration.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៤ ឆ្នាំ២០០៦ គំរោងវិនិយោគបានអនុម័ត និងវិស័យទេសចរណ៍ បានកើនឡើង ប៉ុន្តែគំរោងសាងសង់ និងជញ្ជីងពាណិជ្ជកម្ម បានធ្លាក់ចុះ ធៀបនឹងត្រីមាសមុន ។ កំណើនវិនិយោគ និងវិស័យទេសចរណ៍ នឹងផ្តល់កំណើនបន្ថែម ហើយបង្កើតឱកាសការងារកាន់តែច្រើន ប៉ុន្តែការធ្លាក់ចុះសកម្មភាពសាងសង់ នឹងប៉ះពាល់អវិជ្ជមានទៅលើកំណើននេះ ។

នៅត្រីមាសទី៤ ២០០៦ គំរោងវិនិយោគឯកជនគិតជាទ្រព្យសកម្មជាប់លាប់បានអនុម័ត កើនឡើងខ្លាំង ជិតបួនដងនៃត្រីមាសមុន ដល់ ៩៧១,៩លានដុល្លារ ។ កត្តាដែលបង្កកំណើននេះ គឺគំរោងអនុម័តក្នុងវិស័យសេវាកម្ម និងកសិកម្ម ។ គំរោងអនុម័តក្នុងវិស័យសេវាកម្មកើនដល់ ៧៤០,៧លានដុល្លារ រឺជិតស្មើ ៨ដងនៃត្រីមាសមុន គំរោងអនុម័តខាងវិស័យសាងសង់មាន ៣៦៩,៣លានដុល្លារ ខាងទេសចរណ៍ ៣១៥,៣លានដុល្លារ និងសេវាកម្មដទៃទៀត ៥៦,១លានដុល្លារ ។ គំរោងអនុមតិក្នុងវិស័យកសិកម្ម កើនពីករិតសូន្យនៅត្រីមាសទី៣ ដល់ ១៥៤,៦លានដុល្លារ រីឯគំរោងអនុម័តក្នុងវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៥៥% មកត្រឹម ៧៦,៦លានដុល្លារ នៅត្រីមាសទី៤ ២០០៦ ប៉ុន្តែខាងផ្នែកកាត់ដេរ វាកើន ១២% ដល់ ២៦,១លានដុល្លារ ។ សរុបមកមាន ២២គំរោងវិនិយោគឯកជនត្រូវបានអនុម័ត ហើយគេរំពឹងថានឹងត្រូវការពលករប្រមាណ ៥៧.៨៨៧នាក់ ដែលក្នុងនេះ វិស័យកសិកម្មត្រូវការ ៣៦.៧៥៤នាក់ សំរាប់ ៧គំរោង ឧស្សាហកម្មត្រូវការ ១៣.៩១៥នាក់ សំរាប់ ១១គំរោង និងសេវាកម្មត្រូវការ ៧.២១៨នាក់ សំរាប់ ៤គំរោង ។

ការទទួលបានលក្ខខណ្ឌអនុគ្រោះបំផុតខាងពាណិជ្ជកម្ម (MFN) និងការគោរពស្តង់ដារអង្គការពលកម្មអន្តរជាតិ គឺជាចំណុចវិជ្ជមានសំរាប់ឱ្យកម្ពុជាទាក់ទាញវិនិយោគិន ពីព្រោះវាផ្តល់លទ្ធភាពឱ្យទទួលបានទុនវិនិយោគ និងឱកាសនាំចេញច្រើនថែមទៀត ។

នៅត្រីមាសទី៤ ២០០៦ ការអនុមតិគំរោងសាងសង់នៅភ្នំពេញ ថយចុះ ១៨% ធៀបនឹងត្រីមាសមុន មកត្រឹម ៧៨,១លានដុល្លារ ។ ផ្ទះល្វែង និងសំណង់ដទៃទៀត ធ្លាក់ចុះ ១៩% មកត្រឹម ៥៤,៥លានដុល្លារ និង ៣៣% មកត្រឹម ១៣,៩លានដុល្លារ រីឯសំណង់ភូមិគ្រឹះនិងផ្ទះ កើន ២៨% ដល់ ៩,៧លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៥ អនុមតិគំរោងសាងសង់ កើន ៨,៨% ដោយក្នុងនេះ សំណង់ផ្ទះល្វែងកើន ២១% ហើយភូមិគ្រឹះនិងផ្ទះ កើន ៨០% ។ នៅពេញមួយឆ្នាំ២០០៦ អនុមតិគំរោងសាងសង់ មាន ៥២៤,៨លានដុល្លារ រឺកើន ៤៦% ធៀបនឹងឆ្នាំមុន ។ សំណង់ផ្ទះល្វែងមាន ១៦៨,៥លានដុល្លារ រឺស្មើនឹង ៣២% នៃអនុមតិគំរោងសាងសង់សរុប រីឯភូមិគ្រឹះនិងផ្ទះមាន ៣៣,១លានដុល្លារ រឺ ៦,៣% នៃសំណង់ទាំងអស់ ។

នៅត្រីមាសទី៤ ឆ្នាំ២០០៦ ជញ្ជីងពាណិជ្ជកម្មកម្ពុជា មានឱនភាព ៧០,៤លានដុល្លារ បន្ទាប់ពីមានអតិរេក ២៣,២លានដុល្លារ នៅត្រីមាសមុន ។ ការនាំចេញសរុបធ្លាក់ចុះ រីឯការនាំចូលសរុបបានបន្តកើនឡើងជាច្រើនត្រីមាសមកហើយ ។ នៅត្រីមាសទី៤ ការនាំចេញរបស់កម្ពុជា ធ្លាក់ចុះ ៨,៨% ធៀបនឹងត្រីមាសមុន មកត្រឹម ៧៣៦,៧លានដុល្លារ ។ តាមធម្មតា ការនាំចេញតែងធ្លាក់ចុះនៅត្រីមាសទី៤ ជាពិសេសការនាំចេញផលិតផលកាត់ដេរ ពីព្រោះវាជាប់ទាក់ទងនឹងរដូវកាលទិញឥវ៉ាន់នៅឯប្រទេសភាគខាងជើង ។ ដូច្នេះការធ្លាក់ចុះនេះ វាដើរតាមលំនាំធម្មតាទេ ។ ការនាំចេញក្នុងវិស័យកាត់ដេរ ធ្លាក់ចុះ ៨,៤% មកត្រឹម ៧១៦,០លានដុល្លារ ក្នុងនេះការនាំចេញសំលៀកបំពាក់ធ្លាក់ចុះ ៨,៤% មកត្រឹម ៦៩៥,០លានដុល្លារ ស្បែកជើងធ្លាក់ចុះ ៨,៥% មកត្រឹម ១៧,៣លានដុល្លារ ហើយវាយនភ័ណ្ឌឯទៀតធ្លាក់ចុះ ១៧,៨% មកត្រឹម ៣,៧លានដុល្លារ ។ ការនាំចេញក្នុងវិស័យកសិកម្ម ក៏ធ្លាក់ចុះអស់ ១៩% ដែរ មកត្រឹម ២០,៧លានដុល្លារ ។ ការនាំចេញត្រី ធ្លាក់ចុះ ១៣% មកត្រឹម ១,៤លានដុល្លារ កៅស៊ូ ២៥% មកត្រឹម ១០,២លានដុល្លារ និងឈើ ៣២% មកត្រឹម ១,៧លានដុល្លារ រីឯការនាំចេញអង្ករ កើនពីករិតសូន្យនៅត្រីមាសមុន ដល់ ០,៨លានដុល្លារ ។ ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០០៥ ការនាំចេញសរុប កើន ១៤% ។

នៅត្រីមាសទី៤ ២០០៦ ការនាំចូលកើន ២,៩% ដល់ ៨០៧,១លានដុល្លារ ។ ការនាំចូលសំភារៈសំណង់ ថយចុះ ១៦% ធៀបនឹងត្រីមាសមុន មកត្រឹម ៣៥,៨លានដុល្លារ ក្នុងនេះ ការនាំចូលស៊ីម៉ង់ត៍ និងដែក ធ្លាក់ចុះ ១៣% មកត្រឹម ១៣,៨លានដុល្លារ និង ៣០% មកត្រឹម ១២,៦លានដុល្លារ រីឯការនាំចូលបរិក្ខារសំណង់ កើន ១១% ដល់ ៩,៤លានដុល្លារ ។ ការនាំចូលសាំងកើនបន្តិចបាន ០,៨% ដល់ ១៣,២លានដុល្លារ (៤២.៣១០តោន) រីឯការនាំចូលម៉ាស៊ូត ធ្លាក់ចុះ ៩,៦% មកត្រឹម ២៧,២លានដុល្លារ (៩៥.៧០០តោន) ។

នៅត្រីមាសទី៤ ២០០៦ ភ្ញៀវបរទេសសរុបមកដល់កម្ពុជា កើន ៣៩% ធៀបនឹងត្រីមាសមុន ដល់ ៥១៦.០៩៩នាក់ ។ ភ្ញៀវមកដល់តាមផ្លូវគោកនិងផ្លូវទឹក កើន ៣០% ដល់ ១៩១.០០៥នាក់ ហើយភ្ញៀវមកដល់តាមផ្លូវអាកាសកើន ៤៥% ដល់ ៣២៥.០២៤នាក់ ក្នុងនោះអាកាសយានដ្ឋានភ្នំពេញទទួលបាន ១២៩.៧៨៧នាក់ ។ ភ្ញៀវមកសំរាកលំហែ កើន ៣២% ដល់ ៤២៥.០៨៩នាក់ ហើយភ្ញៀវចូលដោយកិច្ចការជំនួញ ធ្លាក់ចុះ ២,៩% មកត្រឹម ៣២.៧២៩នាក់ ។ ធៀបនឹងត្រីមាសទី៤ ២០០៥ ចំនួនភ្ញៀវចូលសរុប កើន ២៤% ក្នុងនោះភ្ញៀវមកតាមផ្លូវអាកាសកើន ២៩% ហើយតាមផ្លូវគោកនិងផ្លូវទឹក កើន ១៦% ។ ភ្ញៀវមកសំរាកលំហែ កើនឡើង ២២% ។ នៅឆ្នាំ២០០៦ ភ្ញៀវមកដល់កម្ពុជាមានសរុប ១.៧០៥.៩៨៩នាក់ រឺកើន ២១% ធៀបនឹងឆ្នាំមុន ។ ភ្ញៀវទេសចរមកដល់ខេត្តសៀមរាប កើន ២៤% ដល់ ៨៥៦.៥១០នាក់ ។ ជាលទ្ធផល មានការសាងសង់សណ្ឋាគារជាច្រើននៅកម្ពុជា ។ នៅឆ្នាំ២០០៦ សណ្ឋាគារមានទាំងអស់ ៣៥១ រឺកើនឡើង ១១% ធៀបនឹងឆ្នាំមុន ។

## ហិរញ្ញវត្ថុសាធារណៈ

ថវិការដ្ឋាភិបាលនៅត្រីមាសទី៤ មានអតិរេក ១២០,៧ពាន់លានរៀល ធៀបនឹងឱនភាព ១៩១,៩ពាន់លានរៀល នៅត្រីមាសមុន ។ ចំណូល និងចំណាយថវិកាកើនឡើងយ៉ាងខ្លាំង ហើយចំណូលដ៏ច្រើននោះ អាចទូទាត់ចំណាយរដ្ឋាភិបាលបានទាំងអស់នៅត្រីមាសទី៤ ។ ក្នុងអំឡុងពេលនោះ ការប្រមូលចំណូលសរុប កើន ៦៤% ធៀបនឹងត្រីមាសមុន ដល់ ១១៩៩,២ពាន់លានរៀល ។ ការប្រមូលពន្ធ គឺជាប្រភពចំបងដែលបង្កើនចំណូលចរន្តបាន ១៨% ដល់ ៨៤៤,៤ពាន់លានរៀល ។ អាករលើតំលៃបន្ថែម កើនឡើង ១៣% ដល់ ២៤៤,៦ពាន់លានរៀល អាករពិសេស កើន ២២% ដល់ ១២៥,៩ពាន់លានរៀល និងពន្ធគយ កើន ២៧% ដល់ ២០០,០ពាន់លានរៀល ហើយទាំងអស់នេះធ្វើអោយចំណូលពន្ធសរុបកើន ១៧% ដល់ ៦៦១,៣ពាន់លានរៀល ។ នៅត្រីមាសទី៤ ការប្រមូលចំណូលមិនមែនពន្ធ កើន ២១% ដល់ ១៨៣,១ពាន់លានរៀល ក្នុងនេះ ទាំងអាជីវកម្មព្រៃឈើ ប្រៃសណីយ៍និង

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ទូរគមនាគមន៍ កើនឡើងមួយជាបី ដល់ ០,៩ពាន់លានរៀល និង ៣០,០ពាន់លានរៀល រីឯចំណូលពីវិស័យទេសចរណ៍ កើន ១៤% ដល់ ១៤,១ពាន់លានរៀល ។ ចំណូលមូលធន កើន ១០% ដល់ ៣៤៩,៨ពាន់លានរៀល រីឯចំណូលពីឯកជនភាវូបនីយកម្ម ធ្លាក់ចុះ ៣៩% មកត្រឹម ៩,៤ពាន់លានរៀល ។ ធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០០៥ ចំណូលថវិកាកើន ៤៥% ក្នុងនេះ ចំណូលពន្ធ និងមិនមែនពន្ធ កើន ១៩% និង ២៤% រីឯចំណូលមូលធន កើនឡើងជិតមួយជាបី ។

ចំណាយថវិកា កើន ១៧% ដល់ ១០៧៨,៤ពាន់លានរៀល ធៀបនឹងត្រីមាសមុន ។ ចំណាយចរន្តកើន ២០% ដល់ ៧២៨,៧ពាន់លានរៀល ក្នុងនេះ ចំណាយលើរដ្ឋបាលសេដ្ឋកិច្ច កើន ៩,៥% ដល់ ១៧០,១ពាន់លានរៀល រដ្ឋបាលទូទៅ កើន ១៣% ដល់ ១៣៤,៩ពាន់លានរៀល និង សន្តិសុខនិងការពារជាតិ កើន ៤៧% ដល់ ៩២,០ពាន់លានរៀល រីឯចំណាយលើការអប់រំ និងសុខាភិបាល កើនមួយជាពីរ ដល់ ២៨១,៣ពាន់លានរៀល ។ នៅត្រីមាសទី៤ ចំណាយលើបៀវត្សរ៍មន្ត្រីរាជការ មាន ២៤០,៧ពាន់លានរៀល រឺ កើន ៤,០% ធៀបនឹងត្រីមាសមុន ។ ក្នុងពេលជាមួយគ្នា ចំណាយមូលធន ធ្លាក់ចុះ ១០% មកត្រឹម ៣៤៩,៨ពាន់លានរៀល ក្នុងនេះ ៣២% ជាថវិកាក្នុងស្រុក និង ៦៨% ជាថវិកាក្រៅស្រុក ។

## អតិផរណា និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី៤ ថ្លៃទំនិញទូទៅ នៅភ្នំពេញ ធ្លាក់ចុះ ០,៣% ធៀបនឹងត្រីមាសមុន ក្នុងនេះ ថ្លៃម្ហូបអាហារ ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ ធ្លាក់ចុះ ០,៩% និង ០,៧% រីឯថ្លៃសំលៀកបំពាក់ ការថែទាំសុខភាព និងការអប់រំ កើន ០,៨% ០,២% និង ០,៤% ។ ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៥ ថ្លៃទំនិញប្រើប្រាស់ កើន ៣,៤% ដោយថ្លៃអប់រំ កើន ១,៣% ថែទាំសុខភាព កើន ២,២% ម្ហូបអាហារ ៣,៣% និងដឹកជញ្ជូន ៦,៨% ។ បន្ទាប់ពីមានការធ្លាក់ចុះថ្លៃប្រេងឆៅលើពិភពលោក ថ្លៃប្រេងសាំងមានផលប៉ះពាល់តិចជាងមុនលើការប្រែប្រួលថ្លៃទំនិញទូទៅ ហើយការឡើងថ្លៃម្ហូបអាហារ ជាពិសេសសាច់ជ្រូក គោ មាន់ និងទា ជាកត្តាចំបងដែលធ្វើអោយថ្លៃទំនិញទូទៅនៅភ្នំពេញកើនឡើងក្នុងមួយឆ្នាំកន្លងទៅ ។

ទល់នឹងដុល្លារUS ប្រាក់រៀលប្ដូរបាន ៤១២៩,៤រៀល/ដុល្លារ រឺឡើងថ្លៃ ០,៤% ធៀបនឹងត្រីមាសមុន និង ០,៦% ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ។ ប្រាក់រៀលធ្លាក់ថ្លៃ ២,៤% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែទល់នឹងប្រាក់ដុងវៀតណាម វានៅរក្សាថ្លៃដដែល ធៀបនឹងត្រីមាសមុន ដោយប្ដូរបាន ២៤,៩រៀល/១០០ដុង ។ ធៀបនឹងត្រីមាសទី៤ ២០០៥ ប្រាក់រៀលធ្លាក់ថ្លៃ ១១% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែឡើងថ្លៃ ៤,៦% ទល់នឹងប្រាក់ដុងវៀតណាម ។

## ការវិវត្តន៍រូបិយវត្ថុ

នៅត្រីមាសទី៤ ឆ្នាំ២០០៦ រូបិយវត្ថុទូទៅ (M2) កើន ៧,៤% ដល់ ៦៩៤២,៣ពាន់លានរៀល ។ ធាតុផ្សំនៃរូបិយវត្ថុទូទៅ គឺរូបិយវត្ថុក្រៅធនាគារ និងបញ្ញើក្នុងធនាគារ ។ រូបិយវត្ថុក្នុងស្រុកក្រៅធនាគារ កើន ៥,៨% ដល់ ១៥៩៩,៦ពាន់លានរៀល ប្រាក់រៀលក្នុងធនាគារ កើន ១,៩% ដល់ ១៤៦,៧ពាន់លានរៀល និងរូបិយវត្ថុបរទេសក្នុងធនាគារ កើន ៨,១% ដល់ ៥១៩៦,០ពាន់លានរៀល ។ ធៀបនឹងពេលដូចគ្នា ឆ្នាំ២០០៥ រូបិយវត្ថុទូទៅ កើន ៣៨% ក្នុងនេះ រូបិយវត្ថុក្រៅធនាគារ និងរូបិយវត្ថុបរទេសក្នុងធនាគារ កើន ២៥% នឹង ៤៥% ប៉ុន្តែប្រាក់រៀលក្នុងធនាគារ ធ្លាក់ចុះ ៤,៣% ។ ទ្រព្យសកម្មនៃប្រព័ន្ធរូបិយវត្ថុ គឺជាប្រភពចំបងនៃរូបិយវត្ថុទូទៅ ។ នៅត្រីមាសទី៤ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ៤៣% ធៀបនឹងត្រីមាសមុន ដល់ ២៨២,០ពាន់លានរៀល ហើយទ្រព្យសកម្មបរទេសសុទ្ធ កើន ៣,៨% ដល់ ៧២២៤,៣ពាន់លានរៀល ។ ឥណទានក្នុងស្រុក ដែលជាចំណែកមួយនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ១២% ដល់ ២៦៧៦,៥ពាន់លានរៀល ក្នុងនោះឥណទេយ្យលើរដ្ឋាភិបាល កើន ៥,៩% ដល់ ២៨៦,៦ពាន់លានរៀល បញ្ញើរដ្ឋាភិបាលកើន ៦,៧% ដល់ ១២៤០,០ពាន់លានរៀល ហើយឥណទានវិស័យឯកជនកើន ១០% ដល់ ៣៦២៩,៨ពាន់លានរៀល ។ ចំពោះទ្រព្យសកម្មផ្សេងៗទៀត វាមានតំលៃអវិជ្ជមាន ២៩៥៨,៥ពាន់លានរៀល (បំណុល) ពោលគឺបានប្រែប្រួលកាន់តែធ្ងន់ធ្ងរ ២,២% ធៀបនឹងត្រីមាសមុន ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

នៅខែកុម្ភៈ ឆ្នាំ២០០៧ ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះទាំង ១០ក្រុម បានធ្លាក់ចុះជាមធ្យម ៥% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ក្នុងនោះចំណូលរបស់អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នកលក់បន្លែតូចតាច អ្នករើសអេតចាយ អ្នកបំរើតាមភោជនីយដ្ឋាន កម្មករសំណង់មានជំនាញនិងគ្មានជំនាញ ធ្លាក់ចុះ ហើយចំណូលរបស់ពីរក្រុមទៀតគឺ កម្មករកាត់ដេរ និងអ្នករត់ម៉ូតូឌុប កើនឡើង រីឯចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែនៅដដែល ។

នៅខែកុម្ភៈ ២០០៧ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ និងគ្មានជំនាញ ធ្លាក់ចុះ ១៤% និង ១៥% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ដោយសារចំនួនកម្មករសំណង់មានជំនាញនិងគ្មានជំនាញ កើនឡើង ។ ពួកគេមួយចំនួនបានចាកចេញពីជនបទជាមួយក្រុមគ្រួសារមកភ្នំពេញ ដោយសារជីវភាពខ្វះខាត ។ នៅពេលធ្វើអង្កេត មានកម្មករសំណង់មានជំនាញ ៥២% និងគ្មានជំនាញ ៣២% រាយការណ៍ថា ជីវភាពគ្រួសារខ្លួនបានគ្រាន់បើជាងមុនក្រោយពេលបានមកធ្វើកម្មករនៅទីក្រុង ។

ចំណូលអ្នកធាក់ស៊ីក្លូ ធ្លាក់ចុះ ១៧% ពី ៧៨៨៣រៀល នៅខែកុម្ភៈ ២០០៦ មកត្រឹម ៦៥៣៤រៀល នៅខែកុម្ភៈ ២០០៧ ដោយសារមានការប្រកួតប្រជែងពីមធ្យោបាយដឹកជញ្ជូនផ្សេងទៀត ដូចជាកំណើនម៉ូតូទុកទុក និងម៉ូតូឌុប ។ អ្នកធាក់ស៊ីក្លូភាគច្រើន ធ្វើការ១១ម៉ោង/ថ្ងៃ និងប្រហែល ២៥ថ្ងៃ/ខែ ហើយចំណាយប្រហែល ៤០០០រៀល/ថ្ងៃ សំរាប់អាហារ ។ អង្កេតបង្ហាញថា អ្នកធាក់ស៊ីក្លូ ៥៨% មិនជួលកន្លែងស្នាក់នៅទេ ពីព្រោះពួកគេស្នាក់នៅផ្ទះថៅកែស៊ីក្លូ ហើយពួកគេបង់ ២០០០រៀល/ថ្ងៃ លើថ្លៃជួលស៊ីក្លូ ។ អ្នកធាក់ស៊ីក្លូ ៣០% ស្នាក់នៅតាមវត្ត ១០% ជួលកន្លែងស្នាក់នៅ និង ២,៥% រស់នៅជាមួយសាច់ញាតិ ។

នៅខែកុម្ភៈ ឆ្នាំ២០០៧ ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ គឺ ៤៥៣០រៀល រឺធ្លាក់ចុះ ៩% ធៀបនឹងពេលដូចគ្នាឆ្នាំមុន ដោយសារកំណើនចំនួនអ្នករើសអេតចាយ ដែលភាគច្រើនមកពីតំបន់ជនបទ ។ អ្នករើសអេតចាយ ៩៥% និយាយថា ចំណូលបានពីការរើសអេតចាយ គឺសំរាប់ទ្រទ្រង់ជីវភាពគ្រួសារ ។ ជាទូទៅ អ្នករើសអេតចាយចំណាយប្រហែល ២០០០រៀល/ថ្ងៃ សំរាប់អាហារ និងត្រូវធ្វើការ ១១ម៉ោង/ថ្ងៃ ដើម្បីចិញ្ចឹមជីវិត ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

នៅខែកុម្ភៈ ២០០៧ អ្នកលក់បន្លែតូចតាច មានចំណូលប្រចាំថ្ងៃប្រហាក់ប្រហែលនឹងកាលពីខែកុម្ភៈ ឆ្នាំមុនដែរ (តារាង ៨) ។ អ្នកលក់បន្លែតូចតាច ៤៧% និយាយថា ចំណូលបានកើនឡើង រីឯ ៤២% រាយការណ៍ពីការធ្លាក់ចុះចំណូល ហើយ ១០% ថាមានចំណូលនៅដដែល ។ អ្នកលក់បន្លែតូចតាចត្រូវការដើមទុន ២០ដុល្លារ សំរាប់ធ្វើអាជីវកម្មប្រចាំថ្ងៃ ហើយពួកគេ ៦៥% មកពីខេត្តនានានៅក្រៅក្រុងភ្នំពេញ ។ អ្នកលក់បន្លែតូចតាច ៦០% បានចូលរៀន តែមិនទាន់បញ្ចប់បឋមសិក្សាទេ ១០% បានចូលអនុវិទ្យាល័យ និង ៣០% ទៀតមិនដែលបានចូលសាលារៀនសោះ ។

អង្កេតលើអ្នកបំរើតាមភោជនីយដ្ឋាន នៅខែកុម្ភៈ ឆ្នាំ២០០៧ បង្ហាញថា ចំណូលប្រចាំថ្ងៃរបស់ពួកគេ ធ្លាក់ចុះ ១៣% ធៀបនឹងខែកុម្ភៈ ឆ្នាំ២០០៦ ដោយសារអ្នកបំរើមួយចំនួនមិនមានការងារទៀងទាត់ ។ ប៉ុន្តែមាន ៦៥% បានឱ្យដឹងថា ជីវភាពគ្រួសារពួកគេបានប្រសើរឡើង ពីព្រោះពួកគេបានផ្ដល់បៀវត្សរ៍ខ្លះទៅជួយឧបត្ថម្ភគ្រួសារ ។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូឌុបនៅខែកុម្ភៈ កើន ៣% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ដល់ ៩១៤៤រៀល ដោយសារសាំងបានចុះថ្លៃ ហើយអង្កេតនេះបានគ្របដណ្ដប់លើអំឡុងពេលចូលឆ្នាំចិន ។ អ្នករត់ម៉ូតូឌុប ៩០% រាយការណ៍ថា ចំណូលរកបានមិនអាចផ្គត់ផ្គង់គ្រួសារទាំងមូលទេ ពីព្រោះពួកគេត្រូវចំណាយលើអាហារអស់ ៤៥០០រៀល/ថ្ងៃ ។

នៅខែកុម្ភៈ ឆ្នាំ២០០៧ កម្មករកាត់ដេររកចំណូលបានជាមធ្យម ១១.១៤៦រៀល/ថ្ងៃ រីកើនឡើង ២១% ធៀបនឹងខែកុម្ភៈ ឆ្នាំ២០០៦ ។ នេះជារបាយការណ៍ចំណូលខ្ពស់បំផុត ចាប់តាំងពីការធ្វើអង្កេតដំបូងនៅឆ្នាំ២០០០ ដែលបណ្ដាលមកពីកំណើនការងារក្នុងរោងចក្រ ហើយក្នុងនេះអ្នកឆ្លើយសំណួរ ៧៣% ប្រាប់ថា បានធ្វើការលើសពី ៦០ម៉ោង/សប្ដាហ៍ ។ កម្មករកាត់ដេរ ៦៤% យល់ថា រោងចក្រនឹងបន្តដំណើរការយូរឆ្នាំទៅមុខទៀត ។ ម្យ៉ាងទៀតមានតែកម្មករ ៣២% ប៉ុណ្ណោះដែលអាចសន្សំប្រាក់សំរាប់បង្កើតអាជីវកម្មផ្ទាល់ខ្លួន ក្រោយពេលឈប់ធ្វើការនៅរោងចក្រ ហើយ ៥៣% បាននិយាយថា ចំណូលរបស់ខ្លួនមិនអាចលែលកសន្សំទុកបានឡើយ និង ១៥% មិនអាចបញ្ជាក់បាន ។ ជាទូទៅ កម្មករកាត់ដេរចំណាយប្រហែល ២៩០០រៀល សំរាប់អាហារប្រចាំថ្ងៃ ហើយចំណាយសរុបក្នុងមួយខែគឺ ១៥០.០០០រៀល ។

ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែ ស្ថិតនៅដដែលត្រឹម ៤១២៦រៀល ។ ពលករ ៧២% បានរាយការណ៍ថា ចំណូលរបស់ខ្លួនគ្រាន់តែជាចំណែកតូចមួយនៃចំណូលគ្រួសារប៉ុណ្ណោះ ពីព្រោះការងារនេះមិននឹងនរទេ ។ ម្យ៉ាងវិញទៀត អ្នកស៊ីឈ្នួលធ្វើស្រែ ៣២% បាននិយាយថា ជីវភាពគ្រួសារបានប្រសើរឡើង ហើយ ៣៨% ប្រាប់ថា នៅដដែល និង ៣០% ទៀតថា ជីវភាពរបស់ពួកគេបានស្រុតចុះ ។ អ្នកស៊ីឈ្នួលធ្វើស្រែ ៤៨% មិនធ្លាប់ចូលសាលារៀនទេ ហើយ ៥២% ទៀត បានរៀនត្រឹមបឋមសិក្សាប៉ុណ្ណោះ ។

*រៀបរៀងដោយ*
*ប៊ុន ដូរីណា និង ផាន់ ដាលីស*


## Cambodia Development Review—2007 Subscription Rates

**Domestic Subscription (Individual)**

☐ English edition ($14) ☐ Khmer edition (5,000 riels) Payment by ☐ cash or ☐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

☐ English edition ($60 for five copies) ☐ Khmer edition (20,000 riels for five copies) Payment by ☐ cash or ☐ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

☐ Thailand, Laos, Vietnam ☐ English edition ($25)* ☐ Khmer edition ($15)*
☐ Asia and Europe ☐ English edition ($30)* ☐ Khmer edition ($20)*
☐ Americas and Africa ☐ English edition ($35)* ☐ Khmer edition ($25)*

* Subscription includes postage. Payment by ☐ cash (in Phnom Penh) or ☐ cheque (please add $25 to cover bank charges for processing US dollar cheques). At present CDRI can accept payment from overseas only by US-dollar denominated cheque or bankers draft. Total payment enclosed ..........

Title: ☐Mr ☐Ms ☐Dr ☐Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ☐ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Please make cheques payable to the Cambodia Development Resource Institute. Do not send cash through the post.
Please inform the Publications Section at CDRI if your contact details change.

## តារាង ១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q4 | 2006 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 51.6 | 63.9 | 9.8 | 0.4 | 40.3 | 3.7 | 12.3 | 9.1 | 126.5 | 216.9 | 0.0 | 154.6 |
| ឧស្សាហកម្ម | 650.5 | 162.6 | 109.4 | 105.2 | 67.7 | 137.2 | 189.2 | 82.0 | 40.1 | 76.9 | 171.7 | 76.6 |
| កាត់ដេរ | *126.5* | *67.7* | *81.5* | *26.5* | *27.2* | *68.1* | *133.9* | 27.3 | 30.5 | 9.6 | 23.2 | 26.1 |
| សេវាកម្ម | 154.7 | 222.6 | 150.1 | 118.4 | 145.3 | 168.4 | 92.0 | 28.1 | 60.7 | 2,043.2 | 94.5 | 740.7 |
| សណ្ឋាគារ និងទេសចរណ៍ | *112.0* | *171.8* | *79.8* | *73.8* | *47.1* | *124.1* | *55.9* | 22.6 | 0.0 | 26.2 | 3.5 | 315.3 |
| សរុប | 856.8 | 449.1 | 269.2 | 224.0 | 253.3 | 309.3 | 293.5 | 119.2 | 227.3 | 2,337.0 | 266.2 | 971.9 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -70.5 | 90.7 | 928.1 | -88.6 | 265.1 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 15.0 | -47.6 | -40.0 | -19.5 | 10.5 | 31.1 | -12.4 | 628.1 | -52.2 | 2331.2 | -34.1 | 715.4 |

*Including expansion project approvals. Up to June 2006. Source: Cambodian Investment Board*

## តារាង ២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q4 | 2006 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 21.2 | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 30.3 | 5.4 | 10.1 | 5.7 | 7.6 | 9.7 |
| ផ្ទះល្វែង | 227.3 | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 167.6 | 45.1 | 39.9 | 51.8 | 67.1 | 54.5 |
| ផ្សេងៗ | 27.0 | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 65.6 | 21.3 | 17.4 | 24.7 | 20.8 | 13.9 |
| សរុប | 275.4 | 326.8 | 205.4 | 196.2 | 219.8 | 198.9 | 263.4 | 71.8 | 67.4 | 82.2 | 95.5 | 78.1 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -6.1 | -6.2 | 22.2 | 16.1 | -18.1 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 6.9 | 18.7 | -37.2 | -4.5 | 12.0 | -9.5 | 32.5 | 12.0 | -36.5 | -21.2 | 24.8 | 8.9 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង ៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q4 | 2006 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 784.4 | 941.1 | 1056.2 | 1268.2 | 1453.2 | 1708.1 | 2108.1 | 644.8 | 603.2 | 652.5 | 807.5 | 736.7 |
| រួមមានៈ សំលៀកបំពាក់ | 378.0 | 554.0 | 962.1 | 1202.2 | 1355.8 | 1628.4 | 2027.0 | 601.0 | 568.5 | 632.4 | 782.0 | 716.0 |
| - ទៅសហរដ្ឋអាមេរិក | 74.1 | 486.0 | 714.1 | 840.9 | 943.4 | 1099.8 | 1270.9 | 408.1 | 402.5 | 438.6 | 522.8 | 483.2 |
| - ទៅសហភាពអ៊ឺរ៉ុប | - | - | 228.1 | 323.3 | 356.3 | 414.7 | 590.8 | 145.3 | 110.6 | 142.2 | 188.1 | 160.1 |
| - ប្រទេសផ្សេងទៀត | 82.0 | 68.0 | 19.9 | 38.0 | 56.1 | 113.8 | 165.3 | 47.5 | 55.3 | 51.6 | 71.0 | 72.8 |
| កសិកម្ម | - | - | 94.2 | 66.0 | 97.3 | 79.7 | 81.2 | 43.8 | 34.7 | 20.2 | 25.5 | 20.7 |
| - កៅស៊ូ | - | - | 29.6 | 25.9 | 29.7 | 35.1 | 38.3 | 13.4 | 7.8 | 9.8 | 13.6 | 10.2 |
| - ឈើ | - | - | 32.9 | 22.3 | 16.0 | 10.2 | 11.1 | 2.0 | 2.1 | 2.3 | 2.5 | 1.7 |
| - ត្រី | - | - | 5.4 | 6.0 | 4.3 | 2.8 | 10.6 | 6.6 | 1.9 | 1.0 | 1.6 | 1.4 |
| - ផ្សេងៗ | - | - | 26.2 | 11.8 | 47.4 | 31.6 | 21.3 | 21.9 | 22.9 | 7.0 | 7.7 | 7.5 |
| ការនាំចូលសរុប | 1112.2 | 1237.4 | 1417.7 | 1501.4 | 1707.8* | 1824.9 | 2149.0 | 691.1 | 690.7 | 774.9 | 784.3 | 807.1 |
| រួមមានៈ - សាំង | - | - | - | - | 25.9 | 33.2 | 30.2 | 10.7 | 10.9 | 12.4 | 13.1 | 13.2 |
| - ម៉ាស៊ូត | - | - | - | - | 100.8 | 109.6 | 109.4 | 21.1 | 32.5 | 32.2 | 30.1 | 27.2 |
| - សំភារៈសំណង់ | - | - | - | - | 12.9 | 80.8 | 95.3 | 26.2 | 37.0 | 39.1 | 42.5 | 35.8 |
| - ផ្សេងៗ | - | - | - | - | 1568.2 | 1601.3 | 1914.0 | 633.1 | 610.3 | 691.2 | 698.5 | 731.0 |
| ជញ្ជីងពាណិជ្ជកម្ម | -327.8 | -296.3 | -361.5 | -233.2 | -254.6 | -116.8 | -40.9 | -46.3 | -87.5 | -122.4 | 23.2 | -70.4 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | - | -15.3 | -5.4 | 11.2 | 23.7 | -8.4 |
| ការនាំចេញសរុប | - | - | - | - | - | - | - | -11.7 | -6.4 | 8.2 | 23.7 | -8.8 |
| ការនាំចូលសរុប | - | - | - | - | - | - | - | 9.3 | -0.03 | 12.2 | 1.2 | 5.9 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 66.4 | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 24.5 | 15.5 | 27.8 | 27.1 | 10.2 | 19.1 |
| ការនាំចេញសរុប | 59.0 | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 23.4 | 18.3 | 30.3 | 26.7 | 10.6 | 14.3 |
| ការនាំចូលសរុប | 1.6 | 11.3 | 14.6 | 5.9 | 13.7 | 6.9 | 17.8 | 26.1 | 32.6 | 15.6 | 24.3 | 16.8 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF.*

## តារាង ៤. ចំនួនភ្ញៀវបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ១៩៩៨-២០០៦

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q4 | 2006 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ភ្ញៀវពាន់នាក់ | | | | | | | | | | | |
| តាមផ្លូវអាកាស | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 626.1 | 251.5 | 275.4 | 204.4 | 224.2 | 325.0 |
| តាមផ្លូវគោក និងទឹក | 100.2 | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 428.9 | 164.5 | 181.9 | 153.6 | 146.4 | 191.0 |
| សរុប | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 701.1 | 1055.0 | 416.0 | 457.3 | 358.0 | 370.6 | 516.0 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 28.7 | 9.9 | -21.7 | 4.1 | 39.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 9.8 | 20.2 | 21.2 | 14.7 | 24.1 |

*Source: Ministry of Tourism*

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៨-២០០៦ (ពាន់លានរៀល)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q4 | 2006 Q1* | Q2* | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 920 | 1326 | 1528 | 1529 | 1744 | 1765 | 2127 | 827.9 | 595.9 | 731.5 | 732.2 | 1,199.2 |
| ចំណូលចរន្ត | - | - | - | 1521 | 1728 | 1733 | 2107 | 701.6 | 593.2 | 726.9 | 716.8 | 844.4 |
| ចំណូលពន្ធ | 676 | 956 | 1096 | 1096 | 1227 | 1220 | 1577 | 553.8 | 484.7 | 558.6 | 565.8 | 661.3 |
| ពន្ធគយ | 376 | 432 | 376 | 376 | 424 | 395 | 513 | 189.8 | 135.5 | 151.7 | 157.2 | 200.0 |
| ចំណូលមិនមែនពន្ធ | 204 | 348 | 424 | 424 | 501 | 513 | 530 | 147.8 | 108.5 | 168.3 | 151.0 | 183.1 |
| អាជីវកម្មព្រៃឈើ | 20 | 36 | 28 | 29 | 15 | 7 | 2 | 0.1 | 0.5 | 0.7 | 0.3 | 0.9 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 88 | 108 | 124 | 122 | 123 | 120 | 94 | 38.0 | 11.4 | 30.0 | 11.7 | 30.0 |
| ចំណូលជាមូលធន | 36 | 12 | 8 | 9 | 16 | 31 | 19 | 126.3 | 2.7 | 4.6 | 15.4 | 354.7 |
| ចំណាយសរុប | 1296 | 1792 | 2332 | 2332 | 2948 | 2757 | 2932 | 998.9 | 881.7 | 1,012.0 | 924.0 | 1,078.4 |
| ចំណាយជាមូលធន | 368 | 624 | 976 | 977 | 1388 | 1171 | 1163 | 350.3 | 340.1 | 386.6 | 317.2 | 349.8 |
| ចំណាយចរន្ត | 980 | 1164 | 1356 | 1355 | 1560 | 1586 | 1769 | 648.6 | 541.7 | 625.4 | 606.9 | 728.7 |
| អប់រំ និងសុខាភិបាល | 132 | 280 | 344 | 343 | 454 | 473 | 518 | 228.4 | 80.3 | 202.3 | 150.1 | 281.3 |
| ការពារជាតិ និងសន្តិសុខ | 448 | 464 | 404 | 405 | 438 | 411 | 423 | 71.4 | 78.1 | 116.7 | 155.3 | 170.1 |
| ក្រសួងផ្សេងៗទៀត | 332 | 412 | 636 | 637 | 668 | 702 | 828 | 348.8 | 383.2 | 306.4 | 301.5 | 277.3 |
| ឱនភាពជាទូទៅ | -380 | -476 | -804 | -803 | -1204 | -992 | -805 | -171.0 | -285.9 | -280.5 | -191.9 | 120.7 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 268 | 416 | 768 | 766 | 1249 | 886 | 864 | 269.0 | 257.6 | 333.3 | 228.6 | 296.5 |
| ហិរញ្ញប្បទានក្នុងស្រុក | 112 | 60 | 36 | 37 | -45 | 106 | 148 | -97.9 | 28.3 | -52.8 | -36.7 | -417.2 |

*Provisional for 2006. * Revised. Source: Ministry of Economy and Finance.*

## តារាង ៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួល) អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ១៩៩៨-២០០៥

| | 1998 | 1999 | 2000 | 2001* | 2002 | 2003 | 2004 | 2005 Q4 | 2006 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | |
| ខេត្ត | - | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 14.4 | 16.6 | 15.8 | 12.0 | 8.5 | 7.2 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 14.8 | 4.0 | -0.8 | 0.2 | 3.3 | 1.1 | 3.9 | 6.6 | 6.1 | 4.5 | 4.9 | 3.4 |
| - ម្ហូបអាហារ | 14.1 | 7.6 | -3.4 | -2.5 | 1.8 | 1.5 | 6.4 | 10.6 | 10.6 | 6.3 | 5.8 | 3.3 |
| - ដឹកជញ្ជូន | 15.1 | 3.5 | 6.6 | -4.2 | 0.3 | 4.9 | 9.7 | 10.2 | 9.7 | 10.0 | 10.1 | 6.8 |
| | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | |
| រៀលក្នុង ១ ដុល្លារ* | - | - | 3840.8 | 3916.3 | 3912.1 | 3973.3 | 4016.3 | 4,154.3 | 4,094.8 | 4,106.6 | 4,145.3 | 4129.4 |
| រៀលក្នុង ១ បាតថៃ* | - | - | 95.8 | 88.2 | 91.1 | 95.8 | 99.9 | 101.4 | 103.5 | 108.0 | 110.3 | 112.9 |
| រៀលក្នុង ១០០ ដុងវៀតណាម* | - | - | 27.1 | 26.6 | 25.6 | 25.6 | 25.5 | 26.1 | 25.4 | 25.0 | 24.9 | 24.9 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 40.4 | 36.0 | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 57.0 | 64.2 | 72.2 | 73.0 | 72.8 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 883 | 1065 | 1105 | 1329 | 1521 | 1508 | 3442 | 2,921 | 2,867 | 3,110 | 3,333 | 3,250 |
| ថ្លៃសាំង (រៀល/លីត្រ) | 1378 | 1613 | 1760 | 2113 | 2084 | 2150 | 2633 | 3,750 | 3,767 | 4,000 | 4,200 | 4,050 |

** Revised. Sources: CDRI, IMF, NIS, Ministry of Planning, Ministry of Economy and Finance*

## តារាង ៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៨-២០០៦ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 Q4 | 2006 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 1726 | 2019 | 2589 | 3080 | 3737 | 4027 | 4797 | 5,475 | 6,410 | 6,682 | 6,958 | 7,224 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -496 | -576 | -759 | -876 | -849 | -698 | -467 | -450 | -699 | -637 | -497 | -282 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 178 | 103 | 3 | -75 | -119 | -128 | -209 | -421 | -755 | -831 | -892 | -853 |
| ឥណទានចំពោះផ្នែកឯកជន | 655 | 763 | 898 | 936 | 1059 | 1337 | 1817 | 2,394 | 2,778 | 2,997 | 3,288 | 3,628 |
| រូបិយវត្ថុទូទៅ M2 | 1230 | 1443 | 1831 | 2204 | 2888 | 3328 | 4329 | 5,025 | 5,711 | 6,045 | 6,461 | 6,942 |
| រូបិយវត្ថុ M1 | 543 | 531 | 540 | 609 | 813 | 937 | 1153 | 1,323 | 1,449 | 1,512 | 1,563 | 1,658 |
| រូបិយវត្ថុផ្សេងៗ | 687 | 911 | 1291 | 1594 | 2075 | 2391 | 3176 | 3,702 | 4,262 | 4,533 | 4,898 | 5,285 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 15.2 | 30.0 | 16.1 | 27.0 | 30.6 | 29.4 | 38.2 |
| រូបិយវត្ថុ M1 | 41 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 14.7 | 20.9 | 24.4 | 22.2 | 25.3 |
| រូបិយវត្ថុផ្សេងៗ | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 15.2 | 32.8 | 16.6 | 33.6 | 32.8 | 31.9 | 42.7 |

*Source: National Bank of Cambodia*

## តារាង ៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2003 | 2004 | 2005 | 2006 | | | | 2007 | 2006 | | 2007 |
| | វិច្ឆិកា | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7873 | 8546 | 6063 | 7393 | 6534 | -23% | -5% | -17% |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 6519 | 7375 | 5238 | 7045 | 6010 | -13% | 9% | -8% |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6186 | 6492 | 5197 | 6125 | 6125 | -12% | -27% | -1% |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 4984 | 4512 | 4266 | 3903 | 4530 | -2% | -19% | -9% |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4670 | 4243 | 4292 | 4498 | 4078 | -8% | 16% | -13% |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4127 | 4541 | 4137 | 4653 | 4126 | 3% | 10% | 0% |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 9184 | 7860 | 9264 | 8957 | 11146 | 6% | 3% | 21% |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8884 | 8790 | 6744 | 8386 | 9144 | -28% | -13% | 3% |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 5974 | 6407 | 6028 | 5263 | 5094 | -1% | -21% | -15% |
| កម្មករសំណង់មានជំនាញ | 13127 | 13111 | 12679 | 10316 | 11750 | 9833 | 9466 | 10215 | 10146 | -8% | -9% | -14% |

** Waitresses' earnings do not include meals and accommodation provided by shop owners.*
*Surveys on the revenue of waitresses, rice-field workers, garment workers, unskilled workers, motocycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ១០* **ចេញពីការពឹងផ្អែកលើជំនួយ...**

ខ្ញុំតែងគិតថា ប្រាក់ចំណូលដែលកម្ពុជានឹងទទួលបានពីធនធានធម្មជាតិនាពេលឆាប់ៗ គឺជាឱកាសលើកទី២របស់កម្ពុជា ដើម្បីដណ្ដើមមកវិញនូវកិត្យានុភាពនៃអារ្យធម៌ដ៏យូរលង់របស់ខ្លួន និងជាឱកាសលើកទី២ដើម្បីក្លាយជាគំរូ ជាទីប្រាថ្នារបស់ប្រទេសជិតខាងម្ដងទៀត ។ ឆ្នាំនេះជាឆ្នាំដ៏មានឫក្សដើម្បីចាប់ផ្ដើម "ឱកាសលើកទី២" នេះ ។ យើងទាំងអស់គ្នាទើបតែប្រារព្ធពិធីចូលឆ្នាំកុរ ដែលជាឆ្នាំនៃជ្រូកមាស ។ ខ្ញុំយល់ឃើញថា ឆ្នាំជ្រូកគឺជាឆ្នាំមានលាភពិសេសសំរាប់វិនិយោគទុន និងស្ថិរភាព ។ ខ្ញុំនៅតែគិតថា ដើម្បីធានាស្ថិរភាព និងធ្វើវិនិយោគដោយឈ្លាសវៃដើម្បីកសាងអនាគតកម្ពុជា លក្ខណៈល្អៗរបស់ជ្រូក ដូចជា ភាពឆ្លាតវៃ ស្លូតបូត ទៀងត្រង់ សប្បុរស និងឧស្សាហ៍ព្យាយាម ត្រូវមានជាចាំបាច់។

### ឯកសារយោងសំខាន់មួយចំនួនពីវិទ្យាស្ថាន CDRI


Corden, W.M. & J.P. Neary (1982), "Booming Sector and De-industrialization in a Small Open Economy", *Economic Journal*, 92 (December), pp. 825–848

Deacon, Robert & Bernardo Mueller (2004), "Political economy and natural resource use", departmental working papers (University of California, Santa Barbara)

Collier, Paul & Anke Hoeffler (2006), "Civil War", draft chapter for the *Handbook of Defence Economics* (University of Oxford)

Rosser, Andrew (2006), "The political economy of the resource curse: A literature survey", IDS Working paper 268, Institute of Development Studies, UK)

Sok Sina, "Windfall Revenue from Oil and Gas in Cambodia: a Development Blessing or a Curse?", in *Annual Development Review 2006-2007* (Phnom Penh: CDRI)

UNDP (2005), "Review of Development Prospects and Options for the Cambodian Oil and Gas, Sector", Final Mission Report, 11–23 July

UNDP (2006), "A SWOT analysis of the Cambodian Economy", Discussion paper in cooperation with the Supreme National Economic Council and Harvard's Kennedy School


### ឯកសារបោះពុម្ពថ្មីៗ

**Annual Development Review 2006-07**
*by Ann Sovatha, Brett M. Ballard, Christian Sloth, David Craig, Eng Netra, Hing Vutha, Horng Vuthy, Jenny Knowles, Kasper K. Hansen, Kim Sedara, Lim Sovannara, Nou Keosothea, Pak Kim Choeun, Phann Dalis, Phim Runsinarith, Pon Dorina, So Sovannarith, Sok Sina, Top Neth, Thun Vathana and Tuot Sokphally*

Working Paper 35:

**Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia** *by Kim Sedara and Joakim Öjendal*

Working Paper 34:

**Accountability and Neo-patrimonialism in Cambodia: A Critical Literature Review**
*by Pak Kimchoeun, Horng Vuthy, Eng Netra, Ann Sovatha, Kim Sedara, Jenny Knowles and David Craig*

Working Paper 33:

**Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia**
*by Kasper K. Hansen and Neth Top*

ARTNeT (Asia-Pacific Research and Training Network on Trade):

**Trade Research Institutions in Asia-Pacific: Capacity-Building Needs in Developing Countries**
*by Hing Vutha, Larry Strange and K.A.S. Murshid*

### ឯកសារពិភាក្សាជិតចេញផ្សាយ

1. Accountability and Planning in Decentralised Cambodia
2. Accountability and Public Human resource Management in Decentralisation
3. Accountability and Public Expenditure Management in Decentralised Cambodia

*តពីទំព័រ ២៤* **ព័ត៌មានថ្មីៗពី...**

ទេសចរណ៍អំណោយផលដល់អ្នកក្របានចប់សព្វគ្រប់ហើយ ។ ការសិក្សារួមគ្នារបស់ DAN និងឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI នឹងបោះពុម្ពផ្សាយនៅខែសីហា ឆ្នាំ២០០៧ ។

ជាបន្ថែមលើឯកសារពិភាក្សាលេខ៣៤ ស្ដីពីគណនេយ្យភាព ដែលបានបោះពុម្ពផ្សាយហើយ នៅមានឯកសារពិភាក្សា ៣ទៀត ស្ដីពីគណនេយ្យភាព និងការគ្រប់គ្រងចំណាយសាធារណៈ ការរៀបចំផែនការ ការសំរបសំរួល និងសេវាសាធារណៈ កំពុងស្ថិតក្នុងដំណាក់កាលសរសេរបញ្ចប់ ។ ឯកសារពិភាក្សាទាំងនេះគ្រោងបោះពុម្ពផ្សាយនៅចុងខែសីហា ឆ្នាំ២០០៧ ។ ឯកសារពិភាក្សាស្ដីពី ទំនាក់ទំនងនិងគណនេយ្យភាព រវាងក្រុមប្រឹក្សាឃុំសង្កាត់ដែលជាប់ឆ្នោត និងសង្គមស៊ីវិល បានបោះពុម្ពរួចហើយ ។

កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវខាងការគ្រប់គ្រងធនធានទឹក (WRMRCPD) ជាគំរោងរយៈពេល៥ឆ្នាំ ពីខែកក្កដា ឆ្នាំ២០០៦ ដល់ខែមិថុនា ឆ្នាំ២០១១ ឧបត្ថម្ភមូលនិធិដោយទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) បានបង្កើតទំព័រនៅក្នុងវេបសាយរបស់វិទ្យាស្ថាន CDRI www.cdri.org.kh ហើយនិងធ្វើបច្ចុប្បន្នភាពជាបណ្ដើរៗនៅពេលគំរោងរីកលូតលាស់ទៅមុខ ។

ការសិក្សាមួយនៅខេត្តកំពង់ចាម និងខេត្តកំពង់ធំ បានធ្វើឡើងដើម្បីប្រៀបធៀបតំលៃផ្ទាល់ និងមិនផ្ទាល់នៃការប្រើប្រាស់ដីកាលពីមុន និងការយកដីទៅធ្វើចំការកៅស៊ូ ដោយផ្អែកលើផលត្រលប់ប៉ាន់ស្មាននៃចំការកៅស៊ូមានអាយុខុសៗគ្នា ដែលមានដំណើរការជាប់លាប់ហើយ ។

សាកលវិទ្យាល័យ Copenhagen ប្រទេសដាណឺម៉ាក ក្រោមកិច្ចសហការជាមួយផ្នែកបរិស្ថាន និងធនធានធម្មជាតិ នៃវិទ្យាស្ថាន CDRI បានរៀបចំសំណើមួយដើម្បីសិក្សាពីតួនាទីព្រៃត្រូពិច ក្នុងការកាត់បន្ថយភាពក្រីក្រ ហើយបានដាក់ជូនពិនិត្យ និងទទួលការអនុមតិពីក្រុមប្រឹក្សាភិបាលការស្រាវជ្រាវ របស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (Danida) ។ គំរោងនេះ មានរយៈពេល ៤១ខែ គឺពីខែសីហា ឆ្នាំ២០០៧ ដល់ ខែធ្នូ ឆ្នាំ២០១០ ។

## ផ្នែកកសាងសន្ដិភាព និងការបំប្លែងទំនាស់

ដូចក្នុងឆ្នាំមុនៗដែរ ក្រុមបណ្ដុះបណ្ដាលរបស់មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CPD) បានបើកវគ្គបណ្ដុះបណ្ដាលបង្គោលស្ដីពីការងារកសាងសន្តិភាព ។ មានអង្គការចំនួន៣ បានស្នើឱ្យមជ្ឈមណ្ឌលផ្ដល់នូវវគ្គបណ្ដុះបណ្ដាលតាក់តែងយ៉ាងពិសេសស្ដីពីការគ្រប់គ្រងទំនាស់ និងជំនាញប្រស្រ័យទាក់ទង ។ មជ្ឈមណ្ឌល ក៏បានផ្ដល់នូវវគ្គបណ្ដុះបណ្ដាលស្ដីពីការកសាងសន្តិភាព (TOT) ដល់សិក្ខាកាម ១១នាក់ ដែលបានសិក្សាក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីការងារកសាងសន្តិភាពកាលពីមុន ។

### *យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា (ខប់សែល ដំណាក់កាលទី២)*

ខប់សែល បានបន្តសកម្មភាពរបស់ខ្លួនក្នុងការរៀបចំ ខប់សែលប្រជុំទូលាយ (COPCELEM) នៅក្រុងភ្នំពេញ ខប់សែលប្រជុំថ្នាក់ខេត្ត-ក្រុងជុំទី២ (COPCELPROM) ដើម្បីពិភាក្សាបញ្ហាពាក់ព័ន្ធនឹងការបោះឆ្នោត ហើយនិងកិច្ចប្រជុំជាន់ខ្ពស់ចំនួន២ និងសន្និសីទថ្នាក់ជាតិមួយ ស្ដីពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីដកស្រង់បទពិសោធន៍ពីការបោះឆ្នោតឃុំ-សង្កាត់មុន យកធ្វើជាមេរៀនសំរាប់រៀបចំការបោះឆ្នោតលើកក្រោយៗទៀត ។ ខប់សែល តាមរយៈប្រព័ន្ធផ្សព្វផ្សាយ (COPCELMED) ក៏បានធ្វើឡើងដែរ ដើម្បីជំរុញឱ្យមានប្រជាជនចូលរួមកាន់តែច្រើនក្នុងការបោះឆ្នោត ។

## ផ្នែកបោះពុម្ពផ្សាយ

នៅរយៈ៣ខែចុងក្រោយនេះ សៀវភៅសំខាន់ដែលបានបោះពុម្ពផ្សាយរួមមាន របាយការណ៍ស្ដីពីការវាយតំលៃភាពក្រីក្រដោយមានការចូលរួមនៅតំបន់ជុំវិញបឹងទន្លេសាប (PPA) របាយការណ៍ប្រចាំឆ្នាំ២០០៦-០៧ របស់វិទ្យាស្ថាន CDRI និងឯកសារពិភាក្សា ២ទៀត ស្ដីពីគណនេយ្យភាពនិងរបបមេកើយបែបថ្មី និងរបបវិមជ្ឈការនិងប្រជាធិតេយ្យនៅកម្ពុជា ។ នៅពេលជាមួយគ្នា វិទ្យាស្ថាន CDRI បានពង្រីកបណ្ដាញការងាររបស់ខ្លួនជាមួយរោងពុម្ព និងក្រុមហ៊ុនបកប្រែ ។

ផ្នែកបោះពុម្ពផ្សាយ បានបង្កើនសន្ទុះការបណ្ដុះបណ្ដាលភ្ជាប់នឹងការងារក្នុងជំនាញបកប្រែ កែសំរួលអត្ថបទភាសាខ្មែរ និងរៀបចំរចនាប្លង់និងក្របសៀវភៅសំរាប់ឯកសារបោះពុម្ពផ្សាយផ្សេងៗ ។ បុគ្គលិកផ្នែកផ្សព្វផ្សាយ ក៏បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលខ្លីៗស្ដីពី ការបង្កើតមាតិកាលើវេបសាយ និងកម្មវិធី Adobe Photoshop សំរាប់ធ្វើការរចនាកែលំអរូបភាពផងដែរ ។

## បណ្ណាល័យ

បន្ទាប់ពីមានការផ្លាស់ប្ដូរមកប្រើកម្មវិធីថ្មី NewGenLib ដើម្បីសំរួលដល់ប្រតិបត្តិការក្នុងបណ្ណាល័យ បុគ្គលិកបណ្ណាល័យកំពុងរៀបចំសៀវភៅរបស់ខ្លួន ទៅតាមបទដ្ឋានអន្តរជាតិដូចនៅក្នុង Library of Congress System ។ បុគ្គលិកទាំងនេះ ក៏ជួយណែនាំដល់អ្នកប្រើប្រាស់បណ្ណាល័យឱ្យចេះប្រើកម្មវិធីថ្មីនេះផងដែរ ។

នៅខែមិថុនា អ្នកគ្រប់គ្រង និងជំនួយការបណ្ណាល័យម្នាក់ បានទៅចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីកម្មវិធី NewGenLib ដែលរៀបចំឡើងដោយ វិទ្យាស្ថានបណ្ដុះបណ្ដាលអ្នកគ្រប់គ្រងការងារអភិវឌ្ឍន៍នៅកម្ពុជា (VBNK) ។

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានយល់ព្រមនឹងសំណើរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្នុងការប្រើប្រាស់បណ្ណាល័យនៃវិទ្យាស្ថាន CDRI ជាកន្លែងសំរាប់រក្សាឯកសាររបស់ពួកគេ ។ បច្ចុប្បន្ន ស្ថាប័នចំនួន៩ បានទុកឯកសាររបស់ខ្លួននៅបណ្ណាល័យនៃវិទ្យាស្ថាន CDRI គឺមាន ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក គំរោងអន្តរភ្នាក់ងាររបស់សហប្រជាជាតិ (UNIAP) វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍សង្គមរបស់សហប្រជាជាតិ (UNRISD) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។

# ព័ត៌មានថ្មីៗ ពី CDRI-វបសអ

## ការគ្រប់គ្រង

កាលពីខែឧសភា លោក Larry Strange នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានអញ្ជើញទៅចូលរួមក្នុងសន្និសីទអន្តរជាតិមួយ ស្ដីពីសាកលភាវូបនីយកម្ម និងសមាហរណកម្មក្នុងតំបន់ រៀបចំដោយវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា (IRIC) ដោយបានធ្វើបទបង្ហាញស្ដីពី "កម្ពុជា-ផលប្រយោជន៍រួម និងទំរង់នៃកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មនៅក្នុង និងក្រៅតំបន់អាស៊ាន" ។

នៅខែមិថុនា វិទ្យាស្ថាន CDRI មានបើកសិក្ខាសាលាជាន់ខ្ពស់មួយស្ដីពីការស្រាវជ្រាវគោលនយោបាយសាធារណៈនៅកម្ពុជា ដែលរៀបចំដោយសាលាភូមិន្ទរដ្ឋបាល ក្នុងកិច្ចសហការជាដៃគូជាមួយវិទ្យាស្ថាន CDRI និងសាលារដ្ឋបាលជាន់ខ្ពស់នៃសាកលវិទ្យាល័យស៊ីដនី ។ សិក្ខាសាលាបានពិភាក្សាលើការវិវត្តន៍ថ្មីៗក្នុងកំណែទំរង់វិស័យសាធារណៈនៅកម្ពុជា អត្ថន័យកំណែទំរង់ចំពោះតំរូវការស្រាវជ្រាវខាងគោលនយោបាយសាធារណៈ និងវិធីសាស្ត្រប្រសើរបំផុត ដើម្បីធ្វើការអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវខាងគោលនយោបាយសាធារណៈ តាមរយៈស្ថាប័ន ដូចជា សាលាភូមិន្ទរដ្ឋបាល ដែលជាស្ថាប័នបណ្ដុះបណ្ដាលមន្ត្រីរាជការកម្ពុជា ជាដើម ។

លោក ច័ន្ទ សុផល ប្រធានស្រាវជ្រាវជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI ត្រូវបានជ្រើសតាំងជាប្រធានគ្រប់គ្រងថ្មីនៃសមាគមសេដ្ឋកិច្ចកម្ពុជា (CEA) ។ នៅវិទ្យាស្ថាន CDRI នឹងមានបង្កើតលេខាធិការដ្ឋានតូចមួយ ដើម្បីជួយគាំទ្រដល់ CEA ។ ថ្នាក់គ្រប់គ្រងវិទ្យាស្ថាន CDRI ត្រៀមធ្វើការយ៉ាងជិតស្និទ្ធជាមួយ CEA នៅក្រោមការដឹកនាំរបស់លោក ច័ន្ទ សុផល សំដៅពង្រឹងគុណភាពការស្រាវជ្រាវខាងសេដ្ឋកិច្ច និងការអប់រំខាងសេដ្ឋកិច្ចនៅកម្ពុជា ។

វិទ្យាស្ថាន CDRI សូមអរគុណជាពន្លឹកដល់ នាយកដ្ឋានសំរាប់អភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (DFID) ចំពោះការបន្តជំនួយគាំទ្រដល់កម្មវិធីអភិបាលកិច្ច ប្រជាធិបតេយ្យ និងកំណែទំរង់វិស័យសាធារណៈ រហូតដល់ខែមីនា ឆ្នាំ២០០៨ ។

## ផ្នែកស្រាវជ្រាវ

ការវិវត្តន៍ចំបងមួយក្នុងកម្មវិធីស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI គឺការចូលកាន់តំណែងជានាយកផ្នែកស្រាវជ្រាវថ្មីនៃលោកបណ្ឌិត Hossein Jalilian ហើយលោកបណ្ឌិត Brett Ballard ដែលបានបំពេញមុខងារជានាយកផ្នែកស្រាវជ្រាវស្ដីទី អស់រយៈជិត២ឆ្នាំ បានទៅបំពេញមុខងារជាទីប្រឹក្សាស្រាវជ្រាវជាន់ខ្ពស់វិញ ។

កិច្ចពិភាក្សាតុមូល ស្ដីពីសេចក្ដីព្រាងរបាយការណ៍លើការសិក្សាការចាកផុតពីភាពក្រីក្រ (MOPS) បានធ្វើឡើងនៅវិទ្យាស្ថាន CDRI និងបានទទួលយោបល់ដ៏មានប្រយោជន៍យ៉ាងច្រើន សំរាប់បញ្ចូលក្នុងរបាយការណ៍បញ្ចប់នៅខែកក្កដា ។ របាយការណ៍សំរេចនឹងចេញផ្សាយនៅខែសីហា ឆ្នាំ២០០៧ ។ របាយការណ៍វាយតំលៃភាពក្រីក្រដោយមានការចូលរួមនៅតំបន់ជុំវិញបឹងទន្លេសាប (PPA) បានបោះពុម្ព និងផ្សព្វផ្សាយយ៉ាងទូលំទូលាយផងដែរ ។

បណ្ដាញវិភាគអភិវឌ្ឍន៍ (DAN) ដែលរួមមានវិទ្យាស្ថានស្រាវជ្រាវមកពីកម្ពុជា ឡាវ ថៃ វៀតណាម និងចិន កំពុងធ្វើការសិក្សាគំរោងចំនួន២ ស្ដីពីជនចំណាកស្រុកឆ្លងដែននៅមហាអនុតំបន់មេគង្គ និងពាណិជ្ជកម្មខាងកសិកម្ម នៅមហាអនុតំបន់មេគង្គ ។ គំរោងមុនស្ដីពី

*តទៅទំព័រទី ២៣*

**ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា**

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១១ លេខ២ ខែមេសា-មិថុនា ឆ្នាំ២០០៧

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ សំរាប់ពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពល ដល់ប្រទេសកម្ពុជា ។ *អត្ថបទតាមដានសេដ្ឋកិច្ច* ផ្ដល់ការវាយតំលៃឯករាជ្យស្ដីពីដំណើរវិវត្តន៍នៃសេដ្ឋកិច្ចកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវមានចុះហត្ថលេខាប្រត្យក្សភាព លេខទូរស័ព្ទ និងអាសយដ្ឋាន ។ អ្នកនិពន្ធ ត្រូវទាក់ទងមក CDRI-វបសអ មុននឹងផ្ដល់អត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ CDRI-វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយពុំមានបញ្ជាក់ហេតុផល ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, (៨៥៥-១២) ៨៦៧ ២៧៨
🖶 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh, http://www.cdri.org.kh

គ្រឹះស្ថានផ្សាយ: វិទ្យាស្ថាន CDRI
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា
ជំនួយការកែសំរួល: យេន សុផានី និង គីម ចិត្រា
រូបភាពទំព័រមុខ: ដកស្រង់ចេញពីបទបង្ហាញរបស់លោក Douglas Gardner អ្នកសំរបសំរួលនៃអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ក្នុងសន្និសីទចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៧ រៀបចំដោយ CDRI

បោះពុម្ព នៅរោងពុម្ពជប៉ុន ភ្នំពេញ

© រក្សាសិទ្ធិ ២០០៧ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ CDRI-វបសអ ទេ ។